គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គ.ជ.ប.ជ

NATIONAL COMMITTEE FOR COUNTER TRAFFICKING (N.C.C.T)

# ក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍

# ក្នុងការអនុវត្ត

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# ២០២៤-២០២៨



# ក្របខ័ណ្ឌតាមដាន វាយតម្លៃ
# និងសិក្សាដកពិសោធន៍
# ក្នុងការអនុវត្ត

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធ
# ប្រឆាំងអំពើជួញដូរមនុស្ស

# (២០២៤-២០២៨)

# សេចក្តីថ្លែងអំណរគុណ

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សយ៉ាងដាច់ខាត ព្រោះវាបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ ផលប្រយោជន៍ សេចក្តីថ្លៃថ្នូរ សន្តិសុខ សុវត្ថិភាព និងអាយុជីវិតរបស់ប្រជាពលរដ្ឋ។

ការប្តេជ្ញាចិត្តនេះ ក៏បានឆ្លុះបញ្ចាំងផងដែរ អំពីភាពដឹកនាំដ៏មុតមាំ និងកិច្ចសហការយ៉ាងទូលំទូលាយរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ.) ដែលដឹកនាំដោយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន មានក្រសួងស្ថាប័ន ទាំង២២ និង០៥អង្គភាពជំនាញជាសមាជិក និងមានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិដើម្បីរួមគ្នាធ្វើសកម្មភាពតាមផែនការ និងយុទ្ធសាស្ត្រដ៏ជាក់លាក់ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស សង្គ្រោះ ការពារ ដោយផ្អែកលើច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តដែលមានជាធរមានរហូតទទួលបានជោគជ័យ។

ក្នុងតួនាទីជាសេនាធិការនៃរាជរដ្ឋាភិបាល យើងខ្ញុំតំណាងឱ្យគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្រ និងចូលរួម ពីដៃគូអភិវឌ្ឍន៍ទាំងឡាយ ក្នុងគោលដៅពង្រឹងកិច្ចប្រឹងប្រែងប្រឆាំងអំពើជួញដូរមនុស្សរបស់ព្រះរាជាណាចក្រកម្ពុជា។ ការរៀបចំក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ នេះ ត្រូវបានរៀបចំឡើងដោយមានកិច្ចសហការ គាំទ្រទាំងធនធានបច្ចេកទេស និងថវិកាដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីប្រឆាំងការជួញដូរមនុស្សអាស៊ាន-អូស្ត្រាលី (ASEAN-ACT) និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយបានធ្វើការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ទាំងក្នុងរាជរដ្ឋាភិបាល និងដៃគូមិនមែនរដ្ឋាភិបាលជាច្រើនលើក ច្រើនសារ រហូតបានសម្រេចនូវឯកសារ ជាស្ថាពរ និងត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦នេះ។

ក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) សម្រាប់ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រាំឆ្នាំ (២០២៤-២០២៨) នេះ គឺជាការឆ្លុះបញ្ចាំងនូវកិច្ចខិតខំរួមគ្នារបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀតក្នុងការពង្រឹងប្រព័ន្ធជាតិសម្រាប់ការត្រួតពិនិត្យ និងរាយការណ៍ស្តីពីកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ MEL គឺជាវិធីសាស្ត្រនៃការតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការ និងការរាយការណ៍ប្រកបដោយប្រសិទ្ធភាព ដែលមានសារៈសំខាន់ក្រៃលែងសម្រាប់ការយល់ដឹងអំពីទំហំ និងប្រភេទនៃអំពើជួញដូរមនុស្ស ការកំណត់និន្នាការថ្មីៗ រួមទាំងចន្លោះប្រហោងនានា ដោយជានាឱ្យបាននូវការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយមានព័ត៌មានគ្រប់គ្រាន់ នៅក្នុងការបង្ការ ទប់ស្កាត់ ការផ្តល់កិច្ចការពារ ការផ្តន្ទាទោសជនល្មើស និងការឆ្លើយតបក្នុងភាពជាដៃគូ។ តាមរយៈការពង្រឹងការទទួលខុសត្រូវ

ការសិក្សាជកពិសោធន៍ និងការប្រើប្រាស់ទិន្នន័យ ក្របខ័ណ្ឌនៃការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍នេះ បំពេញមុខងារជាឧបករណ៍ជាក់ស្តែងមួយដើម្បីលើកកម្ពស់ និងជំរុញប្រសិទ្ធភាពនៃគោលនយោបាយ និងអន្តរាគមន៍កម្រិតជាតិ លើកកម្ពស់ការសម្របសម្រួលក្នុងចំណោមស្ថាប័នទទួលបន្ទុក និងគាំទ្រវិធានការនានាដែលមានលក្ខណៈឆ្លើយតប និងគោលដៅច្បាស់លាស់ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃបណ្តាក្រសួង ស្ថាប័ន និងដៃគូទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមគ្នាទទួលខុសត្រូវតាមជំនាញរៀងៗខ្លួន ដោះស្រាយបញ្ហាជួញដូរមនុស្សដែលបាន និងកំពុងរីករាលដាលក្នុងតំបន់ និងក្នុងពិភពលោក ដើម្បីលើកស្ទួយយុត្តិធម៌សង្គម ផ្តល់កិច្ចការពារដល់ជនរងគ្រោះ និងជនងាយរងគ្រោះ ដោយលើកកម្ពស់ការគោរពសិទ្ធិមនុស្ស សម្រាប់មនុស្សគ្រប់រូបដោយគ្មានការរើសអើង។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារ MEL នេះ នឹងត្រូវបានអនុវត្ត ដោយក្រសួងស្ថាប័នពាក់ព័ន្ធ ហើយអាស្រ័យដោយការប្តេជ្ញាចិត្តរួមគ្នានេះ យើងនឹងធ្វើឱ្យសម្រេចនូវផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ឆ្នាំ ២០២៤ - ២០២៨ តាមការរំពឹងទុក។

ថ្ងៃ ពុធ ៤ រោច ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

# អារម្ភកថា

ឯកឧត្តម លោកជំទាវ អនុប្រធាន និងជាប្រធាន ក្រុមការងារអន្តរក្រសួងស្ថាប័ន
ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ជាសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល រាជធានី ខេត្ត និងជាប្រធានគណៈកម្មាធិការរាជធានី ខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាទីរាប់អាន

ផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់រយៈពេលប្រាំឆ្នាំ ឆ្នាំ២០២៤ -២០២៨ ដែលត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រោមការសម្របសម្រួល លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃព្រហស្បតិ៍ ទី០១ ខែសីហា ឆ្នាំ២០២៤ ដែលខ្ញុំក្នុងតួនាទីជា **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអនុប្រធាន **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធាន ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួងស្ថាប័ន ជាសមាជិកទាំង ២២ និងអង្គភាពជំនាញពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ អភិបាលរាជធានី ខេត្តជាប្រធានគណៈកម្មាធិការរាជធានី ខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ/គ.ខ.ប.ជ) ព្រមទាំងអង្គទូតនានានៃបណ្តាប្រទេសពាក់ព័ន្ធ មាននិវេសនដ្ឋាន ក្នុងព្រះរាជាណាចក្រកម្ពុជា អង្គការដៃគូភ្ញៀវជាតិ អន្តរជាតិ សរុបប្រមាណ ជិត ៤០០នាក់។








ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានកសាងឡើង ដោយមានការពិគ្រោះយោបល់ជាច្រើនលើក ច្រើនសារជាមួយថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ យោងតាមការវាយតម្លៃផែនការ ឆ្នាំ២០១៩-២០២៣ ដែលទើបនឹងបញ្ចប់ទៅ ស្ថានភាពប្រែប្រួលជាសាកល ការប្រែប្រួលនៃបទល្មើស និងបណ្តាញជនល្មើស និងប៉ាន់ប្រមាណពីភាពប្រឈម នឹងចំណុចខ្វះចន្លោះ ចំពោះមុខ និងត្រូវដាក់វិធានការដោះស្រាយបន្ត។

យុទ្ធសាស្ត្រគន្លឹះចំនួនបួន ត្រូវបានកំណត់យ៉ាងជាក់លាក់អំពីភាពប្រទាក់ក្រឡា ដែលមិនមានក្រសួង ស្ថាប័នណា ឬវិស័យណាមើលរំលងពីការទទួលខុសត្រូវឡើយគឺ (១)ការលើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ (២)ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ (៣)ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារ និងការផ្តល់សេវាជូនជនរងគ្រោះ និង(៤)គឺជាស្នូលនៃយុទ្ធសាស្ត្រទាំងបី ដែលជាភាពចាំបាច់ត្រូវអនុវត្ត នៅគ្រប់យុទ្ធសាស្ត្រ គឺការពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា។ ឯការតាមដាន វាយតម្លៃ ការរាយការណ៍ ការចងក្រង និងផ្សព្វផ្សាយពីបទពិសោធន៍ ដើម្បីបង្កើនប្រសិទ្ធភាព នឹងត្រូវបានធ្វើឡើងជាប្រចាំផងដែរ។



ដូចនេះ ក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដែលហៅកាត់ថា MEL (Monitoring, Evaluation and Learning) គឺជាឯកសារបង្អែកសម្រាប់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ និងក្រសួងស្ថាប័ន ឬរាជធានីខេត្ត អាចតាមដាន និងឆ្លុះបញ្ចាំង អំពីវឌ្ឍនភាព និងចំណុចខ្លាំង ចំណុចខ្សោយ ក្នុងការអនុវត្តសកម្មភាពប្រចាំឆ្នាំដើម្បីធ្វើឱ្យសម្រេចផែនការយុទ្ធសាស្ត្រជាតិប្រាំឆ្នាំ ២០២៤ ដល់២០២៨។

ក្នុងនាម ជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំសូមអំពាវនាវដល់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំក្រុមការងារអន្តរក្រសួងស្ថាប័នទាំងប្រាំមួយ ក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាល រាជធានី ខេត្ត ដែលជាប្រធានគណៈកម្មាធិការរាជធានី ខេត្ត ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងអស់ នឹងបន្តយកចិត្តទុកដាក់ក្នុងការរៀបចំក្រុមតាមដាន ត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព ដែលបានគ្រោងទុក ដើម្បីកាត់បន្ថយ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស និងភាពរងគ្រោះរបស់ប្រជាពលរដ្ឋពីអំពើជួញដូរមនុស្សគ្រប់ទម្រង់។

ថ្ងៃ ចន្ទ ២ រោច ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ២០២៦

**ប្រធាន គ.ជ.ប.ជ**

**អភិសន្តិបណ្ឌិត ស សុខា**

# រចនាសម្ព័ន្ធគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



# ព័ត៌មានអំពីឯកសារ

ត្រូវបានរៀបចំឡើងសម្រាប់៖ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ. )

គាំទ្រដោយ៖ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)

កាលបរិច្ឆេទ៖ ខែសីហា ឆ្នាំ ២០២៥

# ប្រវត្តិនៃការរៀបចំឯកសារ

| កំណែ | កាលបរិច្ឆេទចូលជាធរមាននៃឯកសារ | ការពណ៌នា | រៀបចំដោយ | លទ្ធផលនៃការពិនិត្យ និងការកែលម្អ |
|---|---|---|---|---|
| 0 | ថ្ងៃទី ៤ ខែតុលា ឆ្នាំ២០២៤ | សេចក្តីព្រាងបឋម( Zero draft) សម្រាប់ពិភាក្សាក្នុងសិក្ខាសាលាខែ វិច្ឆិកា ឆ្នាំ ២០២៤ | Myra Navarro-Mukii ( នាយិកាផ្នែកតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍នៃកម្មវិធី ASEAN-ACT) | សិក្ខាសាលាអន្តរស្ថាប័នដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ដោយសហការជាមួយកម្មវិធី ASEAN-ACT ដើម្បីពិនិត្យមើល និងផ្តល់មតិយោបល់លើសេចក្តីព្រាងបឋមនៅថ្ងៃទី ៥ ដល់ថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០២៤ |
| ០.១ | ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២៤ | បានកែប្រែកំណែសេចក្តីព្រាងបឋមពីព័ត៌មានដែលប្រមូលបានក្នុងអំឡុងពេលសិក្ខាសាលាស្តីពីការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ និងធាតុចូលដែលផ្តល់ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអ្នកចូលរួមសិក្ខាសាលា | Myra Navarro-Mukii ( នាយិកាផ្នែកតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍នៃកម្មវិធី ASEAN-ACT) | បានដាក់ជូន **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអគ្គលេខាធិការដ្ឋាន ដើម្បីពិនិត្យមើលលើកទីមួយ |
| ០.២ | ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២៥ | កែសម្រួល ផ្អែកលើធាតុចូល និងមតិយោបល់ដែលផ្តល់ដោយ គ.ជ.ប.ជ. ក្នុងខែឧសភា ឆ្នាំ២០២៥។ មតិយោបល់ជាខេមរភាសា ត្រូវបានបកប្រែទៅជាភាសាអង់គ្លេសដោយក្រុមការងារកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស | Myra Navarro-Mukii ( នាយិកាផ្នែកតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍នៃកម្មវិធី ASEAN-ACT) | តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអគ្គលេខាធិការដ្ឋាន ក្នុងកិច្ចប្រជុំពិនិត្យឯកសារ ដែលដឹកនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. |

កំណត់សម្គាល់៖ ជំហាននានានៃការរៀបចំ កាលបរិច្ឆេទសំខាន់ៗ និងការអនុវត្តក្របខ័ណ្ឌ MEL ត្រូវបានបង្ហាញជូននៅក្នុងផ្នែក ១.៤ នៃឯកសារនេះ

ឯកសារនេះ ត្រូវបានរៀបចំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) និងត្រូវបានឧបត្ថម្ភគាំទ្រមូលនិធិដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)។ ទស្សនៈទាំងឡាយដែលបានសម្ដែងនៅក្នុងឯកសារនេះ មិនមែនចាំបាច់គឺជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីនោះទេ។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ** ....................ii

**អារម្ភកថា** ....................iv

**ព័ត៌មានអំពីឯកសារ** ....................viii

**ប្រវត្តិនៃការរៀបចំឯកសារ**....................viii

**មាតិកា** ....................x

**ពាក្យកាត់ និងអក្សរបំព្រួញ**....................xii

**១. សេចក្តីផ្តើម និងសាវតារ** ....................១

១.១ ទិដ្ឋភាពទូទៅនៃ....................១

១.២ សាវតារ....................២

១.៣ ទិដ្ឋភាពទូទៅនៃការតាមដាន និងវាយតម្លៃ ....................៦

១.៤ របៀបដែលក្របខ័ណ្ឌ MEL ត្រូវបានរៀបចំ....................៧

**២. ទ្រឹស្តីនៃការផ្លាស់ប្តូរអន្តរក្រសួង-ស្ថាប័ន** ....................១០

**៣. ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ MEL** ....................១៦

៣.១ គោលបំណង និងវិសាលភាព ....................១៨

៣.២ គោលការណ៍....................១៩

៣.៣ គោលដៅអ្នកប្រើប្រាស់នៃក្របខ័ណ្ឌ MEL....................២០

៣.៤ ហានិភ័យ និងការសន្មត ....................២១

**៤. វិធីសាស្ត្រតាមដាន និងវាយតម្លៃ** ....................២៣

៤.១ អភិក្រមនៃការតាមដាន ....................២៣

៤.២ សំណួរវាយតម្លៃសំខាន់ៗ....................២៤

៤.៣ វិធីសាស្ត្រតាមដាន ....................២៦

៤.៤ ការវាយតម្លៃ....................២៩

**៥. ការរាយការណ៍ និងការសិក្សាដកពិសោធន៍**....................៣០

៥.១ ការវិភាគព័ត៌មាន ..... ៣០
៥.២ ការរាយការណ៍ ..... ៣០
៥.៣ ការសិក្សាដកពិសោធន៍ ..... ៣៣
៥.៤ ការអភិវឌ្ឍសមត្ថភាព MEL ..... ៣៥
**៦. សកម្មភាព MEL និងការទទួលខុសត្រូវ** ..... ៣៦
៦.១ សកម្មភាព MEL ..... ៣៦
៦.២ តួនាទី និងការទទួលខុសត្រូវ ..... ៣៦
**៧. ក្រមសីលធម៌ក្នុងការតាមដាន និងវាយតម្លៃ** ..... ៣៩
ឧបសម្ព័ន្ធ កៈ សូចនាករ និងសកម្មភាពដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ ..... ៤០
ឧបសម្ព័ន្ធ ខៈ សូចនាករផលសម្រេច ..... ៥១
ឧបសម្ព័ន្ធ គៈ វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ ..... ៥៣
ឧបសម្ព័ន្ធ ឃៈ សេចក្តីព្រាងលក្ខខណ្ឌយោងការងាររបស់មន្ត្រីទទួលបន្ទុកការងារ MEL ..... ៥៤
ឧបសម្ព័ន្ធ ងៈ សកម្មភាព MEL ..... ៥៩
ឧបសម្ព័ន្ធ ចៈ ពាក្យគន្លឹះ និងនិយមន័យ ..... ៦០


## តារាង និងរូបភាព


តារាងទី ១ អ្នកប្រើប្រាស់ក្របខ័ណ្ឌ MEL ឬ អ្នកអាន ..... ២១
តារាងទី ២ សំណួរវាយតម្លៃសំខាន់ៗ សំណួររង និងសូចនាករ ..... ២៤
តារាងទី ៣ គំរូវិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ ..... ២៧
តារាងទី ៤ កិច្ចដំណើរការរាយការណ៍ និងក្របខ័ណ្ឌពេលវេលា ..... ៣១
តារាងទី ៥ សកម្មភាព ឬព្រឹត្តិការណ៍សិក្សាដកពិសោធន៍សម្រាប់ការគ្រប់គ្រងបត់បែនតាមស្ថានភាព .. ៣៤
តារាងទី ៦ ការទទួលខុសត្រូវក្នុងក្របខ័ណ្ឌ MEL ..... ៣៧

រូបភាពទី ១៖ ទ្រឹស្តីនៃការផ្លាស់ប្តូរអន្តរក្រសួង-ស្ថាប័ននៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) ..... ១៤
រូបភាពទី ២៖ ការផ្សារភ្ជាប់រវាងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២៤-២០២៨ ..... ១៥

# ពាក្យកាត់ និងអក្សរបំព្រួញ

| | | |
|---|---|---|
| ASEAN-ACT | ASEAN-Australia Counter Trafficking | កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស |
| ACTIP | ASEAN Convention against Trafficking in Persons, Especially Women and Children | អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ |
| ACWC | ASEAN Commission for the Promotion and Protection of the Rights of Women and Children | គណៈកម្មាធិការអាស៊ានដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CTIP | counter–trafficking in persons | ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| EOSO | end-of-strategy outcome | លទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ |
| GEDSI | gender equality, disability and social inclusion | សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម |
| KEQ | key evaluation question | សំណួរវាយតម្លៃសំខាន់ៗ |
| M&E | monitoring and evaluation | ការតាមដាន និងវាយតម្លៃ |
| MEL | monitoring, evaluation and learning | ការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ |
| M/PCCT | Municipal/Provincial Committee for Counter Trafficking | គណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.) |
| NCCT | National Committee for Counter Trafficking | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| TIP | Trafficking in persons | អំពើជួញដូរមនុស្ស |

# ១ សេចក្តីផ្តើម និងសាវតារ

ឯកសារនេះបង្ហាញពីក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ក៏ដូចជាវិសាលភាពនៃសកម្មភាព MEL សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨ នៃព្រះរាជាណាចក្រកម្ពុជា។ ក្របខ័ណ្ឌ MEL ផ្តល់ជូនក្រសួង ស្ថាប័ន និងសមាជិកដែលជាអង្គភាពឯកទេសនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) និងគណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.) នៅថ្នាក់ក្រោមជាតិ និងដៃគូនៅក្នុងការតាមដាន ការវាយតម្លៃ និងការរាយការណ៍ នូវការរំពឹងទុក លទ្ធផល គោលការណ៍ និងការអនុវត្តសកម្មភាពគ្រោង និងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។ ឯកសារនេះបានពង្រីកប្រព័ន្ធតាមដាន និងវាយតម្លៃ (M&E) នៃផែនការយុទ្ធសាស្ត្រជាតិ (ផ្នែក ឃ) ដោយផ្តល់ព័ត៌មានលម្អិត និងការពណ៌នាបន្ថែមអំពីរបៀបដែលប្រព័ន្ធតាមដាន និងវាយតម្លៃ (M&E) នឹងត្រូវបានអនុវត្ត។

## ១.១ ទិដ្ឋភាពទូទៅនៃ

ក្របខ័ណ្ឌ MEL នេះចែកចេញជាផ្នែកដូចខាងក្រោម៖

- ផ្នែកទី ១៖ សេចក្តីផ្តើម សាវតារ និងគោលបំណងនៃ MEL
- ផ្នែកទី ២៖ ទ្រឹស្តីនៃការផ្លាស់ប្តូរអន្តរក្រសួង-ស្ថាប័ន
- ផ្នែកទី ៣៖ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ MEL
- ផ្នែកទី ៤៖ វិធីសាស្ត្រតាមដាន និងវាយតម្លៃ
- ផ្នែកទី ៥៖ ការរាយការណ៍ និងការសិក្សាដកពិសោធន៍

- ផ្នែកទី ៦៖ សកម្មភាព MEL និងការទទួលខុសត្រូវ
- ផ្នែកទី ៧៖ ក្រមសីលធម៌ក្នុងការតាមដាន និងវាយតម្លៃ

ឯកសារនេះ មានភ្ជាប់ជាមួយឧបសម្ព័ន្ធ៖

- ឧបសម្ព័ន្ធ ក៖ សូចនាករលទ្ធផលដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ
- ឧបសម្ព័ន្ធ ខ៖ សូចនាករផលសម្រេច
- ឧបសម្ព័ន្ធ គ៖ វិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ
- ឧបសម្ព័ន្ធ ឃ៖ សេចក្តីព្រាងឯកសារយោងការងារនៃមន្ត្រីទទួលបន្ទុកការងារ MEL
- ឧបសម្ព័ន្ធ ង៖ សកម្មភាព MEL
- ឧបសម្ព័ន្ធ ច៖ ពាក្យគន្លឹះ និងនិយមន័យ

## ១.២ សាវតារ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) គឺជាយន្តការជាតិដែលមានភារកិច្ចដឹកនាំ សម្របសម្រួល ប្រមូលព័ត៌មាន វិភាគទិន្នន័យ រាយការណ៍វឌ្ឍនភាព និងផ្តួចផ្តើមកសាងច្បាប់ គោលនយោបាយ និងផែនការនានា ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលុបបំបាត់ការជួញដូរមនុស្សគ្រប់ទម្រង់ ជាអាទិ៍មានការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការបំពាននិងកេងប្រវ័ញ្ចតាមអ៊ីនធឺណិត ការពពោះជំនួសដើម្បីការជួញដូរកុមារ/ទារក និងការជួញដូរសរីរាង្គមនុស្ស។ គ.ជ.ប.ជ. ដឹកនាំការអនុវត្តដែលមានការចូលរួម និងសម្របសម្រួលអនុវត្តផែនការយុទ្ធសាស្ត្រជាតិដោយក្រសួង និងស្ថាប័នជាសមាជិកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀត។

គ.ជ.ប.ជ. ស្ថិតក្រោមការដឹកនាំរបស់ប្រធាន គឺ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មានក្រសួងចំនួន ២២ និងអង្គភាពឯកទេសចំនួន ៥ ជាសមាជិក។ គ.ជ.ប.ជ. មានអគ្គលេខាធិការដ្ឋានមួយ ដែលត្រូវបានដឹកនាំ និងណែនាំដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. ទទួលបន្ទុកដឹកនាំអគ្គលេខាធិការដ្ឋានសម្រាប់កិច្ចប្រតិបត្តិការទូទៅក្នុងគណៈកម្មាធិការជាតិ ដែលអម

ដោយ អគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួន។ អគ្គលេខាធិការដ្ឋាននេះ ដើរតួនាទីសំខាន់ក្នុងការសម្របសម្រួល ដឹកនាំ តាមដាន និងជំរុញកិច្ចសហប្រតិបត្តិការរវាងក្រសួង-ស្ថាប័ន និងដៃគូអន្តរជាតិ និងដៃគូក្នុងស្រុក ដោយផ្តោតសំខាន់លើការអនុវត្តយុទ្ធសាស្ត្រនានាដើម្បីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

នៅចុងឆ្នាំ ២០២៣ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. បានដឹកនាំការងារវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិ (ផ.យ.ជ) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩-២០២៣ (ផ.យ.ជ.)។ លទ្ធផល និងអនុសាសន៍នៃការវាយតម្លៃនេះ បានផ្តល់ព័ត៌មានដល់ការរៀបចំផែនការយុទ្ធសាស្ត្រជាតិបន្ត ដែលត្រូវបានរៀបចំតាមរយៈការពិភាក្សាច្រើនជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានា នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក៏ដូចជា ជាមួយដៃគូជាតិនិងអន្តរជាតិនានា។ លទ្ធផលសម្រេចបាន គឺផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ឆ្នាំ ២០២៤-២០២៨ ដែលត្រូវបានផ្សព្វផ្សាយជាផ្លូវការនៅខែសីហា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គសេនាធិបតីឧត្ដមសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធានគណៈកម្មា ធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.)។

## គោលដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨ មានគោលដៅលុបបំបាត់រាល់ទម្រង់ចាស់ថ្មីនៃអំពើជួញដូរមនុស្ស ដែលបង្កដោយឧក្រិដ្ឋជន តាមរយៈ ការធ្វើសកម្មភាពគ្រប់មធ្យោបាយ ក្នុងគោលបំណងកេងប្រវ័ញ្ចលើមនុស្សដោយទុច្ចរិត ធ្វើឱ្យរងគ្រោះយ៉ាងធ្ងន់ធ្ងរដល់រូបកាយ សុខភាពផ្លូវចិត្ត ផ្លូវភេទ អាយុជីវិត ដែលជាការរំលោភសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់មនុស្សគ្រប់វ័យ គ្រប់យេនឌ័រ គ្រប់ស្ថានភាព គ្រប់ពណ៌សម្បុរ ក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងលើប្រជាជនកម្ពុជានៅក្រៅប្រទេស។

ផែនការយុទ្ធសាស្ត្រជាតិនេះ ជំរុញឲ្យមានសាមគ្គីភាព ឯកភាព និងកិច្ចសហការក្នុងភាពជាដៃគូរវាងសហគមន៍ជាតិនិងអន្តរជាតិ ក្នុងគោលបំណងធានាឱ្យមានប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីបង្ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវភាពរងគ្រោះ ជំរុញការអនុវត្តច្បាប់ និងធ្វើការផ្តន្ទាទោសយ៉ាងសុក្រឹតចំពោះបទឧក្រិដ្ឋនេះ សម្រាប់យុត្តិធម៌សង្គម ជាពិសេសកិច្ចការពារសិទ្ធិ និងផលប្រយោជន៍

ស្របច្បាប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាមនុស្សគ្រប់វ័យ គ្រប់យេនឌ័រ គ្រប់ពណ៌សម្បុរ និងនៅគ្រប់ស្ថានភាពក្នុងសង្គម។

## យុទ្ធសាស្ត្រគន្លឹះទាំងបួននៃផែនការយុទ្ធសាស្ត្រជាតិ

យុទ្ធសាស្ត្រគន្លឹះទាំង ៤ នេះ ត្រូវបានកំណត់ដើម្បីសម្រេចបាននូវគោលដៅនៃផែនការយុទ្ធសាស្ត្រជាតិ និងឆ្លើយតបទៅនឹងដំណាក់កាលទាំង ៣ នៃអំពើជួញដូរមនុស្ស៖ (១) ការបង្ការទប់ស្កាត់ (២) ការអនុវត្តច្បាប់ និង (៣) កិច្ចការពារ និងការផ្តល់សេវាជូនជនរងគ្រោះ។ កិច្ចសហប្រតិបត្តិការគឺជាកត្តាជំរុញ និងស្នូលនៃយុទ្ធសាស្ត្រទាំង ៣ ផ្សេងទៀត។

- យុទ្ធសាស្ត្រទី ១. ការបង្ការទប់ស្កាត់ - លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ។
- យុទ្ធសាស្ត្រទី ២. ការអនុវត្តច្បាប់ - បង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់។
- យុទ្ធសាស្ត្រទី ៣. កិច្ចការពារ និងការផ្តល់សេវាជូនជនរងគ្រោះ - បង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ។
- យុទ្ធសាស្ត្រទី ៤. កិច្ចសហប្រតិបត្តិការ - ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត។

## គោលដៅ និងគោលបំណងនៃការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍

- ធានាបាននូវប្រសិទ្ធភាព និងជោគជ័យនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិប្រាំឆ្នាំស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ ដោយផ្អែកលើសូចនាករដែលបានកំណត់។
- ឆ្លើយតបទៅនឹងគោលបំណងនៃការអនុវត្តការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (ឬសណ្តាប់ធ្នាប់) (Global Compact for Safe, Orderly and Regular Migration: GCM) ដែលកម្ពុជាគឺជាសមាជិក ហើយដែលនៅក្នុងនោះ កម្ពុជា

គឺជាប្រទេសដែលមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តគំនិតផ្តួចផ្តើមនៃនីតិវិធីនេះ ក្នុងនាមជាប្រទេសនាំមុខមួយ ក្នុងការផ្តួចផ្តើមអនុវត្ត GCM (Champion Country for GCM initiative )។

- ផ្តល់មូលដ្ឋានសម្រាប់រៀបចំអនុសាសន៍ជូនដល់រាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេចលើការកែលម្អគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្តនានា ស្របតាមស្ថានភាពដែលប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព។
- មានទិន្នន័យដែលនឹងជួយក្នុងកែលម្អការអនុវត្តផែនការសកម្មភាព។

ក្របខ័ណ្ឌ MEL នេះ រួមបញ្ចូលអនុសាសន៍នានាស្តីពីការតាមដាន វាយតម្លៃ និងរាយការណ៍នៃការវាយតម្លៃឆ្នាំ ២០២៣ លើផែនការយុទ្ធសាស្ត្រជាតិ៖

- បន្តប្រើប្រាស់យន្តការ គ.ជ.ប.ជ. ដែលមានស្រាប់នៅគ្រប់កម្រិត តាមរយៈការរាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ។
- រៀបចំគោលការណ៍ណែនាំស្តីពីការតាមដាន វាយតម្លៃ និងរាយការណ៍ ដើម្បីណែនាំដល់មន្ត្រីថ្មីអំពីរបៀបរាយការណ៍អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- កែសម្រួល/ធ្វើបច្ចុប្បន្នភាពទម្រង់របាយការណ៍ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្របតាមសូចនាករដែលបានកំណត់ដែលអាចប្រើដើម្បីវាស់វែងលទ្ធផលរំពឹងទុកអំពីការអនុវត្តសកម្មភាព ឬកម្រងសកម្មភាពទាំងឡាយនៅក្នុងយុទ្ធសាស្ត្រនីមួយៗនៃផែនការយុទ្ធសាស្ត្រជាតិ។
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. នឹងបន្តសម្របសម្រួល និងតាមដានក្រសួង និងស្ថាប័នពាក់ព័ន្ធដើម្បីឱ្យពួកគេអាចចែករំលែកព័ត៌មាន ឬរាយការណ៍ទាន់ពេលវេលាអំពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលក្រសួងនិងស្ថាប័នពាក់ព័ន្ធបានអនុវត្ត។
- បង្កើនការផ្សព្វផ្សាយដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់អំពីសកម្មភាពនិងអាទិភាពទាំងឡាយដែលបានគ្រោងទុក នៅក្នុងផែនការយុទ្ធសាស្ត្រជាតិខាងមុខ ដើម្បីឱ្យពួកគេអាចយល់បានកាន់តែច្បាស់ អាចរៀបចំផែនការសកម្មភាព និងអាចអនុវត្តសកម្មភាពដែលបានគ្រោងទុកឱ្យកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល។

- គ.ជ.ប.ជ. នឹងពិនិត្យលទ្ធភាពបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យ ដើម្បីប្រមូលព័ត៌មានទាំងអស់ស្តីពីករណីជួញដូរមនុស្សក្នុងប្រទេស ដែលបន្សុីគ្នានឹងមូលដ្ឋានទិន្នន័យជាតិផ្សេងទៀត និងទិន្នន័យដែលដៃគូកំពុងប្រើប្រាស់ ហើយក្នុងពេលជាមួយគ្នានោះ ធានារក្សាការសម្ងាត់ និងឯកជនភាពសម្រាប់បុគ្គលពាក់ព័ន្ធ។
- វាយតម្លៃយន្តការមានស្រាប់នៅតាមក្រសួង និងស្ថាប័ននានាដើម្បីកំណត់វឌ្ឍនភាព បញ្ហាប្រឈម និងជំហានបន្ទាប់ ដើម្បីបង្កើតមជ្ឈមណ្ឌលទិន្នន័យ ទន្ទឹមគ្នានឹងការធានាសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ។
- លើកកម្ពស់ភាពទៀងទាត់នៃកិច្ចប្រជុំរបស់ក្រុមការងារនីមួយៗ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីកែលម្អទំនាក់ទំនង ការចែករំលែកព័ត៌មាន ការអនុវត្តល្អ មេរៀនដែលបានទទួល និងបទពិសោធន៍ជាក់ស្តែងលើការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ ព្រមទាំងពិនិត្យឡើងវិញនូវសកម្មភាពដែលបានគ្រោងទុក បញ្ហាប្រឈមពាក់ព័ន្ធ និងរបៀបឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ។
- ចងក្រងជាឯកសារនូវការអនុវត្តល្អ រួមទាំងការសម្របសម្រួល កិច្ចសហប្រតិបត្តិការ ការផ្តល់ភាពអង់អាច និងការផ្តល់ការគាំទ្រនិងជំនួយដល់ជនដែលធ្លាប់រងគ្រោះ (survivor) ដោយអំពើជួញដូរមនុស្ស ដើម្បីឱ្យពួកគេមានសមត្ថភាព លទ្ធភាព និងឯករាជ្យភាពផ្នែកហិរញ្ញវត្ថុតាមរយៈសកម្មភាពរកប្រាក់ចំណូលដោយខ្លួនឯង និងកិច្ចការផ្សេងៗទៀតទាក់ទិននឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ១.៣ និន្នាការនៃការតាមដាន និងវាយតម្លៃ

ការតាមដាន គឺជាដំណើរការនៃការប្រមូល និងពិនិត្យឡើងវិញជាទៀងទាត់ និងជាប្រព័ន្ធនូវទិន្នន័យមានស្រាប់ ដែលផ្តល់ការចង្អុលបង្ហាញនៅពេលណាមួយអំពីវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផលដែលបានគ្រោងទុក។ ការតាមដានត្រូវបានប្រើជាញឹកញាប់នៅកម្រិតផ្សេងៗនៃស្ថាប័ន និងផ្តល់មូលដ្ឋានព័ត៌មានដល់ការគ្រប់គ្រងផ្ទៃក្នុង ការធ្វើសេចក្តីសម្រេច និងការកែលម្អជាបន្តបន្ទាប់។

ការវាយតម្លៃ គឺជាសកម្មភាពតាមកាលកំណត់ បានគ្រោងទុក និងមានគោលដៅ ដែលឆ្លើយតបនឹងសំណួរវាយតម្លៃសំខាន់ៗ និងផ្អែកលើទិន្នន័យមានស្រាប់ និងថ្មី ដែលភាគច្រើនត្រូវបានបង្កើត

ចេញពីសកម្មភាពតាមដាន ដើម្បីធ្វើការវិនិច្ឆ័យនិងផ្ដល់អនុសាសន៍។ ការវាយតម្លៃអាចជាការវាយតម្លៃផ្ដោតលើដំណើរការ ឬអាចជាការវាយតម្លៃផ្ដោតលើលទ្ធផល និងជួយផ្ដល់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីទិដ្ឋភាពសំខាន់ៗនិងមានតម្លៃនៃអន្តរាគមន៍នានា ដូចជា ប្រសិទ្ធភាព ភាពសមស្រប ភាពពាក់ព័ន្ធ និរន្តរភាព និងផលប៉ះពាល់របស់វា។ ការវាយតម្លៃផ្ដល់ការយល់ដឹង លើកពីសំណួរ «តើធ្វើអ្វី?» «ដោយរបៀបណា?» និង «ហេតុអ្វី?»...។ល។

ការតាមដាន និងវាយតម្លៃ គឺជាសកម្មភាពមានទំនាក់ទំនងគ្នា ហើយនេះគឺជាហេតុផលដែលការតាមដាន និងវាយតម្លៃត្រូវបានបញ្ចូលជាក្របខ័ណ្ឌរួមមួយ។ ជាញឹកញាប់ សូចនាករ និងទិន្នន័យតាមដាន បន្សុីគ្នាទៅនឹងសំណួរវាយតម្លៃ និងផ្ដល់មូលដ្ឋានព័ត៌មានដល់គំហើញពីការវាយតម្លៃ។ ជាញឹកញាប់ គំហើញពីការវាយតម្លៃផ្ដល់មូលដ្ឋានព័ត៌មានដល់សកម្មភាពតាមដានដែលបានកែលម្អនិងមានលក្ខណៈលម្អិតជាងមុន។ រួមគ្នា ការតាមដាន និងវាយតម្លៃ ផ្ដល់នូវមូលដ្ឋានភ័ស្តុតាងដ៏សំខាន់និងដែលមានរចនាសម្ព័ន្ធ សម្រាប់ផ្ដល់មូលដ្ឋានព័ត៌មានដល់ការធ្វើសេចក្ដីសម្រេច ការរៀបចំផែនការយុទ្ធសាស្ត្រ និងការសិក្សាដកពិសោធន៍។

ពាក់ព័ន្ធក្របខ័ណ្ឌ MEL នេះ ការតាមដានត្រូវបានស្នើឡើងនៅកម្រិតផលសម្រេចនិងកម្រិតលទ្ធផលរយៈពេលមធ្យម។ ការប្រមូលទិន្នន័យនៅក្នុងដំណើរការតាមដានដំបូង នឹងផ្ដោតលើការប្រមូលលទ្ធផលក្នុងរយៈពេល ២ឆ្នាំដំបូង នៃសកម្មភាពអនុវត្តដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិ។ ការតាមដានផែនការសកម្មភាពប្រចាំឆ្នាំ ឬផែនការការងារប្រចាំឆ្នាំដែលបានមកពីផែនការយុទ្ធសាស្ត្រជាតិ ក៏នឹងរួមមានការប្រមូលទិន្នន័យ និងការរាយការណ៍អំពីលទ្ធផលផងដែរ (សូមមើលឧបសម្ព័ន្ធ គ សម្រាប់បញ្ជីសូចនាករលទ្ធផល)។ ការវាយតម្លៃអាចធ្វើបាននៅពាក់កណ្ដាលអាណត្តិ និង/ឬនៅចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រជាតិ។ ការវាយតម្លៃដែលបានកំណត់ ទំនងជាផ្ដោតសំខាន់លើលទ្ធផលរយៈពេលមធ្យមនិងរយៈពេលវែង ដើម្បីឆ្លើយតបទៅនឹងសំណួរវាយតម្លៃសំខាន់ៗ (KEQ) និងកំណត់ថាតើគេសម្រេចបានលទ្ធផលរយៈពេលវែងឬទេនៅចុងបញ្ចប់នៃការអនុវត្តផែនការយុទ្ធសាស្ត្រ។

## ១.៤ របៀបដែលក្របខ័ណ្ឌ MEL ត្រូវបានរៀបចំ

រចនាសម្ព័ន្ធនៃក្របខ័ណ្ឌ MEL បានទទួលព័ត៌មានពីការវិភាគលម្អិតលើផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០២៤-២០២៨ និងគំហើញពីការវាយតម្លៃចុងបញ្ចប់លើផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០១៩-២០២៣។ ឯកសារនេះ ពោលគឺ ខ្លឹមសារនិងរចនាសម្ព័ន្ធនៃក្របខ័ណ្ឌ MEL ត្រូវបានរៀបចំ

ដោយប្រើធនធាន/ឯកសារពាក់ព័ន្ធផ្សេងៗ ដូចជាសៀវភៅមគ្គុទេសក៍សម្រាប់ការតាមដានអភិក្រម ដែលយកចិត្តទុកដាក់ចំពោះយេនឌ័រនិងផ្ដោតលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស របស់គណៈកម្មាធិការអាស៊ានដើម្បីលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) ក្របខ័ណ្ឌតាមដានវាយតម្លៃ វាយការណ៍ និងសិក្សាដកពិសោធន៍នៃផែនការអាស៊ានបូហូល ២.០ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០២៣ របស់ គ.ជ.ប.ជ.។

សិក្ខាសាលាពិគ្រោះយោបល់លើកទីមួយជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានធ្វើឡើង នៅថ្ងៃទី ៥ ដល់ ៧ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ជាមួយសមាជិកតំណាង គ.ជ.ប.ជ.។ ធាតុចូលពីអ្នកចូលរួមលើសេចក្ដីព្រាងក្របខ័ណ្ឌនេះ ត្រូវបានបូកសរុប ដែលព័ត៌មានដល់ការកែសម្រួលឯកសារព្រាងបឋម។ ឯកសារព្រាងនេះ ត្រូវបានពិនិត្យឡើងវិញ និងកែសម្រួលជាមួយក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័ននៃ គ.ជ.ប.ជ. និងជាមួយលេខាធិការដ្ឋាន គ.ជ.ប.ជ. ក្នុងត្រីមាសទី ២ ឆ្នាំ ២០២៥។ ឯកសារព្រាងនេះ ត្រូវបានកែសម្រួលជាកំណែចុងក្រោយ មុនពេលប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាព **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជាប្រធាន គ.ជ.ប.ជ. នៅចុងត្រីមាសទី ២ ឆ្នាំ ២០២៥។ ការបណ្ដុះបណ្ដាលស្ដីពីការអនុវត្តក្របខ័ណ្ឌ MEL សម្រាប់មន្ត្រីទទួលបន្ទុកការងារប្រមូលទិន្នន័យ និងរាយការណ៍សម្រាប់ MEL ដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ក្រុមការងារអន្តរក្រសួង និងថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំបន្ទាប់ពីការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃឯកសារក្របខ័ណ្ឌ MEL នេះ។ ខាងក្រោមនេះគឺជាជំហាន និងក្របខ័ណ្ឌពេលវេលាក្នុងការរៀបចំ និងការអនុវត្តក្របខ័ណ្ឌ MEL៖

- ថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០២៤ - សេចក្ដីព្រាងបឋមសម្រាប់ពិភាក្សាក្នុងសិក្ខាសាលា ខែវិច្ឆិកា ឆ្នាំ ២០២៤ - សិក្ខាសាលាអន្តរក្រសួង-ស្ថាប័ន ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. សហការជាមួយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)។
- ថ្ងៃទី ៥-៧ ខែវិច្ឆិកា ឆ្នាំ ២០២៤ – បានប្រមូលធាតុចូលក្នុងអំឡុងពេលសិក្ខាសាលា ដែលផ្ដល់ដោយ គ.ជ.ប.ជ. និងអ្នកចូលរួមសិក្ខាសាលា – សេចក្ដីព្រាងបឋមត្រូវបានកែសម្រួលដោយកម្មវិធី ASEAN-ACT ដោយផ្អែកលើធាតុចូលក្នុងអំឡុងពេលសិក្ខាសាលា ដែលត្រូវបានបញ្ចប់នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០២៤។
- ថ្ងៃទី ១២ ឧសភា ឆ្នាំ ២០២៥ – កិច្ចពិភាក្សារវាងតំណាងអនុប្រធាននិងសមាជិក គ.ជ.ប.ជ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ដើម្បីផ្ដល់ព័ត៌មានបន្ថែម និងកំណត់ជំហានបន្ទាប់ ដែលដឹកនាំដោយ

**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ – ជាតុចូល និងមតិយោបល់ ត្រូវបានកត់ត្រា និងទទួលបានដោយកម្មវិធី ASEAN-ACT ក្នុងកិច្ចប្រជុំបច្ចេកទេសនេះ

- ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២៥ - ឯកសារព្រាងត្រូវបានពិនិត្យបន្ថែមដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងបានផ្តល់ជាតុចូលបន្ថែមដល់កម្មវិធី ASEAN-ACT សម្រាប់កែសម្រួលសេចក្តីព្រាងក្របខ័ណ្ឌ MEL នេះ។
- សប្តាហ៍ចុងក្រោយនៃខែឧសភា ឆ្នាំ ២០២៥ – អគ្គលេខាធិការដ្ឋានបានបញ្ជូនកំណែកែសម្រួលជូនកម្មវិធី ASEAN-ACT ដើម្បីសម្អាត និងបកប្រែ។
- សប្តាហ៍ទីបីនៃខែមិថុនា ឆ្នាំ ២០២៥ – កម្មវិធី ASEAN-ACT ប្រគល់ឯកសារកែសម្រួលចុងក្រោយជូន **លោកជំទាវ ជូ ប៊ុនអេង** និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ដើម្បីពិនិត្យ និងអនុម័តមុនពេលបោះពុម្ព។
- សប្តាហ៍ទីមួយនៃខែកក្កដាឆ្នាំ ២០២៥ – គ.ជ.ប.ជ. ស្នើសុំការយល់ព្រមជាផ្លូវការលើក្របខ័ណ្ឌ MEL និងស្នើសុំការឯកភាពលើការផ្សព្វផ្សាយជាផ្លូវការពី **ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី ប្រធាន គ.ជ.ប.ជ ។
- សប្តាហ៍ទីបីនៃខែកក្កដា ឆ្នាំ ២០២៥ – គ.ជ.ប.ជ. រៀបចំចាត់ចែងសម្រាប់ការផ្សព្វផ្សាយ – អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. សហការជាមួយកម្មវិធី ASEAN-ACT និងអង្គការដៃគូពាក់ព័ន្ធ។
- សប្តាហ៍ទី ១ ខែសីហា ឆ្នាំ ២០២៥ – ការផ្សព្វផ្សាយ និងការដាក់ឱ្យដំណើរការជាផ្លូវការនៃក្របខ័ណ្ឌ MEL នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០២៤-២០២៨។
- ខែសីហា ឆ្នាំ ២០២៥ – គ.ជ.ប.ជ. និង កម្មវិធី ASEAN-ACT សហការរៀបចំវិធីសាស្ត្រនិងឧបករណ៍តាមដាន និងរាយការណ៍ សម្រាប់ការបណ្តុះបណ្តាល និងការសាកល្បងជាមួយមន្ត្រីទទួលបន្ទុកការងារ MEL នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ – សំណើសុំការតែងតាំងមន្ត្រីទទួលបន្ទុកការងារ MEL ដើម្បីទទួលបន្ទុកការប្រមូលទិន្នន័យ និងរាយការណ៍ស្របតាមក្របខ័ណ្ឌ MEL ដែលបានអនុម័ត ត្រូវបានធ្វើចេញពីលេខាធិការដ្ឋាន គ.ជ.ប.ជ. ក្រុមការងារអន្តរក្រសួង និងថ្នាក់ក្រោមជាតិ។
- ខែកញ្ញា ឆ្នាំ ២០២៥ - ការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការងារ MEL និងការចាប់ផ្តើមសកម្មភាព MEL។

# ២ ទ្រឹស្តីនៃការផ្លាស់ប្តូរ អន្តរក្រសួង-ស្ថាប័ន

រចនាសម្ព័ន្ធនៃក្របខ័ណ្ឌ MEL នេះប្រើទ្រឹស្តីនៃការផ្លាស់ប្តូរ ឬវិធីតក្កវិទ្យាមួយដើម្បីពណ៌នាអំពីសកម្មភាព ផលសម្រេច លទ្ធផលរយៈពេលខ្លី លទ្ធផលរយៈពេលមធ្យម និងលទ្ធផលរយៈពេលវែង ដែលបានដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រជាតិ និងក្របខ័ណ្ឌតាមដាន និងវាយតម្លៃរបស់ ACWC ។ ផ្នែកនេះបង្ហាញការពណ៌នាអំពីទ្រឹស្តីនៃការផ្លាស់ប្តូរ - នៅក្នុងរូបទីមួយ ដែលតំណាងឱ្យលទ្ធផលដែលបានគ្រោងទុក និងលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រទាំង ៤ ក្នុងរយៈពេលប្រាំឆ្នាំនៃផែនការយុទ្ធសាស្ត្រជាតិ។ រូបភាពទី ២ តំណាងឱ្យយុទ្ធសាស្ត្រដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិពោលគឺ ឪយ៉ាក្រោមផែនការយុទ្ធសាស្ត្រ។

មានលទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ (EOSO) ចំនួន ៤ ដែលយើងរំពឹងថានឹងសម្រេចបាននៅចុងបញ្ចប់ឆ្នាំ ២០២៨ ដែលត្រូវបានសម្របតាមយុទ្ធសាស្ត្រទាំង ៤ នៃផែនការយុទ្ធសាស្ត្រជាតិ ប្រសិនបើការសន្មតរបស់យើងគឺត្រឹមត្រូវ។

- EOSO ១ ការបង្ការទប់ស្កាត់៖ ក្រុមគោលដៅ ជាពិសេសក្រុមងាយរងគ្រោះ មានភាពងាយរងគ្រោះថយចុះចំពោះអំពើជួញដូរមនុស្សគ្រប់ទម្រង់។
- EOSO ២ ការអនុវត្តច្បាប់៖ ប្រព័ន្ធយុត្តិធម៌ មានចម្លើយតបប្រកបដោយគុណភាព និងប្រសិទ្ធភាពចំពោះអំពើជួញដូរមនុស្សគ្រប់ទម្រង់។
- EOSO ៣ កិច្ចការពារ និងការផ្តល់សេវាជូនជនរងគ្រោះ៖ ជនរងគ្រោះទទួលបានសេវាគាំទ្រដែលយកចិត្តទុកដាក់ដល់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) និងដែលមានលក្ខណៈសមស្រប។

### តើអ្វីជាទ្រឹស្តីនៃការផ្លាស់ប្តូរ?

ទ្រឹស្តីនៃការផ្លាស់ប្តូរគឺជាឧបករណ៍ត្រិះរិះដែលជួយឱ្យយើងយល់ និងបង្ហាញលទ្ធផលចុងក្រោយដែលយើងអាចរំពឹងទុកពីសកម្មភាពដែលបានអនុវត្តក្រោមផែនការយុទ្ធសាស្ត្រជាតិ។

ទ្រឹស្តីនេះបង្ហាញពីទំនាក់ទំនង «ហេតុ និងផល» រវាងសកម្មភាព និងលទ្ធផល។

ទ្រឹស្តីនេះក៏ជួយយើងផងដែរក្នុងការតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិ ពីព្រោះយើងអាចផ្តោតសំខាន់លើការវាស់វែង និងការវាយតម្លៃកម្រិតនៃការសម្រេចបានលទ្ធផល។

- EOSO ៤ កិច្ចសហប្រតិបត្តិការ៖ ភាគីពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបង្កើនកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ ការបង្ក្រាបអំពើជួញដូរមនុស្ស និងគាំទ្រជនរងគ្រោះ។

EOSO ១ ការបង្ការទប់ស្កាត់៖ ក្រុមគោលដៅ ជាពិសេសក្រុមជនងាយរងគ្រោះ មានភាពងាយរងគ្រោះថយចុះចំពោះអំពើជួញដូរមនុស្សគ្រប់ទម្រង់។

ស្ថាប័នទទួលបន្ទុក កំពុងធ្វើការជាមួយស្ថាប័នចូលរួម ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃសហគមន៍គោលដៅ ជាពិសេស ក្រុមងាយរងគ្រោះចំពោះការជួញដូរមនុស្សគ្រប់ទម្រង់។ តាមរយៈកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងធ្វើការជាមួយវិស័យផ្សេងៗ ដូចជា សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានអប់រំ ប្រព័ន្ធផ្សព្វផ្សាយ និងដៃគូអន្តរជាតិ គោលបំណងគឺសំដៅធានាឱ្យបានថាប្រជាជនយល់ ចូលរួម និងផ្លាស់ប្តូរទស្សនៈ និងអាកប្បកិរិយាទាំងឡាយដែលនឹងធ្វើឱ្យពួកគេងាយរងគ្រោះចំពោះការបោកប្រាស់គ្រប់រូបភាពដោយជនល្មើសនៃអំពើជួញដូរមនុស្ស ។ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងរៀបចំកម្មវិធី សម្ភារ និងឧបករណ៍អប់រំប្រកបដោយគុណភាព និងទូលំទូលាយ ដើម្បីសម្រួលដល់យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងស្តីពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស។ យុទ្ធនាការជំរុញការយល់ដឹងទាំងនេះ សំដៅលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីធ្វើទេសន្តរប្រវេសន៍ស្របច្បាប់ ប្រកបដោយសុវត្ថិភាព និងសណ្តាប់ធ្នាប់ សម្រាប់ពលករវិល

ត្រឡប់ និងពលករដែលចង់ធ្វើចំណាកស្រុក។ កម្មវិធីយុទ្ធនាការជាក់លាក់ និងយន្តការទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ នឹងត្រូវបានបង្កើតនិងអនុវត្ត ដើម្បីទប់ស្កាត់ និងការពារកុមារពីគ្រប់ទម្រង់នៃការជួញដូរ ការរំលោភបំពាន និងការកេងប្រវ័ញ្ច រួមទាំងការកេងប្រវ័ញ្ចតាមអនឡាញ។

EOSO ២ ការអនុវត្តច្បាប់៖ ប្រព័ន្ធយុត្តិធម៌ មានចម្លើយតបប្រកបដោយគុណភាព និងប្រសិទ្ធភាពចំពោះអំពើជួញដូរមនុស្សគ្រប់ទម្រង់។

គោលបំណង គឺសំដៅបង្កើនការចូលរួម និងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋលើប្រព័ន្ធយុត្តិធម៌ តាមរយៈការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃចម្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ចំពោះការជួញដូរមនុស្សគ្រប់ទម្រង់។ លិខិតគុបករណ៍ច្បាប់ពាក់ព័ន្ធនានា ដូចជាច្បាប់ គោលនយោបាយ គោលការណ៍ នីតិវិធី និងសេចក្តីណែនាំ នឹងត្រូវបានពិនិត្យឡើងវិញ ធ្វើវិសោធនកម្ម និងអនុវត្ត ដើម្បីឆ្លើយតបទៅនឹងការជួញដូរមនុស្សនាពេលបច្ចុប្បន្ន និងនិន្នាការដែលកំពុងកើតមាន។ វិធីសាស្ត្រផ្តោតលើជនរងគ្រោះ នឹងត្រូវបានប្រើ រួមទាំងការកែលម្អប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះ និងការពង្រឹងការប្រមូលទិន្នន័យ និងការរាយការណ៍ករណីជួញដូរមនុស្ស។ មួយវិញទៀត ការពង្រីកការប្រើប្រាស់នីតិវិធីបែបកុមារមេត្រីក្នុងអំឡុងពេលកំណត់អត្តសញ្ញាណជនរងគ្រោះ ការសម្ភាស និងដំណើរការរបស់តុលាការ ក៏នឹងត្រូវមានការផ្តោតជាក់លាក់។

EOSO ៣ កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាជូនជនរងគ្រោះ៖ ជនរងគ្រោះទទួលបានសេវាគាំទ្រដែលយកចិត្តទុកដាក់ដល់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) និងដែលមានលក្ខណៈសមស្រប។

ដោយផ្តោតលើបរិយាបន្នសង្គម សមភាពយេនឌ័រ និងលើបរិបទផ្សេងៗនៃអាយុ ពិការភាព និងស្ថានភាពងាយរងគ្រោះផ្សេងទៀត - លទ្ធផលទីបីនេះ សំដៅកែលម្អគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារ និងការគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៅកម្ពុជា នឹងមានតួនាទីដែលបានកំណត់យ៉ាងច្បាស់លាស់លើការកំណត់អត្តសញ្ញាណជនរងគ្រោះ និងក្នុងការបង្កើត ពង្រឹង និងអនុវត្តប្រព័ន្ធបញ្ជូនថ្នាក់ជាតិសម្រាប់ករណីជួញដូរមនុស្ស សេវាគាំទ្រសមស្រប ដូចជាការគ្រប់គ្រងករណី និងការស្តារនីតិសម្បទាជនរងគ្រោះ ដោយផ្អែកលើឧត្តមប្រយោជន៍របស់ជនរងគ្រោះ។

EOSO ៤ កិច្ចសហប្រតិបត្តិការ៖ ភាគីពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបង្កើនកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ ការបង្ក្រាបបទល្មើស និងការគាំទ្រជនរងគ្រោះ។

កិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស គឺជា «ស្នូលនៃយុទ្ធសាស្ត្រទាំង៣» ដែលជានាដល់ការសម្រេចបាននូវលទ្ធផលចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រទាំង ៣ ដែលនឹងមិនត្រូវអនុវត្តដាច់ដោយឡែកពីគ្នានោះទេ ជាពិសេសកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយប្រទេសពាក់ព័ន្ធ ក្នុងការពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិនានា ដើម្បីឆ្លើយតបទៅនឹងនិន្នាការថ្មីៗនៃអំពើជួញដូរមនុស្ស និងដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះ និងអ្នកដែលធ្លាប់ជាជនរងគ្រោះ។

## រូបភាពទី ១៖ ទ្រឹស្តីនៃការផ្លាស់ប្តូរអន្តរក្រសួង-ស្ថាប័ននៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨)

| យុទ្ធសាស្ត្រ | យុទ្ធសាស្ត្រទី ១. លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ | យុទ្ធសាស្ត្រទី ២. បង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ | យុទ្ធសាស្ត្រទី ៣. បង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ | យុទ្ធសាស្ត្រទី ៤. ពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា |
|---|---|---|---|---|
| | **ការបង្ការទប់ស្កាត់** | **ការអនុវត្តច្បាប់** | **កិច្ចការពារជនរងគ្រោះ** | **កិច្ចសហប្រតិបត្តិការ** |
| **លទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ** | EOSO ១: ក្រុមគោលដៅ ជាពិសេសក្រុមងាយរងគ្រោះ មានភាពងាយរងគ្រោះថយចុះចំពោះអំពើជួញដូរមនុស្សគ្រប់ទម្រង់ | EOSO ២: បង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ | EOSO ៣: បង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ | EOSO ៤: ការពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា |
| **លទ្ធផលរយៈពេលមធ្យម** | ១.ក ក្រុមងាយរងគ្រោះ និងអ្នកពាក់ព័ន្ធដែលជាក្រុមអាទិភាពបានទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងមានសង្គតិភាព<br>១.ខ សហគមន៍ និងក្រុមគោលដៅមានការយល់ដឹងកាន់តែច្រើនស្តីពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស<br>១.គ តំបន់គោលដៅបានអភិវឌ្ឍកម្មវិធីអប់រំស្តីពីអំពើជួញដូរមនុស្សដែលគ្រប់ជ្រុងជ្រោយ និងមានគុណភាព<br>១.ឃ ពលករវិលត្រឡប់ និងពលករដែលប្រឈមនឹងការធ្វើទេសន្តរប្រវេសន៍ដឹងអំពីនីតិវិធីធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងសណ្តាប់ធ្នាប់<br>១.ង បានបង្កើត និងអនុវត្តកម្មវិធីយុទ្ធនាការ និងយន្តការបង្ការទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ | ២.ក លិខិតុបករណ៍ច្បាប់ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងការវិវត្តនៃឧក្រិដ្ឋកម្មជួញដូរមនុស្ស<br>២.ខ វិស័យយុត្តិធម៌បានពង្រឹងយន្តការប្រមូលទិន្នន័យ និងរាយការណ៍ស្តីពីករណីអំពើជួញដូរមនុស្ស<br>២.គ វិស័យយុត្តិធម៌បានធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងសំណុំរឿងជនរងគ្រោះ<br>២.ឃ មន្ត្រីអនុវត្តច្បាប់បានពង្រឹងសមត្ថភាពស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>២.ង ប្រព័ន្ធយុត្តិធម៌បានពង្រីកការប្រើនីតិវិធីស្តាប់ចម្លើយតាមបែបកុមារមេត្រីក្នុងអំឡុងពេលកំណត់អត្តសញ្ញាណ ការសម្ភាស និងដំណើរការតុលាការ | ៣.ក ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណប្រកបដោយប្រសិទ្ធភាព<br>៣.ខ ប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ត្រូវបានបង្កើត និងអនុវត្ត<br>៣.គ ស្ថាប័នមានតួនាទីដែលបានកំណត់យ៉ាងច្បាស់លាស់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងយន្តការបញ្ជូន<br>៣.ឃ ប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះ និងការប្រមូលទិន្នន័យពាក់ព័ន្ធ ត្រូវបានពង្រឹង<br>៣.ង ការស្តារនីតិសម្បទាជនរងគ្រោះផ្តោតលើចរិតលក្ខណៈ និងតម្រូវការរបស់បុគ្គល | ៤.ក វិស័យឯកជន សង្គមស៊ីវិល និងស្ថាប័នថ្នាក់ក្រោមជាតិកំពុងចូលរួម និងប្រឡូកយ៉ាងសកម្មក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស<br>៤.ខ ស្ថាប័នយុត្តិធម៌ និងអ្នកពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កំពុងសហការគ្នាបង្ការទប់ស្កាត់ បង្ក្រាប និងឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស<br>៤.គ អ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលបានពង្រឹងកិច្ចសហប្រតិបត្តិការ ដោយតម្កល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះនៅគ្រប់ដំណាក់កាល<br>៤.ឃ កិច្ចព្រមព្រៀង ផែនការ និងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងមានប្រសិទ្ធភាព<br>៤.ង ច្បាប់ និងគោលនយោបាយត្រូវបានកែសម្រួល និង/ឬបង្កើតដើម្បីដោះស្រាយនិន្នាការថ្មីនៃអំពើជួញដូរមនុស្ស |

## រូបភាពទី ២៖ ការផ្សារភ្ជាប់រវាងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០២៤-២០២៨




*យុទ្ធសាស្ត្រដោះស្រាយបញ្ហា នៅ បី ដំណាក់កាល ៖*

☆មុនពេលបទល្មើសកើតឡើង៖ បង្ការទប់ស្កាត់

☆ក្នុងពេលមានបទល្មើស៖ អនុវត្តច្បាប់ (បង្ក្រាប សង្គ្រោះ ផ្តន្ទាទោស)

☆ក្រោយពេលបង្ក្រាបបទល្មើស៖ ការពារ និងផ្តល់សេវាជូនជនរងគ្រោះ

# ៣ ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ MEL



ក្របខ័ណ្ឌ MEL នេះ ប្រើគំរូតក្កវិទ្យា ឬលំដាប់លំដោយព័ត៌មានដែលភ្ជាប់គ្នាពីធាតុចូលទៅសកម្មភាព ផលសម្រេច និងលទ្ធផលរយៈពេលមធ្យម។ ក្របខ័ណ្ឌនេះ គូសបញ្ជាក់ពីអ្វីដែលយើងនឹងតាមដាន និងវាយតម្លៃ ក្រោមផែនការយុទ្ធសាស្ត្រជាតិ ព្រមទាំងរបៀបដែលយើងនឹងប្រមូល និងវិភាគព័ត៌មាន ធ្វើការវិនិច្ឆ័យវាយតម្លៃ រាយការណ៍ និងកែលម្អយុទ្ធសាស្ត្ររបស់យើងក្នុងការឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស។

**សកម្មភាព** - ក្របខ័ណ្ឌ MEL ត្រូវបានសម្របតាមកម្រងសកម្មភាពដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រជាតិ ដែលត្រូវបានបង្ហាញយ៉ាងជាក់លាក់ ក្រោមយុទ្ធសាស្ត្រទាំង ៤។ សកម្មភាព គឺជាវិធានការដែលបានធ្វើឡើង ឬការងារដែលបានបំពេញ ដែលតាមរយៈនោះ ធាតុចូលផ្សេងៗ ដូចជាមូលនិធិ ជំនួយបច្ចេកទេស និងប្រភេទធនធានផ្សេងទៀត ត្រូវបានកៀរគរដើម្បីសម្រេចបាន ឬបំពេញផលសម្រេចជាក់លាក់។

**ផលសម្រេច** - គឺជាផលិតផល និងសេវាកម្មរូបវន្តដែលទទួលបានតាមរយៈការអនុវត្តផែនការសកម្មភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២៤-២០២៨។ ផលសម្រេច ឬលទ្ធផលដែលបានពិពណ៌នានៅក្នុងក្របខ័ណ្ឌ MEL រួមមានលទ្ធផលដែលឆ្លើយតបទៅនឹងសូចនាករអាទិភាពនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ដែលត្រូវបានកំណត់សម្រាប់ផែនការសកម្មភាពប្រចាំឆ្នាំ (សូមមើលឧបសម្ព័ន្ធ គ)។

**លទ្ធផលរយៈពេលមធ្យម** – គឺជាសមិទ្ធផលកម្រិតខ្ពស់ ដែលត្រូវបានកំណត់ជាអាទិភាពដើម្បីសម្រេចបានក្នុងរយៈពេលពី ២ ទៅ ៥ ឆ្នាំ។ លទ្ធផលរយៈពេលមធ្យមនៅក្នុងក្របខ័ណ្ឌ MEL ត្រូវបានចាត់ទុកថាជាតម្រូវការជាមុន ឬបុព្វលក្ខខណ្ឌដើម្បីគាំទ្រ និងជំរុញការសម្រេចបាននូវលទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ ឬលទ្ធផលរយៈពេលវែងនៅពេលបញ្ចប់ផែនការយុទ្ធសាស្ត្រជាតិនៅឆ្នាំ ២០២៨។ ការប្រចាប់បញ្ចូលគ្នានៃផលសម្រេច នឹងគាំទ្រដល់ការសម្រេចបាននូវលទ្ធផលរយៈពេលមធ្យមមួយ ឬច្រើន។

**លទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ (EOSO)** - ត្រូវបានសម្របដោយផ្ទាល់ទៅនឹងយុទ្ធសាស្ត្រទាំង ៤ ។ ទាំងនេះគឺជាលទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ ឬលទ្ធផលរយៈពេលវែងដែលត្រូវបានដកស្រង់ចេញពីផែនការយុទ្ធសាស្ត្រជាតិ។ EOSOs គឺជាលទ្ធផលចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រទាំង ៤ នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២៤-២០២៨។ ប្រសិនបើការសន្មតគឺត្រឹមត្រូវ EOSOs ត្រូវតែសម្រេចបានដូចការរំពឹងទុក នៅឆ្នាំ ២០២៨។

## ៣.១ គោលបំណង និងវិសាលភាព

ក្របខ័ណ្ឌ MEL នេះមានគោលបំណងជាក់លាក់ ដូចខាងក្រោម៖

- ពង្រឹងការទទួលខុសត្រូវរបស់ គ.ជ.ប.ជ. នៅគ្រប់កម្រិតនៃរចនាសម្ព័ន្ធ ដើម្បីប្រមូល និងចងក្រងទិន្នន័យនិងរបាយការណ៍ប្រកបដោយគុណភាព និងដែលអាចវាស់វែងបាន។
- ផ្តល់មូលដ្ឋានសម្រាប់ណែនាំការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ដើម្បីធានាឱ្យបាននូវសង្គតិភាព និងគុណភាពសម្រាប់ក្រសួង ស្ថាប័នជាសមាជិក និងគណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរ (គ.រ.ប.ជ/គ.ខ.ប.ជ.) ដោយផ្អែកលើភស្តុតាង និងព័ត៌មានដែលប្រមូលបានតាមរយៈក្របខ័ណ្ឌ MEL។
- ចងក្រង និងចែករំលែកព័ត៌មាន មេរៀន និងបទពិសោធន៍ដែលទទួលបាន ដើម្បីលើកកម្ពស់ការអនុវត្តល្អ ដោយបែងចែកប្រភេទទិន្នន័យតាមបរិមាណ និងគុណភាព សម្រាប់ក្រសួងពាក់ព័ន្ធ និងស្ថាប័នជាតិ និងអន្តរជាតិ។
- កំណត់បរិមាណ និងគុណភាពនៃការអនុវត្តសកម្មភាពទាំងឡាយដែលបានកំណត់ក្រោមផែនការយុទ្ធសាស្ត្រជាតិ។
- រៀបចំព័ត៌មានដែលត្រូវបានបែងចែកគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។

ក្របខ័ណ្ឌ MEL នេះត្រូវបានរៀបចំឡើង ដើម្បីគ្របដណ្តប់លើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទាំងអស់ដែលបានអនុវត្តនៅកម្ពុជា ឬដោយក្រសួង-ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា និងដៃគូ ។ សកម្មភាពទាំងនោះ មានបំណងរួមចំណែកដល់ការសម្រេចបាននូវលទ្ធផលនៃផែនការយុទ្ធសាស្ត្រជាតិ ការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាក្រោមអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រីនិងកុមារ (ACTIP) អនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង (ជាពិសេស ការជួញដូរមនុស្ស) និងនីតិវិធីធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងសណ្តាប់ធ្នាប់។ បន្ទាត់គណនេយ្យភាព លាតសន្ធឹងដល់លទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ (EOSO) នៃការអនុវត្តយុទ្ធសាស្ត្រទាំង ៤ របស់ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២៤-២០២៨ នៅឆ្នាំ២០២៨។

ក្របខ័ណ្ឌ MEL នៃផែនការយុទ្ធសាស្ត្រជាតិ នឹងត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពទាំងឡាយក្នុងរចនាសម្ព័ន្ធ គ.ជ.ប.ជ. ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមានក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័នទាំង ៦ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានការសម្របសម្រួលពីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. នៅថ្នាក់ជាតិ និងក្រុមការងារនៃនាយកដ្ឋាន និងស្ថាប័នទាំង ៦ នៅថ្នាក់ក្រោមជាតិ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋានគណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.)។

## ៣.២ គោលការណ៍

ក្របខ័ណ្ឌ MEL នេះ មានសង្គតិភាពជាមួយនឹងគុណតម្លៃ និងគោលការណ៍ស្នូលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល
- គោលការណ៍គោរពសិទ្ធិមនុស្សជាមូលដ្ឋាន
- គោលការណ៍យកចិត្តទុកដាក់ដល់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI)
- ការចូលរួមដ៏សកម្មពីសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ
- កិច្ចសហប្រតិបត្តិការនិងភាពជាដៃគូពហុវិស័យ
- ការតាមដាននិងវាយតម្លៃជាប្រព័ន្ធ និងប្រកបដោយនិរន្តរភាព

បន្ថែមលើគោលការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងដើម្បីធានាឱ្យបានថាផែនការយុទ្ធសាស្ត្រជាតិមានការតាមដាន និងវាយតម្លៃជាប្រព័ន្ធ និងប្រកបដោយនិរន្តរភាព គោលការណ៍នៃក្របខ័ណ្ឌ MEL គឺមានដូចខាងក្រោម៖

- ការកសាងសមត្ថភាពមន្ត្រីជួរមុខ
- មានលក្ខណៈច្បាស់លាស់ ជាក់លាក់ គុណភាពល្អ អាចវាស់វែងបាន និងផ្តោតលើគោលដៅ
- ផ្អែកលើគោលការណ៍នៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បែងចែកជាដំណាក់កាល និងកំណត់អាទិភាពសកម្មភាព ដែលជាការឆ្លើយតប និងសម្របទៅតាមស្ថានភាពជាក់ស្តែង

- ធានាឱ្យបានថា គំហើញ និងភ័ស្តុតាងដែលជាលទ្ធផលចេញពីការតាមដាន ការវាយតម្លៃ និងការសិក្សាដកពិសោធន៍ (MEL) ត្រូវបានប្រើដើម្បីជាប្រយោជន៍សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

## ៣.៣ គោលដៅអ្នកប្រើប្រាស់នៃក្របខ័ណ្ឌ MEL

គោលដៅសម្រាប់អ្នកប្រើប្រាស់នៃក្របខ័ណ្ឌ MEL នេះ និងតម្រូវការព័ត៌មានរបស់ពួកគេ មានបង្ហាញក្នុងតារាងទី ១។ អាទិភាពចម្បង គឺសម្រាប់អ្នកដែលត្រូវការព័ត៌មានដើម្បីវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីកែលម្អ ឬពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ព័ត៌មានអាទិភាពទីពីរ គឺសម្រាប់អ្នកដែលត្រូវការព័ត៌មានដើម្បីរៀបចំផែនការសកម្មភាពរបស់ពួកគេយោងតាមស្ថានភាពពួកគេ។ ជាទូទៅ អ្នកប្រើប្រាស់ចម្បង ជាធម្មតារួមមានអ្នកដែលកំពុងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងអ្នកដែលកំពុងផ្តល់មូលនិធិដល់ការអនុវត្តសកម្មភាព។ អ្នកប្រើប្រាស់បន្ទាប់បន្សំ អាចអានរបាយការណ៍ដែលចេញផ្សាយជាសាធារណៈស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប៉ុន្តែ ក្របខ័ណ្ឌ MEL មិនត្រូវបានបង្កើតឡើងដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ទាំងនេះនោះទេ។

### តារាងទី ១៖ អ្នកប្រើប្រាស់ក្របខ័ណ្ឌ MEL ឬ អ្នកអាន

| អាទិភាពនៃការប្រើ | អ្នកប្រើ | តម្រូវការព័ត៌មាន |
|---|---|---|
| ចម្បង | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ.<br>ក្រសួង-ស្ថាប័ន និងអង្គភាពឯកទេសជាសមាជិក គ.ជ.ប.ជ.<br>គណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.)<br>ក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័ន | ▪ លទ្ធផល និងភ័ស្តុតាងនៃផលសម្រេចក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ<br>▪ វឌ្ឍនភាពធៀបនឹងផែនការសកម្មភាពប្រចាំឆ្នាំ<br>▪ វឌ្ឍនភាពធៀបនឹងការរំពឹងទុកលើសមិទ្ធកម្ម<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានទទួល<br>▪ ភ័ស្តុតាងនៃកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ<br>▪ ក្រុមការងារអន្តរក្រសួង-ស្ថាប័ន |
| បន្ទាប់បន្សំ | ដៃគូអភិវឌ្ឍន៍អន្តរជាតិ តំបន់ និងជាតិផ្សេងទៀតរួមទាំងអ្នកវាយតម្លៃ | ▪ ភ័ស្តុតាងនៃវឌ្ឍនភាព<br>▪ លទ្ធផលចុងបញ្ចប់ក្រោយនៃផលសម្រេច និងលទ្ធផល<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានទទួល |
| | ភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងវិស័យឯកជន និងអ្នកបំពេញការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ▪ ភ័ស្តុតាងនៃការចូលរួម<br>▪ លទ្ធផលនៃផលសម្រេច និងលទ្ធផល |
| | មន្ត្រីរដ្ឋាភិបាលផ្សេងទៀតក្រៅប្រព័ន្ធយុត្តិធម៌ | ▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានទទួល |
| | ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ | ▪ ការរួមចំណែករបស់ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានទទួល |
| | ប្រព័ន្ធផ្សព្វផ្សាយ គ្រឹះស្ថានសិក្សា អ្នកស្រាវជ្រាវ | ▪ លទ្ធផលនៃផលសម្រេចនិងលទ្ធផល<br>▪ ព័ត៌មានអំពីការអនុវត្តល្អ និងមេរៀនដែលបានទទួល |

## ៣.៤ ហានិភ័យ និងការសន្មត

ការអនុវត្តក្របខ័ណ្ឌ MEL ចាំបាច់ត្រូវគិតគូរពីហានិភ័យ និងការសន្មតដែលអាចកើតឡើងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ហានិភ័យនិងការសន្មតនឹងត្រូវបានតាមដាននិងពិនិត្យឡើងវិញ រៀងរាល់ឆ្នាំក្នុងអំឡុងពេលនៃកិច្ចដំណើរការឆ្លុះបញ្ចាំង និងរៀបចំផែនការប្រចាំឆ្នាំ អាស្រ័យដោយស្ថានភាពជាក់ស្តែង ក្នុងដំណាក់កាលនីមួយៗ ។

ខាងក្រោមនេះជាការសន្មតលទ្ធផលសំខាន់ៗពីទ្រឹស្តីនៃការផ្លាស់ប្តូរ។ យើងសន្មតថា៖

- ផែនការសកម្មភាពប្រចាំឆ្នាំត្រូវបានរៀបចំចេញពីផែនការយុទ្ធសាស្ត្រជាតិ ដោយផ្តល់ព័ត៌មានលម្អិតអំពីសកម្មភាពជាអាទិភាពដោយក្រសួង ស្ថាប័ន និងអង្គភាពឯកទេស/សមាជិក គ.ជ.ប.ជ.
- មានធនធាន និងថវិកាសម្រាប់អនុវត្តសកម្មភាពជាអាទិភាពនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំទាក់ទងនឹងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ
- ការបង្កើនការយល់ដឹងរបស់ប្រជាជនអំពីការជួញដូរមនុស្ស នឹងនាំឱ្យមានការកាត់បន្ថយភាពងាយរងគ្រោះចំពោះអំពើជួញដូរមនុស្ស
- កិច្ចសហប្រតិបត្តិការ និងឆន្ទៈចូលរួម ត្រូវបានពង្រឹង និងបន្តក្នុងចំណោមក្រសួង និងដៃគូប្រឆាំងការជួញដូរ ដើម្បីអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំពាក់ព័ន្ធ និងផែនការយុទ្ធសាស្ត្រជាតិ រួមទាំងឆន្ទៈរបស់ពួកគេក្នុងការចូលរួមក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ
- គុណភាពនៃប្រព័ន្ធយុត្តិធម៌ និង/ឬ ការគាំទ្រឬសេវាកម្មដែលផ្តល់ជូនជនរងគ្រោះដោយអំពើជួញដូរ ត្រូវបានលើកកម្ពស់។

# ៤ វិធីសាស្រ្តតាមដាន និងវាយតម្លៃ

## ៤.១ អភិក្រមនៃការតាមដាន

ផែនការយុទ្ធសាស្រ្តជាតិ បានទទួលស្គាល់សារៈសំខាន់នៃការមាន 'ការតាមដាន និងវាយតម្លៃជាប្រព័ន្ធ និងប្រកបដោយនិរន្តរភាព' មួយ ពោលគឺប្រព័ន្ធដ៏រឹងមាំមួយដើម្បីកំណត់បរិមាណនិងគុណភាពនៃការអនុវត្តសកម្មភាព។ អភិក្រម MEL នឹងមានលក្ខណៈចូលរួម ប្រើប្រាស់ប្រព័ន្ធប្រមូលទិន្នន័យមានស្រាប់ និង នឹងផ្អែកលើគោលការណ៍នៃក្របខ័ណ្ឌ MEL ដែលមានលក្ខណៈសម្របតាមគោលបំណង។ ក្នុងន័យនេះ អភិក្រមតាមដាននេះនឹងត្រូវបានអនុវត្តជាដំណាក់កាល ដោយចាប់ផ្តើមក្នុងទ្រង់ទ្រាយតូចក្នុងរយៈពេល ២ ឆ្នាំដំបូងនៃការអនុវត្ត ព្រមទាំងនឹងត្រូវបានពង្រីកជាបណ្តើរៗក្នុងដំណាក់កាលបន្ទាប់រហូតដល់ពេលបញ្ចប់។ ក្របខ័ណ្ឌ MEL នេះក៏តម្រូវផងដែរឱ្យមានការប្រមូលតែទិន្នន័យ ឬព័ត៌មានសំខាន់ៗ និងជាអាទិភាពតែប៉ុណ្ណោះ ដើម្បីគាំទ្រដល់ការរាយការណ៍អំពីវឌ្ឍនភាពនៃផែនការការងារប្រចាំឆ្នាំ និងការយល់ដឹងអំពីលទ្ធផលតាមដំណាក់កាលនៃការអនុវត្តផែនការយុទ្ធសាស្រ្ត។

យុទ្ធសាស្រ្តទាំង ៤ មានសូចនាករលទ្ធផលចំនួន ៨២ និងត្រូវបានចាត់ថ្នាក់ក្រោមចង្កោមសកម្មភាពសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្រ្តជាតិ (សូមមើលការដកស្រង់សេចក្តីសង្ខេបនៅក្នុងឧបសម្ព័ន្ធ ក) ។ ក្នុងការអនុវត្តអភិក្រមជាដំណាក់កាលចំពោះការតាមដាន ក្របខ័ណ្ឌ MEL នេះបង្ហាញនូវបញ្ជីអាទិភាពនៃសូចនាករលទ្ធផល (សូមមើលផ្នែករង ៤.២)។ សូចនាករលទ្ធផលនឹងសម្រេចបានពីការប្រៀបធៀបបញ្ចូលគ្នានៃផលសម្រេច ។ សូចនាករផលសម្រេចដែលបានស្នើឡើង (ឧបសម្ព័ន្ធ ខ) នឹងត្រូវបានប្រមូលចាប់ពីឆ្នាំ ២០២៥ រហូតដល់ចុងបញ្ចប់នៃផែនការយុទ្ធសាស្រ្តជាតិនៅឆ្នាំ២០២៨។ ទិន្នន័យនិងព័ត៌មានស្តីពីផលសម្រេចនិងលទ្ធផល នឹងត្រូវបានប្រមូលដោយប្រើឧបករណ៍ និងទម្រង់ផ្សេងៗដែលនឹងត្រូវបានរៀបចំជាឯកសារដោយឡែកមួយ ដែលនឹងត្រូវបានប្រើនៅក្នុងការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលមន្រ្តីទទួលបន្ទុកការងារ MEL នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៤.២ សំណួរវាយតម្លៃសំខាន់ៗ

សំណួរវាយតម្លៃសំខាន់ៗ (KEQs) ជាសំណួរគោលដែលជាត្រីវិស័យនៃក្របខ័ណ្ឌ MEL។ សំណួរទាំងនេះ ផ្តល់ការណែនាំសម្រាប់ការរៀបចំផែនការសកម្មភាព ការគ្រប់គ្រង និងការសិក្សាដកពិសោធន៍។[1] សំណួរវាយតម្លៃសំខាន់ៗ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងគោលបំណងចម្បងៗនៃក្របខ័ណ្ឌ MEL និងតម្រូវការព័ត៌មានរបស់អ្នកប្រើប្រាស់ចម្បងនៃក្របខ័ណ្ឌនេះ។ បន្ទាប់មក គឺការកំណត់សំណួរបន្ទាប់បន្សំ និងសូចនាករអាទិភាពពាក់ព័ន្ធ ដើម្បីបង្កើតមូលដ្ឋាននៃការប្រមូលទិន្នន័យអ្វីខ្លះដែលត្រូវតាមដាន និងប្រមូលភ័ស្តុតាង ដើម្បីឆ្លើយតបនឹងសំណួរវាយតម្លៃសំខាន់ៗ។ សំណួរទាំងនេះក៏នឹងគាំទ្រដល់ការរាយការណ៍អំពីវឌ្ឍនភាព និងដំណើរការសិក្សាដកពិសោធន៍ ដើម្បីប្រាប់អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២៤-២០២៨។

### តារាងទី ២៖ សំណួរវាយតម្លៃសំខាន់ៗ សំណួររង និងសូចនាករ

| សំណួរវាយតម្លៃសំខាន់ៗ (KEQ) | សំណួររង | សូចនាករអាទិភាព (ដកស្រង់ពីសូចនាករលទ្ធផល ឧបសម្ព័ន្ធ ក និងសូចនាករផលសម្រេច ឧបសម្ព័ន្ធ ខ) |
|---|---|---|
| KEQ1: តើយុទ្ធសាស្ត្ររបស់យើងក្រោមផែនការយុទ្ធសាស្ត្រជាតិមានប្រសិទ្ធភាពកម្រិតណាក្នុងការសម្រេចបានផលសម្រេច និងលទ្ធផលដែលចង់បាន?<br><br>**ប្រសិទ្ធភាព** | ១.១ តើមានសកម្មភាពអ្វីខ្លះដែលត្រូវបានអនុវត្ត នៅទីណា ដូចម្តេច និងដោយនរណា?<br>១.២ តើមានមនុស្សប៉ុន្មាននាក់ (បែងចែកជាប្រភេទសមស្រប) ដែលត្រូវបានគ្របដណ្តប់?<br>១.៣ តើយើងសម្រេចលទ្ធផលរំពឹងទុកបានកម្រិតណា? | ការប្រមូលទិន្នន័យនៃផលសម្រេចពីឆ្នាំ ២០២៥ ដល់ឆ្នាំ ២០២៨៖<br>▪ ចំនួនសកម្មភាពដែលបានបញ្ចប់ (បែងចែកតាមប្រភេទ ទីតាំង និងយុទ្ធសាស្ត្រ)<br>▪ ចំនួនអ្នកចូលរួម (បែងចែកតាមយេនឌ័រ អាយុ ពិការភាព និងស្ថានភាពផ្សេងទៀត វិស័យ ទីកន្លែង ប្រភេទភាគីពាក់ព័ន្ធ)<br>▪ ចំនួននៃកិច្ចសហប្រតិបត្តិការ កិច្ចព្រមព្រៀង អនុស្សរណៈដែលបានចុះហត្ថលេខា<br>▪ ចំនួនមន្ត្រីអនុវត្តច្បាប់ដែលត្រូវបានបណ្តុះបណ្តាល បែងចែកតាមយេនឌ័រ |

[1] អភិក្រមថ្មីៗបំផុតក្នុងការតាមដាន និងការវាយតម្លៃ និងការរៀបចំនៃក្របខ័ណ្ឌការតាមដាន និងការវាយតម្លៃ ត្រូវបានរៀបចំជុំវិញសំណុំសំណួរវាយតម្លៃសំខាន់ៗកម្រិតខ្ពស់។ សំណួរវាយតម្លៃសំខាន់ៗទាំងនេះ ត្រូវបានសម្របតាមលក្ខណៈវិនិច្ឆ័យជាក់លាក់នៃការតាមដាន និងការវាយតម្លៃ ឧទាហរណ៍ ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព ភាពជាដៃគូ ផលប៉ះពាល់ ការរួមចំណែក ភាពសមស្រប ភាពពាក់ព័ន្ធ។ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជ្រើសរើសតែលក្ខណៈវិនិច្ឆ័យសំខាន់ៗទាំងឡាយណាដែលនឹងមានប្រយោជន៍សម្រាប់ការតាមដាន និងការវាយតម្លៃ។

| | | |
|---|---|---|
| | | ▪ ចំនួន និងព័ត៌មានលម្អិតនៃច្បាប់ នីតិវិធី គោលនយោបាយ និងកិច្ចព្រមព្រៀងដែលបានពិនិត្យ បង្កើត កែសម្រួល ឬបញ្ចប់<br>ការប្រមូលទិន្នន័យនៃលទ្ធផលពីឆ្នាំ ២០២៦ ដល់ឆ្នាំ ២០២៨៖<br>▪ សមាសធាតុពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានពង្រឹងការយល់ដឹងអំពីគោលនយោបាយទាក់ទងនឹងអំពើជួញដូរមនុស្ស ល្បិចជនល្មើស និងផលប៉ះពាល់នៃហានិភ័យក្នុងការធ្វើទេសន្តរប្រវេសន៍ និងទម្រង់នៃការជួញដូរមនុស្ស (សូចនាករ #១៧)<br>▪ កម្មវិធីអប់រំដ៏ទូលំទូលាយ សម្រាប់ប្រជាជននៅគ្រប់តំបន់គោលដៅត្រូវបានបង្កើតឡើងប្រកបដោយគុណភាពខ្ពស់ និងត្រូវបានអនុវត្តជាប្រចាំ (សូចនាករ #២៣)<br>▪ នីតិវិធីសម្រាប់សំណងជនរងគ្រោះត្រូវបានបង្កើតឡើង និងអនុវត្ត (សូចនាករ #៤៣)<br>▪ ទិន្នន័យពាក់ព័ន្ធគ្រប់ទម្រង់នៃករណីជួញដូរមនុស្សត្រូវបានប្រមូលនៅគ្រប់ដំណាក់កាល ហើយចែករំលែក/រាយការណ៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធទាន់ពេលវេលាប្រកបដោយភាពត្រឹមត្រូវ និងសង្គតិភាព (សូចនាករ #៤៤)<br>▪ សេចក្តីណែនាំស្តីពីទម្រង់ និងនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សសម្រាប់ការផ្តល់សេវាសមស្រប ត្រូវបានកែសម្រួល/ធ្វើបច្ចុប្បន្នភាព ផ្សព្វផ្សាយ និងអនុវត្តប្រកបដោយប្រសិទ្ធភាព ស្របតាមក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស (សូចនាករ #៥០)<br>▪ ជនរងគ្រោះដោយអំពើជួញដូរមនុស្សបានទទួលសេវាសមរម្យ និងគុណភាព (សូចនាករ #៥៧) |
| KEQ២: តើយើងបានរួមចំណែកប្រកបដោយប្រសិទ្ធភាពកម្រិតណា និងដោយរបៀបណា ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការផ្តន្ទាទោសអ្នកជួញដូរមនុស្ស និងកិច្ច | ២.១ តើមានគោលនយោបាយ ប្រព័ន្ធ ឬ សមត្ថភាពអ្វីខ្លះដែលត្រូវបានបង្កើតឡើង និងងអនុវត្ត?<br>២.២ តើមានការសម្រេចបានការផ្លាស់ប្តូរអ្វីខ្លះពាក់ព័ន្ធនឹងចំណេះដឹង ឥរិយាបថ ការអនុវត្ត និងគោល | ការប្រមូលទិន្នន័យនៃលទ្ធផលពីឆ្នាំ ២០២៦ ដល់ឆ្នាំ ២០២៨៖<br>▪ សេវាកម្មដែលគាំទ្រការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាពមានភាពប្រសើរឡើង (សូចនាករ #២)<br>▪ នីតិវិធីសម្រាប់ផ្តល់សំណងជូនជនរងគ្រោះត្រូវបានបង្កើតឡើង និងអនុវត្ត (សូចនាករ #៤៣) |

| | | |
|---|---|---|
| ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស?<br><br>**ការរួមចំណែក** | នយោបាយ ដោយសារការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ?<br>២.៣ តើជនរងគ្រោះ និងជនដែលធ្លាប់រងគ្រោះដោយអំពើជួញដូរមនុស្សកំពុងទទួលបានអត្ថប្រយោជន៍ពីសេវាគាំទ្រសមស្រប ក្នុងកម្រិតណា?<br>២.៤ តើសកម្មភាពរបស់យើងបានធ្វើឱ្យមានភាពខុសប្លែកអ្វីខ្លះចំពោះការបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ និងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស? | ▪ សេវាកម្មត្រូវបានផ្តល់ជូនជនរងគ្រោះដោយមានការគិតគូរយ៉ាងយកចិត្តទុកដាក់លើគោលការណ៍ទាក់ទងនឹងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងឧត្តមប្រយោជន៍របស់ជនរងគ្រោះ (សូចនាករ #៥២)<br>▪ ប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះត្រូវបានបង្កើត និងអនុវត្តប្រកបដោយប្រសិទ្ធភាពដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីពាក់ព័ន្ធ (សូចនាករ #៥៥) |
| KEQ៣: តើកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូកំពុងកែលម្អចម្លើយតបរបស់យើងចំពោះការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការអនុវត្តច្បាប់ និងកិច្ចការពារជនរងគ្រោះបានកម្រិតណា?<br><br>**ភាពជាដៃគូ** | ៣.១ តើភាគីពាក់ព័ន្ធមិនមែនរដ្ឋាភិបាល រួមទាំងក្រុមជួបការលំបាក និងជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ កំពុងមានឥទ្ធិពលលើច្បាប់ គោលនយោបាយ និងការអនុវត្តដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានកម្រិតណា?<br>៣.២ តើស្ថាប័នប្រឆាំងការជួញដូរ និងភាគីពាក់ព័ន្ធបានសហការ និងចែករំលែកចំណេះដឹងដល់កម្រិតណា ដើម្បីលើកកម្ពស់កិច្ចខិតខំ ឬសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ពួកគេ ក្នុងកម្រិតណា និងដោយរបៀបណា?<br>៣.៣ តើស្ថាប័នពាក់ព័ន្ធទទួលបានព័ត៌មានពីនិន្នាការថ្មី និងភ័ស្តុតាងនៃការអនុវត្តល្អក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិរបស់ពួកគេ ក្នុងកម្រិតណា? | ការប្រមូលទិន្នន័យអំពីលទ្ធផលពីឆ្នាំ ២០២៦ ដល់ឆ្នាំ ២០២៨៖<br>▪ វិស័យឯកជនចូលរួមយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់ការជួញដូរមនុស្ស (សូចនាករ#១៦)<br>▪ ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីអនុវត្តច្បាប់ និងព្រះរាជអាជ្ញា ស្ថាប័នតុលាការ និងអ្នកផ្តល់សេវាសង្គមត្រូវបានអនុវត្តយ៉ាងរលូន ដើម្បីលើកកម្ពស់សិទ្ធិ សេចក្តីថ្លៃថ្នូរ និងឧត្តមប្រយោជន៍របស់ជនរងគ្រោះ (សូចនាករ #៤៥)<br>▪ កិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលត្រូវបានពង្រឹង (សូចនាករ #៦១)<br>▪ ចំនួនអ្នកចូលរួមព្រឹត្តិការណ៍ ដែលមកពីវិស័យឯកជន សង្គមស៊ីវិល និងអ្នកតំណាងជនរងគ្រោះ រួមទាំងក្រុមជួបការលំបាក (សូចនាករផលសម្រេច) |

## ៤.៣ វិធីសាស្ត្រតាមដាន

ការប្រមូលទិន្នន័យបែបបរិមាណនិងបែបគុណភាព ត្រូវតែធ្វើឡើងជាប្រចាំដើម្បីតាមដាន និងយល់ដឹងពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពប្រចាំឆ្នាំពាក់ព័ន្ធក្នុងការសម្រេចបានផលសម្រេច និងលទ្ធផលទៅតាមដំណាក់កាលដែលបានកំណត់ និងផ្អែកលើវិធីសាស្ត្រផ្សេងៗ និងដើម្បីដកស្រង់មេរៀនដែលបានទទួល។ តារាងទី ៣ បង្ហាញនូវវិធីសាស្ត្រ និងឧបករណ៍ប្រមូលទិន្នន័យ ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌ MEL។ ព័ត៌មានលម្អិតអំពីវិធីសាស្ត្រនិង

ទម្រង់នៃឧបករណ៍និងគំរូប្រមូលទិន្នន័យទាំងអស់ នឹងត្រូវបានដាក់បញ្ចូលក្នុងឯកសារកញ្ចប់ឧបករណ៍ដោយឡែកមួយ ដែលនឹងត្រូវប្រើផងដែរសម្រាប់ការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការងារ MEL។

## តារាងទី ៣៖ គំរូវិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ

| វិធីសាស្ត្រឬឧបករណ៍ប្រមូលទិន្នន័យ | ការពិពណ៌នា | ភាពញឹកញាប់ |
|---|---|---|
| តាមដានសកម្មភាពទាំងឡាយដែលបានរាយការណ៍ ដោយផ្អែកលើផែនការសកម្មភាព | ការឃ្លាំមើល និងការតាមដានរបាយការណ៍ស្តីពីសកម្មភាពទាំងឡាយដែលបានអនុវត្ត ដូចដែលមានចែងក្នុងផែនការសកម្មភាពប្រចាំឆ្នាំស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងសកម្មភាពសំខាន់ៗដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិ ដើម្បីប្រមូលព័ត៌មាន ឬព័ត៌មានលម្អិតអំពីសកម្មភាពដែលបានអនុវត្ត/បញ្ចប់ និងកំពុងបន្ត។ ការប្រមូលទិន្នន័យក៏នឹងរួមបញ្ចូលផងដែរនូវទិន្នន័យបែងចែកអំពីអ្នកចូលរួម ដើម្បីជួយឱ្យដឹងថាតើយើងកំពុងឈានដល់បុគ្គល ឬក្រុមគោលដៅដែលបានគ្រោងទុកឬទេ។ ទិន្នន័យដែលបានប្រមូលទាំងនេះ ត្រូវបានរក្សាទុក នៅតាមក្រសួងនិងស្ថាប័នអនុវត្តរៀងៗខ្លួន។ | ប្រមូលជាប្រចាំ (ប្រចាំខែ) |
| ទម្រង់ផ្តល់មតិកែលម្អ | ការប្រមូលមតិកែលម្អរបស់អ្នកចូលរួមសកម្មភាព ដែលអនុវត្តដោយក្រសួងស្ថាប័នពាក់ព័ន្ធ។ ទិន្នន័យដែលបានប្រមូលទាំងនេះ ត្រូវបានទុកដាក់ និងរក្សាទុកនៅតាមស្ថាប័នអនុវត្តរៀងៗខ្លួន។ | ប្រមូលជាប្រចាំ (ប្រចាំខែ) |
| រឿងនៃការផ្លាស់ប្តូរ ឬករណីសិក្សា | ឧបករណ៍ដែលយើងនឹងប្រើដើម្បីប្រមូលលទ្ធផល ដោយផ្អែកលើសូចនាករ ដោយផ្តោតលើការផ្លាស់ប្តូរវិជ្ជមានសំខាន់ៗ ឧទាហរណ៍នៃការផ្លាស់ប្តូរ ឬករណីសិក្សា ទិន្នន័យ ឬព័ត៌មានសម្រាប់រឿងរ៉ាវពីប្រភពផ្សេងៗ រួមទាំងការសម្ភាស ឬការពិភាក្សាជាក្រុម។ | ប្រចាំឆមាស និងប្រចាំឆ្នាំ |
| ការស្ទង់មតិគោលដៅ | ការស្ទង់មតិអាចត្រូវបានធ្វើឡើងចំពោះក្រុមគោលដៅបុគ្គល ឬក្រុមគោលដៅដៃគូអនុវត្ត ឬដើម្បីគាំទ្រដល់ការប្រមូលលទ្ធផល ដោយផ្អែកលើសូចនាករ ឬវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានលទ្ធផលរយៈពេលមធ្យម។ វិធីសាស្ត្រនេះ ក៏រួមមានផងដែរការស្ទង់មតិនៃអ្នកចូលរួមវគ្គបណ្តុះបណ្តាលដែលបានធ្វើឡើងពី ៣ ទៅ ៦ ខែបន្ទាប់ពីការបណ្តុះបណ្តាលដើម្បីតាមដានលើវិសាលភាពដែលចំណេះដឹង ឬជំនាញថ្មីត្រូវបានប្រើប្រាស់ក្នុងការអនុវត្ត និងដើម្បីកំណត់ការប្រែប្រួលណាមួយរវាងលទ្ធផលសម្រាប់បុរស និងស្ត្រី និងជនដែលមានពិការភាព។ ករណីសិក្សាមួយ | ប្រចាំឆ្នាំ |

| | | |
|---|---|---|
| | អាចត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ ដើម្បីបង្ហាញលទ្ធផលពីការស្ទង់មតិគោលដៅ។ | |
| សៀវភៅមគ្គុទ្ទេសក៍តាមដាន និងប្រព័ន្ធវាយតម្លៃកម្រិតអភិវឌ្ឍន៍ស្ថាប័ន (Building Block Maturity Framework) នៃ ACWC | សៀវភៅណែនាំអាស៊ានសម្រាប់តាមដានអភិក្រមដែលយកចិត្តទុកដាក់ដល់យេនឌ័រ និងជនរងគ្រោះ ចំពោះការជួញដូរមនុស្ស ជាមួយនឹងលទ្ធផលភ្លាមៗដែលអាចភ្ជាប់ទៅ ឬស្រដៀងគ្នាទៅនឹងសូចនាករលទ្ធផលមួយចំនួនរបស់ផែនការយុទ្ធសាស្ត្រជាតិ។ ឯកសារអេឡិកត្រូនិកនៃសៀវភៅមគ្គុទ្ទេសក៍ និងឧបករណ៍តាមដានការអភិវឌ្ឍស្ថាប័នអាចរកបានតាមការស្នើសុំ។ | ប្រចាំឆ្នាំ |
| ប្រភពព័ត៌មានផ្សេងទៀត | ទិន្នន័យមានស្រាប់ស្តីពីការជួញដូរមនុស្សនៅតាមក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ នៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំរបស់ខ្លួន គ.ជ.ប.ជ. បង្ហាញការនិទានរឿងព័ត៌មាន និងទិន្នន័យស្តីពីកិច្ចខិតខំប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ បញ្ជីសង្ខេបទិន្នន័យមានស្រាប់ គឺមាននៅក្នុងឧបសម្ព័ន្ធ ឃ.៥។ | ប្រចាំឆ្នាំ |

## ការប្រមូលទិន្នន័យបែងចែកតាមប្រភេទ

តាមដែលអាចធ្វើទៅបាន ព័ត៌មាននឹងត្រូវបានបែងចែកតាមប្រភេទដូចខាងក្រោម៖

- យេនឌ័រ - ប្រុស ស្រី ភេទ និងស្ថានភាពផ្សេងទៀត
- ក្រុមអាយុ
- ទីតាំងភូមិសាស្ត្រនៃសកម្មភាព - នៅកម្រិតក្រុង ឬខេត្ត
- ពិចារណាប្រមូលព័ត៌មានអំពីស្ថានភាពនៃពិការភាព - តាមដែលអាចអនុវត្តបាន
- ប្រភេទសកម្មភាព - យុទ្ធនាការបង្កើនការយល់ដឹង ការបណ្តុះបណ្តាល ការរៀបចំគោលនយោបាយ ការស្រាវជ្រាវ
- ប្រភេទស្ថាប័ន/អង្គការអនុវត្ត – រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល ឯកជន អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ តំបន់គ្របដណ្តប់ ប្រភេទសកម្មភាព។

## ៤.៤ ការវាយតម្លៃ

ការវាយតម្លៃ ឬការពិនិត្យឡើងវិញដោយឯករាជ្យលើផែនការយុទ្ធសាស្ត្រជាតិ នឹងត្រូវបានធ្វើឡើងដោយ គ.ជ.ប.ជ. មុនដំណាច់ឆ្នាំ ២០២៨។ គោលបំណងគឺសំដៅធ្វើការប៉ាន់ប្រមាណវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅសម្រេចបានលទ្ធផលរយៈពេលមធ្យម និងការរួមចំណែកដល់លទ្ធផលនៅចុងបញ្ចប់យុទ្ធសាស្ត្រ។

មុនការវាយតម្លៃនេះ លក្ខខណ្ឌយោងការងារនឹងត្រូវបានរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារបច្ចេកទេសទាំង៦ បន្ទាប់មកត្រូវបានអនុម័តដោយ គ.ជ.ប.ជ.។ ការវាយតម្លៃ នឹងត្រូវបានធ្វើដោយប្រើព័ត៌មានដែលទទួលបានពីក្របខ័ណ្ឌ MEL ហើយទិន្នន័យតាមដាន និងរបាយការណ៍វឌ្ឍនភាពពាក់ព័ន្ធ នឹងផ្តល់ព័ត៌មានដល់ការវាយតម្លៃស្របតាមលក្ខខណ្ឌយោងការងារនៃការវាយតម្លៃ។

# ៥ ការរាយការណ៍ និងការសិក្សាដកពិសោធន៍

## ៥.១ ការវិភាគព័ត៌មាន

ព័ត៌មាន និងទិន្នន័យស្តីពីអំពើជួញដូរមនុស្ស រួមទាំងសកម្មភាពពាក់ព័ន្ធដើម្បីទប់ស្កាត់ ស៊ើបអង្កេត ផ្តន្ទាទោស និងវិនិច្ឆ័យករណីជួញដូរមនុស្ស និងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានប្រមូលដោយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល។ ការប្រមូលព័ត៌មានទាំងនេះ នឹងរួមមានការប្រមូលនិងការវិភាគ ដើម្បីផ្តល់ព័ត៌មានដល់ការរៀបចំផែនការការអនុវត្តសកម្មភាព និងការរាយការណ៍អំពីវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវលទ្ធផលដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ និងវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ។ ការប្រមូល ការវិភាគ និងការទុកដាក់ទិន្នន័យ នឹងជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ឬអង្គភាពប្រមូលទិន្នន័យរៀងៗខ្លួន មានន័យថា អ្នកដែលប្រមូលព័ត៌មានឬទិន្នន័យនឹងទទួលខុសត្រូវលើការទុកដាក់ ការថែរក្សា ការប្រមូល និងការវិភាគទិន្នន័យ។ ការមានទិន្នន័យប្រកបដោយសង្គតិភាព និងគុណភាព នឹងត្រូវដាក់បញ្ចូលជាសកម្មភាព MEL ជាអាទិភាព ( សូមមើលផ្នែកទី៦ )។

## ៥.២ ការរាយការណ៍

ផ្នែកនេះផ្តល់នូវកម្រិតផ្សេងៗនៃការរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ វឌ្ឍនភាពនៃការអនុវត្តផែនការការងារប្រចាំឆ្នាំ ឬផែនការសកម្មភាព និងវឌ្ឍនភាពឆ្ពោះទៅសម្រេចបានលទ្ធផលរយៈពេលមធ្យម។ យន្តការរាយការណ៍ដែលមានស្រាប់នៅ គ.ជ.ប.ជ. នឹងនៅបន្តអនុវត្ត ហើយប្រសិនបើចាំបាច់ នឹងត្រូវបានពង្រឹងបន្ថែមដើម្បីដាក់បញ្ចូលតម្រូវការទិន្នន័យថ្មីពីផែនការយុទ្ធសាស្ត្រជាតិចុងក្រោយបំផុត និងពីក្របខ័ណ្ឌ MEL នេះ។

នឹងមានការរាយការណ៍បីកម្រិត ស្របតាមយន្តការរាយការណ៍មានស្រាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការរាយការណ៍ត្រូវបានពង្រីកដើម្បីដាក់បញ្ចូលការតាមដានសូចនាករសំខាន់ៗ – សម្រាប់ទាំងផលសម្រេច និងលទ្ធផលតាមដំណាក់កាល។

- ការរាយការណ៍ថ្នាក់ជាតិ - រួមមានរបាយការណ៍ជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.ជ.ប.ជ. របាយការណ៍វឌ្ឍនភាពជាតិរបស់ក្រុមការងារអន្តរក្រសួង-ស្ថាប័នទាំង ៦ ជូនអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងរបាយការណ៍វឌ្ឍនភាពជាតិរបស់ក្រសួង និងស្ថាប័ន ជូនក្រុមការងារអន្តរក្រសួង-ស្ថាប័នថ្នាក់ជាតិ។
- ការរាយការណ៍ថ្នាក់ក្រោមជាតិដល់ថ្នាក់ជាតិ - របាយការណ៍វឌ្ឍនភាពស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ គ.រ.ប.ជ./គ.ខ.ប.ជ. ជូន គ.ជ.ប.ជ. និងមន្ទីររាជធានី/ខេត្តធ្វើរបាយការណ៍ជូនក្រសួង ស្ថាប័នថ្នាក់ជាតិរៀងៗខ្លួន។
- ការរាយការណ៍ថ្នាក់ក្រោមជាតិ - របាយការណ៍វឌ្ឍនភាពស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់ស្ថាប័នថ្នាក់ក្រោមជាតិ និងក្រុមការងារថ្នាក់ក្រោមជាតិជូន គ.រ.ប.ជ./គ.ខ.ប.ជ.។

គំរូរបាយការណ៍មានស្រាប់នឹងត្រូវបានពិនិត្យមើលឡើងវិញ និងត្រូវបានកែលម្អដើម្បីដាក់បញ្ចូលលក្ខខណ្ឌប្រមូលទិន្នន័យ និងរាយការណ៍ក្រោមក្របខ័ណ្ឌ MEL។ គំរូទាំងនេះនឹងត្រូវបានដាក់បញ្ចូលនៅក្នុងកញ្ចប់ឧបករណ៍ដែលត្រូវប្រើក្នុងអំឡុងពេលបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការងារ MEL នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

## តារាងទី ៤៖ កិច្ចដំណើរការរាយការណ៍ និងក្របខ័ណ្ឌពេលវេលា

| ឈ្មោះរបាយការណ៍ | ការពិពណ៌នាអំពីរបាយការណ៍ | របាយការណ៍ត្រូវបានរៀបចំដោយ | របាយការណ៍ត្រូវបានដាក់ជូន | ពេលដែលត្រូវដាក់របាយការណ៍ |
|---|---|---|---|---|
| របាយការណ៍សកម្មភាពប្រចាំខែ | របាយការណ៍បូកសរុបស្តីពីសកម្មភាពលម្អិតដែលបានបញ្ចប់ និងកំពុងដំណើរការ | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រុមការងារបច្ចេកទេសនៃក្រសួង និងស្ថាប័នទាំង ៦ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំខែ - រៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ |

| ឈ្មោះរបាយការណ៍ | ការពិពណ៌នាអំពីរបាយការណ៍ | របាយការណ៍ត្រូវបានរៀបចំដោយ | របាយការណ៍ត្រូវបានដាក់ជូន | ពេលដែលត្រូវដាក់របាយការណ៍ |
|---|---|---|---|---|
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំខែ - រៀងរាល់ថ្ងៃទី ៥ នៃខែបន្ទាប់ |
| | | មន្ទីរ/អង្គភាពថ្នាក់ក្រោមជាតិ | គ.រ.ប.ជ./គ.ខ.ប.ជ. | ប្រចាំខែ - រៀងរាល់ថ្ងៃទី ៥ នៃខែបន្ទាប់ |
| របាយការណ៍ផលសម្រេច | ទិន្នន័យ ឬព័ត៌មានទាក់ទងនឹងព័ត៌មានលម្អិតអំពីផលសម្រេច ឬលទ្ធផលនៃសកម្មភាពដែលបានអនុវត្ត ដែលត្រូវបានចងក្រងពីរបាយការណ៍សកម្មភាព | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រុមការងារបច្ចេកទេសនៃក្រសួង និងស្ថាប័នទាំង ៦ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំខែ - រៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំខែ - រៀងរាល់ថ្ងៃទី ៥ នៃខែបន្ទាប់ |
| | | មន្ទីរ/អង្គភាពថ្នាក់ក្រោមជាតិ | គ.រ.ប.ជ./គ.ខ.ប.ជ. | ប្រចាំខែ - រៀងរាល់ថ្ងៃទី ៥ នៃខែបន្ទាប់ |
| របាយការណ៍វឌ្ឍនភាពប្រចាំឆមាស | របាយការណ៍បូកសរុបវឌ្ឍនភាពអំពីផលសម្រេច និងលទ្ធផល រួមទាំងសេចក្ដីសង្ខេបអំពីក្របខ័ណ្ឌការងារ ACWC | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័នទាំង ៦ និង ក្រុមការងារ MEL នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំឆមាស - រៀងរាល់ថ្ងៃទី ១០ នៃខែកក្កដា និងខែមករា |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំឆមាស - រៀងរាល់ថ្ងៃទី ៥ នៃខែកក្កដា និងខែមករា |
| | | មន្ទីរ/អង្គភាពថ្នាក់ក្រោមជាតិ | គ.រ.ប.ជ./គ.ខ.ប.ជ. | ប្រចាំឆមាស - រៀងរាល់ថ្ងៃទី ៥ នៃខែកក្កដា និងខែមករា |
| របាយការណ៍ប្រចាំឆ្នាំ | របាយការណ៍បូកសរុបវឌ្ឍនភាពប្រចាំឆ្នាំ ដែលចងក្រងចេញពីរបាយការណ៍ផល | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័នទាំង ៦ និង ក្រុមការងារ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំឆ្នាំ - រៀងរាល់ខែកុម្ភៈ |

| ឈ្មោះរបាយការណ៍ | ការពិពណ៌នាអំពីរបាយការណ៍ | របាយការណ៍ត្រូវបានរៀបចំដោយ | របាយការណ៍ត្រូវបានដាក់ជូន | ពេលដែលត្រូវដាក់របាយការណ៍ |
|---|---|---|---|---|
| | សម្រេច និងរបាយការណ៍វឌ្ឍនភាពប្រចាំធមាស | MEL នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | | |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំឆ្នាំ - រៀងរាល់ថ្ងៃទី ៣១ ខែមករា នៃឆ្នាំបន្ទាប់ |
| | | មន្ទីរ/អង្គភាពថ្នាក់ក្រោមជាតិ | គ.រ.ប.ជ./គ.ខ.ប.ជ. | ប្រចាំឆ្នាំ - រៀងរាល់ថ្ងៃទី ៣១ ខែមករា នៃឆ្នាំបន្ទាប់ |

រៀងរាល់មួយឆ្នាំម្តង របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនឹងដាក់បញ្ចូលការវាយតម្លៃអំពីវឌ្ឍនភាពធៀបនឹងផែនការសកម្មភាព/ និងវឌ្ឍនភាពធៀបនឹងលទ្ធផលរយៈពេលមធ្យមនៃផែនការយុទ្ធសាស្ត្រជាតិ (រូបទី ១ ទ្រឹស្តីនៃការផ្លាស់ប្តូរ)។ ដើម្បីសង្គតិភាពក្នុងការរាយការណ៍ និងការវាយតម្លៃ ស្ថាប័នអនុវត្ត និងក្រុមការងារអន្តរក្រសួង-ស្ថាប័ននៃ គ.ជ.ប.ជ. នឹងប្រើរង្វាស់វាយតម្លៃមួយដែលនឹងត្រូវបានរៀបចំ និងដាក់បញ្ចូលនៅក្នុងកញ្ចប់ឯកសារណែនាំស្តីពីការរាយការណ៍។ រង្វាស់វាយតម្លៃនេះ នឹងផ្តល់ការណែនាំអំពីរបៀបវាយតម្លៃវឌ្ឍនភាព ជាឧទាហរណ៍ លទ្ធផលសម្រេចបាន សម្រេចបានខ្លះៗ មានការលំបាក ឬ មានការយឺតយ៉ាវខ្លះនៅក្នុងការអនុវត្តផែនការសកម្មភាព។

## ៥.៣ ការសិក្សាដកពិសោធន៍

ផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលស្គាល់សារៈសំខាន់នៃការងារ MEL។ ក្របខ័ណ្ឌ MEL នេះ កំពុងជំរុញការអនុវត្តការតាមដាន និងការវាយតម្លៃ ដើម្បីកែលម្អការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាពជាតិ។ វិធីសាស្ត្រ 'សិក្សាដកពិសោធន៍' នឹងធានាឱ្យបានប្រាដកថាអ្នកប្រើប្រាស់ចម្បងនៃក្របខ័ណ្ឌ MEL នឹងពិនិត្យមើលទិន្នន័យ និងនឹងវិភាគទិន្នន័យដែលនឹងបានទទួល ដើម្បីកែសម្រួលផែនការ និងសកម្មភាពដោយផ្អែកលើការសិក្សាដកពិសោធន៍របស់ពួកគេ។ តារាងទី ៥ ពិពណ៌នាអំពីវិប្បធម៌សិក្សាដកពិសោធន៍ស្របតាមផែនការយុទ្ធសាស្ត្រជាតិ។

## តារាងទី ៥៖ សកម្មភាព ឬព្រឹត្តិការណ៍សិក្សាដកពិសោធន៍សម្រាប់ការគ្រប់គ្រងបែបបត់បែន

| ព្រឹត្តិការណ៍ | អ្នកចូលរួមគោលដៅ | គោលបំណង | ពេលវេលា |
|---|---|---|---|
| កិច្ចប្រជុំសកម្មភាព (ផ្ទៃក្នុង) | អ្នកពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ឬដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ | ដើម្បីចែករំលែកនិងពិភាក្សាបច្ចុប្បន្នភាពសកម្មភាព:<br>▪ វឌ្ឍនភាពធៀបនឹងផែនការសកម្មភាពប្រចាំឆ្នាំ<br>▪ មេរៀនដែលបានទទួល<br>▪ សំណើកែប្រែចំពោះផែនការ ឬ សកម្មភាពដែលត្រូវធ្វើឆ្ពោះទៅមុខ | ប្រចាំខែ |
| កិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័ន | អ្នកពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តសកម្មភាពដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ឬដែលបានលើកឡើងនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ | ដើម្បីចែករំលែក និងពិភាក្សា បច្ចុប្បន្នភាពសកម្មភាព:<br>▪ វឌ្ឍនភាពធៀបនឹងផែនការសកម្មភាពប្រចាំឆ្នាំ<br>▪ ហានិភ័យ និងការកាត់បន្ថយហានិភ័យ<br>▪ មេរៀនដែលបានទទួល<br>▪ សំណើកែប្រែចំពោះផែនការ ឬ សកម្មភាពដែលត្រូវធ្វើឆ្ពោះទៅមុខ | ប្រចាំត្រីមាស ឬតាមតម្រូវការ |
| សិក្ខាសាលាពិនិត្យឡើងវិញ ឆ្លុះបញ្ចាំង និងរៀបចំផែនការនៃ គ.រ.ប.ជ./គ.ខ.ប.ជ. | សមាជិកថ្នាក់ក្រោមជាតិ | ដើម្បីចែករំលែក និងពិភាក្សា៖<br>▪ វឌ្ឍនភាពធៀបនឹងលទ្ធផល<br>▪ វឌ្ឍនភាពធៀបនឹងផែនការយុទ្ធសាស្ត្រជាតិ<br>▪ បញ្ហាប្រឈម ឧបសគ្គ និង គម្លាត<br>▪ របៀបដោះស្រាយឧបសគ្គ<br>▪ មេរៀនដែលបានទទួល<br>▪ សកម្មភាពដែលត្រូវធ្វើឆ្ពោះទៅមុខ | ប្រចាំឆមាស ឬប្រចាំឆ្នាំ |
| សិក្ខាសាលាឆ្លុះបញ្ចាំង និងរៀបចំផែនការនៃក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័ន | សមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួង-ស្ថាប័ន | ដើម្បីចែករំលែក និងពិភាក្សា៖<br>▪ វឌ្ឍនភាពធៀបនឹងលទ្ធផល<br>▪ វឌ្ឍនភាពធៀបនឹងផែនការយុទ្ធសាស្ត្រជាតិ<br>▪ បញ្ហាប្រឈម ឧបសគ្គ និង គម្លាត<br>▪ របៀបដោះស្រាយឧបសគ្គ<br>▪ មេរៀនដែលបានទទួល<br>▪ សកម្មភាពដែលត្រូវធ្វើឆ្ពោះទៅមុខ | ប្រចាំឆ្នាំ |

| ព្រឹត្តិការណ៍ | អ្នកចូលរួមគោលដៅ | គោលបំណង | ពេលវេលា |
|---|---|---|---|
| សិក្ខាសាលាពិនិត្យឡើងវិញ ឆ្លុះបញ្ចាំង និងរៀបចំផែនការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | សមាជិក និង/បុគ្គលិកនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ដើម្បីចែករំលែក និងពិភាក្សា៖<br>▪ វឌ្ឍនភាពធៀបនឹងលទ្ធផល<br>▪ វឌ្ឍនភាពធៀបនឹងផែនការយុទ្ធសាស្ត្រជាតិ<br>▪ បញ្ហាប្រឈម ឧបសគ្គ និង ចន្លោះប្រហោង<br>▪ របៀបដោះស្រាយឧបសគ្គ<br>▪ មេរៀនដែលបានទទួល<br>▪ សកម្មភាពដែលត្រូវធ្វើឆ្ពោះទៅមុខ | ប្រចាំឆមាស និង ប្រចាំឆ្នាំ |

## ៥.៤ ការអភិវឌ្ឍសមត្ថភាព MEL

គន្លឹះសម្រាប់ការអនុវត្តក្របខ័ណ្ឌ MEL នេះ គឺការកសាងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងក្រសួង-ស្ថាប័នជាសមាជិកគោលដៅ លើការតាមដាន និងការរាយការណ៍។ ក្រុមការងារ MEL ដែលត្រូវបានតែងតាំងនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. នឹងសម្របសម្រួលការអនុវត្តក្របខ័ណ្ឌនេះ រួមទាំងសកម្មភាព MEL ដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ។ អគ្គលេខាធិការដ្ឋាន ក៏នឹងបង្កើតផងដែរនូវបណ្តាញមន្ត្រីទទួលបន្ទុកការងារ MEL ដែលតំណាងឱ្យក្រសួង និងស្ថាប័នជាសមាជិក គ.ជ.ប.ជ. សូមមើលសេចក្តីព្រាងលក្ខខណ្ឌយោងនៅក្នុងឧបសម្ព័ន្ធ "ឃ"។ សកម្មភាព MEL ជាអាទិភាព នឹងរួមមានការបណ្តុះបណ្តាល និងសិក្ខាសាលាដើម្បីកសាងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារ MEL ដែលត្រូវបានតែងតាំង លើការតាមដាន និងរាយការណ៍ ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌ MEL នេះ។

# ៦ សកម្មភាព MEL និងការទទួលខុសត្រូវ

## ៦.១ សកម្មភាព MEL

ផែនការយុទ្ធសាស្ត្រជាតិ រួមមានផ្នែកមួយស្ដីពីការតាមដាន និងការវាយតម្លៃ រួមទាំងសកម្មភាពសម្រាប់ការអនុវត្តពីឆ្នាំ ២០២៤ ដល់ឆ្នាំ ២០២៨។ ការអភិវឌ្ឍក្របខ័ណ្ឌ MEL នេះ គឺជាសកម្មភាពគ្រឹះមួយ ដើម្បីត្រួសត្រាយផ្លូវឆ្ពោះទៅរកការបំពេញសកម្មភាពតាមដាន និងវាយតម្លៃដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រជាតិ។ ក្របខ័ណ្ឌ MEL នេះបានពង្រីកសកម្មភាព MEL ដើម្បីដាក់បញ្ចូលផែនការអនុវត្តសម្រាប់ក្របខ័ណ្ឌ MEL នេះ ដូចជាការប្រមូលទិន្នន័យ ការរាយការណ៍ អភិក្រមសិក្សាដកពិសោធន៍ និងការកសាងសមត្ថភាព។ ព័ត៌មានលម្អិតអំពីសកម្មភាព MEL ដែលបានគ្រោងពីឆ្នាំ ២០២៥ ដល់ឆ្នាំ ២០២៨ ត្រូវបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ "ង"។

## ៦.២ តួនាទី និងការទទួលខុសត្រូវ

ការទទួលខុសត្រូវពាក់ព័ន្ធនឹងការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ត្រូវបានសង្ខេបក្នុងតារាងទី ៦។

មន្ត្រីទទួលបន្ទុកការងារ MEL នឹងត្រូវបានកំណត់នៅក្នុងក្រសួង-ស្ថាប័នសមាជិកនីមួយៗនៃ គ.ជ.ប.ជ. ដើម្បីធ្វើការជាមួយក្រុមការងារ MEL នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ក្នុងការអនុវត្តក្របខ័ណ្ឌ MEL នេះ។ សេចក្តីព្រាងលក្ខខណ្ឌយោងការងារនៃមន្ត្រីទទួលបន្ទុកការងារ MEL (ឧបសម្ព័ន្ធ ឃ) ពិពណ៌នាអំពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកការងារ MEL។

## តារាងទី ៦៖ ការទទួលខុសត្រូវក្នុងក្របខ័ណ្ឌ MEL

| តួនាទី | ការទទួលខុសត្រូវ |
|---|---|
| គ.ជ.ប.ជ. | ▪ ត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ និងការអនុវត្តជារួមឆ្ពោះទៅសម្រេចគោលដៅ និងលទ្ធផលដែលបានគ្រោងទុកនៃផែនការយុទ្ធសាស្ត្រជាតិ<br>▪ ផ្តល់ការណែនាំ និងការធានាគុណភាពលើរបាយការណ៍វឌ្ឍនភាព<br>▪ ប្រើប្រាស់ទិន្នន័យសម្រាប់ការសម្រេចចិត្ត ការរៀបចំផែនការ និងការរាយការណ៍ |
| អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ▪ រៀបចំ និងពិនិត្យមើលក្របខ័ណ្ឌ MEL<br>▪ តាមដាន និងគ្រប់គ្រងការអនុវត្តផែនការក្របខ័ណ្ឌ MEL រួមទាំងការរាយការណ៍អំពីវឌ្ឍនភាព និងដំណើរការសិក្សាដកពិសោធន៍<br>▪ គ្រប់គ្រងការរៀបចំផែនការ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងការរាយការណ៍អំពីវឌ្ឍនភាព ស្របតាមក្របខ័ណ្ឌ MEL និងផែនការយុទ្ធសាស្ត្រជាតិ<br>▪ សម្របសម្រួលសិក្ខាសាលាពិនិត្យឡើងវិញ ឆ្លុះបញ្ចាំង និងរៀបចំផែនការរបស់ក្រុមការងារអន្តរក្រសួង-ស្ថាប័នទាំង ៦<br>▪ ប្រើប្រាស់ទិន្នន័យសម្រាប់ការធ្វើផែនការ ការអនុវត្តសកម្មភាព និងការរាយការណ៍<br>▪ លើកកម្ពស់ និងកសាងវប្បធម៌ MEL ជាមួយក្រសួង ស្ថាប័ន និងដៃគូនានា |
| មន្ត្រីទទួលបន្ទុកការងារ MEL | ▪ សម្របសម្រួលការអនុវត្តក្របខ័ណ្ឌ MEL នៅក្នុងក្រសួង ឬស្ថាប័នរបស់ខ្លួន<br>▪ អនុវត្តតួនាទីរបស់មន្ត្រីទទួលបន្ទុកការងារ MEL ស្របតាមលក្ខខណ្ឌយោងការងារ MEL (ឧបសម្ព័ន្ធ ឃ)<br>▪ សម្របសម្រួលការប្រមូល ការរួមផ្សំ និងការវិភាគផលសម្រេច និងសូចនាករលទ្ធផលដែលបានលើកឡើងនៅក្នុងក្របខ័ណ្ឌ MEL<br>▪ ព្រាងរបាយការណ៍វឌ្ឍនភាពសម្រាប់ក្រសួង ឬស្ថាប័នរៀងៗខ្លួន |
| ក្រុមការងារអន្តរក្រសួង-ស្ថាប័ន | ▪ តាមដានការវិភាគ និងការព្រាងរបាយការណ៍វឌ្ឍនភាពដោយអនុលោមតាមក្របខ័ណ្ឌ MEL និងពេលវេលាដែលបានព្រមព្រៀងគ្នា |

| តួនាទី | ការទទួលខុសត្រូវ |
|---|---|
| | ▪ សម្របសម្រួលសិក្ខាសាលាពិនិត្យឡើងវិញ ឆ្លុះបញ្ចាំង និងរៀបចំផែនការនៃក្រុមការងារអន្តរក្រសួង/ស្ថាប័ន<br>▪ ប្រើប្រាស់ទិន្នន័យសម្រាប់ការធ្វើផែនការ ការអនុវត្តសកម្មភាព និងការរាយការណ៍<br>▪ គាំទ្រការអនុវត្ត និងការពិនិត្យឡើងវិញនៃក្របខ័ណ្ឌ MEL<br>▪ គាំទ្រការអនុវត្តនៃសកម្មភាព MEL<br>▪ លើកកម្ពស់ និងគាំទ្រការកសាងវប្បធម៌ MEL ជាមួយក្រសួង ស្ថាប័ន និងដៃគូនានា |
| ក្រសួង ស្ថាប័ន និងអង្គភាពឯកទេសជាសមាជិក គ.ជ.ប.ជ. | ▪ រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ស្របតាមផែនការយុទ្ធសាស្ត្រជាតិ និងក្របខ័ណ្ឌ MEL<br>▪ សម្របសម្រួលការប្រមូលទិន្នន័យ និងចងក្រងទិន្នន័យ និងរក្សាទុកមូលដ្ឋានទិន្នន័យពាក់ព័ន្ធ ស្របតាមផែនការសកម្មភាពប្រចាំឆ្នាំរៀងៗខ្លួន<br>▪ រៀបចំ និងដាក់ជូនរបាយការណ៍វឌ្ឍនភាពស្របតាមពេលវេលាដែលឯកភាពគ្នា<br>▪ គាំទ្រការអនុវត្ត និងការពិនិត្យឡើងវិញក្របខ័ណ្ឌ MEL<br>▪ គាំទ្រការអនុវត្តសកម្មភាព MEL<br>▪ លើកកម្ពស់ និងគាំទ្រការកសាងវប្បធម៌ MEL |
| ភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដៃគូអនុវត្តន៍ | ▪ លើកកម្ពស់ និងគាំទ្រការកសាងវប្បធម៌ MEL ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>▪ គាំទ្រការប្រមូល និងការរាយការណ៍ទិន្នន័យ នៅពេលមានការស្នើសុំ<br>▪ ចូលរួមក្នុងសកម្មភាព MEL របស់ គ.ជ.ប.ជ. និងលេខាធិការដ្ឋាន នៅពេលមានការអញ្ជើញ |

# ៧ ក្រមសីលធម៌ក្នុងការតាមដាន និងការវាយតម្លៃ

ក្របខ័ណ្ឌនេះ ទទួលស្គាល់សារៈសំខាន់នៃក្រមសីលធម៌ក្នុងការតាមដាន វាយតម្លៃ និងរាយការណ៍។ ផែនការយុទ្ធសាស្ត្រជាតិ ប្រហែលជានឹងពាក់ព័ន្ធជាមួយជនងាយរងគ្រោះ ជនរងគ្រោះ-ជនដែលធ្លាប់រងគ្រោះ និងកុមារ។ ក្របខ័ណ្ឌនេះ នឹងគោរពតាមការអនុវត្តប្រកបដោយក្រមសីលធម៌ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ការប្រមូល ការរក្សាទុក និងការរាយការណ៍ទិន្នន័យក្រោមក្របខ័ណ្ឌនេះ នឹងអនុវត្តតាមនីតិវិធីតឹងរ៉ឹងដើម្បីរក្សាការសម្ងាត់នៃព័ត៌មានដែលបានប្រមូល រក្សាទុក និងរាយការណ៍។

មុនពេលប្រមូលទិន្នន័យពីបុគ្គលណាម្នាក់សម្រាប់គោលបំណង MEL អ្នកចូលរួមត្រូវបានតម្រូវឱ្យផ្តល់ការយល់ព្រមប្រកបដោយព័ត៌មានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ (ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់)។ ប្រការនេះ ត្រូវអនុវត្តនៅពេលធ្វើការសម្ភាស សម្រាប់ករណីសិក្សា ការស្រាវជ្រាវ និង/ឬរឿងរ៉ាវនៃការផ្លាស់ប្តូរ និងក្នុងពេលធ្វើការវាយតម្លៃ ។

# ឧបសម្ព័ន្ធ ក៖ សូចនាករ និងសកម្មភាពដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ

| លទ្ធផលរយៈពេលមធ្យម<br>(ដកស្រង់ពីរូបទី ១ នៃក្របខ័ណ្ឌ MEL នេះ) | ចង្កោមសកម្មភាព/សកម្មភាពចម្បង<br>(ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) | លទ្ធផលសូចនាករ<br>(ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) |
|---|---|---|
| **យុទ្ធសាស្ត្រទី ១៖ លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារ** | | |
| ១.ក ក្រុមងាយរងគ្រោះ និងភាគីពាក់ព័ន្ធដែលជាក្រុមអាទិភាពបានទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងមានសង្គតិភាព។ | ១.១. រៀបចំ និងអនុវត្តវិធីសាស្ត្រ ឆ្ពោះទៅការផ្លាស់ប្តូរឥរិយាបថអវិជ្ជមានដែលងាយបង្កភាពរងគ្រោះដោយអំពើ ជួញដូរមនុស្សគ្រប់ទម្រង់ ។ | ១. ស្ថានភាព និងផលប៉ះពាល់ នៃការធ្វើទេសន្តរប្រវេសន៍ចំពោះសង្គម ត្រូវបានតាមដានជាប្រចាំ និងផ្សព្វផ្សាយ<br>២. សេវាកម្មសម្រាប់ការគាំទ្រសុវត្ថិភាពទេសន្តរប្រវេសន៍ មានភាពប្រសើរឡើង<br>៣. ទិន្នន័យអំពីសិប្បកម្ម ធុរកិច្ច និងតម្រូវការកម្លាំងផលិតករ កម្មករ ត្រូវបានដាក់ផ្សព្វផ្សាយជាប្រចាំ<br>៤. អភិក្រមបង្ការ បង្ការទប់ស្កាត់យុវវ័យ និងកុមារប្រឈមភាពរងគ្រោះត្រូវបានផលិត |
| ១.ក ក្រុមងាយរងគ្រោះ និងភាគីពាក់ព័ន្ធដែលជាក្រុមអាទិភាពបានទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងមានសង្គតិភាព។ | ១.២. លើកកម្ពស់ គុណតម្លៃ និងសង្គតិភាពនៃសារ និងអភិក្រមអប់រំផ្សព្វផ្សាយ ដោយផ្តោតការយកចិត្តទុកដាក់លើក្រុមដែលងាយរងគ្រោះ និងភាគីពាក់ព័ន្ធជាអាទិភាព និងទម្រង់នៃបទល្មើសជួញដូរមនុស្ស ដែលកំពុងកើតមាន ។ | ៥. ពិនិត្យ រៀបចំ និងដាក់ឱ្យប្រើប្រាស់ ឧបករណ៍ សម្ភារ និងសាររួមសម្រាប់ប្រើប្រាស់ក្នុងការផ្សព្វផ្សាយ បង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស ប្រកបដោយភាពច្បាស់លាស់ និងសង្គតិភាព ទៅតាមក្រុមគោលដៅជាក់លាក់នីមួយៗ<br>៦. បានរៀបចំ និងដាក់ឱ្យប្រើប្រាស់ ប្រព័ន្ធផ្ទុកឧបករណ៍ សម្ភារ និងសាររួម ដែលអាចឱ្យអ្នកប្រើប្រាស់ និងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងអង្គការដៃគូ ទាញយក និងផលិតឡើងវិញ<br>៧. សង្គតិភាព និងគុណភាពនៃសារបង្ការបង្ការទប់ស្កាត់ត្រូវបានពង្រឹង |
| ១.ក ក្រុមងាយរងគ្រោះ និងភាគីពាក់ព័ន្ធដែលជាក្រុមអាទិភាពបានទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងមានសង្គតិភាព។ | ១.៣. លើកកម្ពស់ការធ្វើការសម្រេចចិត្ត ដើម្បីជម្រើសដែលល្អប្រសើរសម្រាប់ការទទួលបានការងារ និងមុខរបរសមរម្យ ជាពិសេស ស្ត្រី យុវជន ក្មេង និងយុវជន។ | ៨. បានបង្កើនចំណេះដឹងដល់ប្រជាជនគោលដៅដែលអាចជួយឱ្យមានការសម្រេចចិត្តជ្រើសយកជម្រើសប្រសើរចៀសផុតពីភាពរងគ្រោះ ដោយចំណាកស្រុកដោយប្រថុយប្រថាន និងដោយអំពើជួញដូរមនុស្ស |

| លទ្ធផលរយៈពេលមធ្យម (ដកស្រង់ពីរូបទី ១ នៃក្របខ័ណ្ឌ MEL នេះ) | ចង្កោមសកម្មភាព/សកម្មភាពចម្បង (ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) | លទ្ធផលសូចនាករ (ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) |
|---|---|---|
| ១.ក ក្រុមងាយរងគ្រោះ និងភាគីពាក់ព័ន្ធដែលជាក្រុមអាទិភាពបានទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងមានសង្គតិភាព។ | ១.៤. លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឌីជីថលប្រកបដោយសុវត្ថិភាព។ | ៩. ចំណេះដឹង និងការអនុវត្តពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឌីជីថលប្រកបដោយសុវត្ថិភាពត្រូវបានផ្សព្វផ្សាយទូលំទូលាយដល់ប្រជាជនគោលដៅ<br>១០. មានកិច្ចសហការប្រកបដោយប្រសិទ្ធភាពជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថលក្នុងការចូលរួមបង្ការបង្ក្រាទប់ស្កាត់អំពើជួញដូរមនុស្ស<br>១១. កិច្ចអន្តរាគមន៍ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធករណីរំលោភបំពានកេងប្រវ័ញ្ចតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឌីជីថល |
| ១.គ តំបន់គោលដៅបានអភិវឌ្ឍកម្មវិធីអប់រំស្តីពីអំពើជួញដូរមនុស្សដែលគ្រប់ជ្រុងជ្រោយ និងមានគុណភាព | ១.៥. ជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព វិធានការអធិការកិច្ចទីតាំងគោលដៅសង្ស័យពាក់ព័ន្ធអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ | ១២. គ្រប់ជំនាញតាមក្រសួង ស្ថាប័នពាក់ព័ន្ធ បានពង្រឹងការចុះតាមដាន តាមដានទីតាំងគោលដៅសង្ស័យ ដែលអាចកើតមានបទល្មើសជួញដូរ រំលោភបំពាន និង កេងប្រវ័ញ្ចផ្សេងៗប្រកបដោយប្រសិទ្ធភាពខ្ពស់ |
| ១.ក ក្រុមងាយរងគ្រោះ និងភាគីពាក់ព័ន្ធដែលជាក្រុមអាទិភាពបានទទួលសារ និងកម្មវិធីផ្សព្វផ្សាយដែលមានគុណភាព និងមានសង្គតិភាព។ | ១.៦. ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ (ការបណ្តុះបណ្តាលជំនាញគ្រប់គ្រងផ្នែកហិរញ្ញវត្ថុគ្រួសារ ផែនការជីវិត ជំនាញបំណិនជីវិត/ជំនាញទន់ និងភាពធន់ទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ជាដើម)។ | ១៣. ប្រជាជនគោលដៅទទួលបានចំណេះជំនាញចាំបាច់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងទ្រទ្រង់ជីវភាពគ្រួសារដោយពុំចាំបាច់ពឹងផ្អែកទាំងស្រុងលើការធ្វើចំណាកស្រុកដោយប្រថុយប្រថាន |
| ៤.ក វិស័យឯកជន សង្គមស៊ីវិល និងស្ថាប័នថ្នាក់ក្រោមជាតិកំពុងចូលរួម និងប្រឡូកយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស | ១.៧. ជំរុញការចូលរួមពីវិស័យឯកជនក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ (មានជាអាទិ៍៖ វិស័យអប់រំ ទេសចរណ៍ ការងារ កសិកម្ម ឧស្សាហកម្ម សិប្បកម្ម សុខាភិបាល មីក្រូហិរញ្ញវត្ថុ ដឹកជញ្ជូន ធនាគារ ប្រៃសណីយ៍ និងទូរគមនាគមន៍) | ១៤. កម្មវិធីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមសាលារៀន ត្រូវបានអនុវត្ត<br>១៥. គ្រូទទួលបានការយល់ដឹងពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស<br>១៦. វិស័យឯកជនបានចូលរួមយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស |

| លទ្ធផលរយៈពេលមធ្យម (ដកស្រង់ពីរូបទី ១ នៃក្របខ័ណ្ឌ MEL នេះ) | ចង្កោមសកម្មភាព/សកម្មភាពចម្បង (ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) | លទ្ធផលសូចនាករ (ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) |
|---|---|---|
| ១.គ តំបន់គោលដៅបានអភិវឌ្ឍកម្មវិធីអប់រំស្តីពីអំពើជួញដូរមនុស្សដែលគ្រប់ជ្រុងជ្រោយ និងមានគុណភាព | ១.៨. វិធានការបង្ការទប់ស្កាត់ តាមរយៈការបង្កើនការយល់ដឹង អំពីច្បាប់ គោលនយោបាយ លិខិតុបករណ៍ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធរាល់ទម្រង់នៃបទល្មើសជួញដូរមនុស្ស | ១៧. គ្រប់សមាសភាពពាក់ព័ន្ធ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ទទួលបានការយល់ដឹងពីខ្លឹមសារ គោលនយោបាយពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កលល្បិចជនល្មើស និងផលប៉ះពាល់នៃទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន និងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស |
| ១.ខ សហគមន៍ និងក្រុមគោលដៅមានការយល់ដឹងកាន់តែច្រើនស្តីពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស | ១.៩. ពង្រឹងការអនុវត្តវិធានការបង្ការទប់ស្កាត់ការជួញដូរមនុស្សតាមរូបភាពរៀបអាពាហ៍ពិពាហ៍ ឬការជ្រើសរើសគូស្រករ | ១៨. ព័ត៌មានពីភាពរងគ្រោះតាមរយៈអាពាហ៍ពិពាហ៍ជាមួយជនបរទេស ត្រូវបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគោលដៅ<br>១៩. អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសមិនស្របច្បាប់ ត្រូវបានកាត់បន្ថយ |
| ១.ខ សហគមន៍ និងក្រុមគោលដៅមានការយល់ដឹងកាន់តែច្រើនស្តីពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស | ១.១០. ជំរុញការអនុវត្តវិធានការ ឆ្លើយតប និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ។ | ២០. អ្នកសារព័ត៌មាន ពិធីករ សិល្បករ ផលិតករ ពាណិជ្ជករវិស័យសិល្បៈ ពាណិជ្ជករវិស័យទេសចរណ៍ វិស័យសេវាកម្សាន្ត និងភាគីពាក់ព័ន្ធ បានយល់ច្បាស់អំពីអំពើជួញដូរមនុស្ស<br>២១. បានបង្កើតស្នាដៃអប់រំសង្គម ឱ្យរួមគ្នាលុបបំបាត់អំពើជួញដូរមនុស្ស គ្រប់រូបភាព ប្រកបដោយសីលធម៌វិជ្ជាជីវៈ<br>២២. ប្រជាជនគោលដៅយល់ដឹង អំពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់ នៃអំពើជួញដូរមនុស្ស |
| ១.គ តំបន់គោលដៅបានអភិវឌ្ឍកម្មវិធីអប់រំស្តីពីអំពើជួញដូរមនុស្សដែលគ្រប់ជ្រុងជ្រោយ និងមានគុណភាព | ១.១១. ពង្រឹងប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈ រួមទាំងយុទ្ធនាការថ្នាក់ជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ២៣. កម្មវិធីអប់រំផ្សព្វផ្សាយទូលំទូលាយ ដល់ប្រជាពលរដ្ឋគ្រប់តំបន់គោលដៅ ត្រូវបានបង្កើតឡើងប្រកបដោយគុណភាពខ្ពស់ និងត្រូវបានអនុវត្តជាប្រចាំ |
| ១.ខ សហគមន៍ និងក្រុមគោលដៅមានការយល់ដឹងកាន់តែច្រើនស្តីពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស | ១.១២. ពង្រឹង និងជំរុញការប្រើប្រាស់យន្តការរាយការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលាចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពាន ដែលពាក់ព័ន្ធ | ២៤. យន្តការរាយការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលាចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានដែលពាក់ព័ន្ធ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រជាជនគោលដៅ |

| លទ្ធផលរយៈពេលមធ្យម (ដកស្រង់ពីរូបទី ១ នៃក្របខ័ណ្ឌ MEL នេះ) | ចង្កោមសកម្មភាព/សកម្មភាពចម្បង (ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) | លទ្ធផលសូចនាករ (ដកស្រង់ពីផែនការយុទ្ធសាស្ត្រជាតិ) |
|---|---|---|
| ១.ឃ ពលករវិលត្រឡប់ និងពលករដែលប្រឈមនឹងការធ្វើទេសន្តរប្រវេសន៍ដឹងអំពីនីតិវិធីធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងសណ្តាប់ធ្នាប់ | ១.១៣. លើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ | ២៥. មណ្ឌលទទួលពលករតាមព្រំដែន (មណ្ឌលទទួលពលករកំរៀង បាត់ដំបង មណ្ឌលសំចតប៉ោយប៉ែត បន្ទាយមានជ័យ) ត្រូវបានពង្រឹង ដើម្បីផ្តល់ព័ត៌មាន អំពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព និងសេវាដល់ពលករដែលវិលត្រឡប់ និងពលករត្រូវការស្វែងយល់ និងប្រជាពលរដ្ឋតាមសហគមន៍<br>២៦. ឃុំ-សង្កាត់ មានផែនការសកម្មភាពបង្ការទប់ស្កាត់សម្រាប់អនុវត្ត<br>២៧. គុណភាពនៃកម្មវិធីបណ្តុះបណ្តាល និងការបណ្តុះបណ្តាលមុនចេញដំណើរ តាមបណ្តាស្ថាប័នជ្រើសរើសឯកជន ត្រូវបានពង្រឹង និងអនុវត្ត<br>២៨. បញ្ជីទិន្នន័យពាក់ព័ន្ធនឹងស្ថាប័នជ្រើសរើសឯកជន ត្រូវបានធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយជាប្រចាំ<br>២៩. ស្ថាប័នជ្រើសរើសឯកជនត្រូវបានធ្វើអធិការកិច្ចជាប្រចាំ<br>៣០. វិធានការចំពោះស្ថាប័នជ្រើសរើសឯកជនដែលមិនអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត ត្រូវបានរឹតបន្តឹង និងអនុវត្តយ៉ាងខ្ជាប់ខ្ជួន |
| ៤.ខ ស្ថាប័នយុត្តិធម៌ និងភាគីពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កំពុងសហការគ្នាបង្ការទប់ស្កាត់ បង្ក្រាប និងឆ្លើយតបនឹងអំពើជួញដូរមនុស្ស | ១.១៤. ពង្រឹងកិច្ចសហប្រតិបត្តិការ និងវិធានការគ្រប់គ្រងព្រំដែនរួមគ្នា និងពង្រឹងវិធានការជំនាញបង្ការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ | ៣១. វិធានការសហប្រតិបត្តិការជាមួយប្រទេសពាក់ព័ន្ធស្តីពីការពង្រឹងវិធានការជំនាញបង្ការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់<br>៣២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យលំហូរចេញ-ចូលរបស់ពលករ ត្រូវបានដំណើរការ |

| ការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ | | |
|---|---|---|
| ១.ង បានរៀបចំ និងអនុវត្តកម្មវិធីយុទ្ធនាការ និងយន្តការបង្ការទប់ស្កាត់ស្ដីពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ | ១.១៥. ពង្រឹងប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ | ៣៣. ប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ត្រូវបានពង្រឹង និងអនុវត្តយ៉ាងទូលំទូលាយដល់ប្រជាជនគោលដៅ |
| ១.ង បានរៀបចំ និងអនុវត្តកម្មវិធីយុទ្ធនាការ និងយន្តការបង្ការទប់ស្កាត់ស្ដីពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ | ១.១៦. លើកកម្ពស់ប្រព័ន្ធសុវត្ថិភាពកុមារ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារគ្រប់រូបភាព (ក្រសួងអប់រំ៖ មុខវិជ្ជាអប់រំសុខភាពសិក្សា) | ៣៤. ចំណេះដឹងស្ដីពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស និងកិច្ចការពារកុមារ ត្រូវបានផ្សព្វផ្សាយ និងអនុវត្ត នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ គ្រប់កម្រិត<br>៣៥. បណ្ដាញសុវត្ថិភាពការពារកុមារក្នុងសាលារៀនត្រូវបានបង្កើត និងពង្រីកបន្ថែម |
| ១.ង បានរៀបចំ និងអនុវត្តកម្មវិធីយុទ្ធនាការ និងយន្តការបង្ការទប់ស្កាត់ស្ដីពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ | ១.១៧. ពង្រឹង និងជំរុញការប្រើប្រាស់យន្តការរាយការណ៍តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលាចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារគ្រប់ទម្រង់ | ៣៦. យន្តការរាយការណ៍តាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ចំពោះអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារ គ្រប់ទម្រង់ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយប្រជាជនគោលដៅ |
| ១.ង បានរៀបចំ និងអនុវត្តកម្មវិធីយុទ្ធនាការ និងយន្តការបង្ការទប់ស្កាត់ស្ដីពីការរំលោភបំពាន និងការកេងប្រវ័ញ្ចកុមារ | ១.១៨. ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងកិច្ចការពារកុមារ (កម្មវិធីកុមារឆ្លាតវៃ និងសុវត្ថិភាពឌីជីថល-និយ័តករក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ វិធានការការពារសុវត្ថិភាពនៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារ | ៣៧. ប្រព័ន្ធបណ្ដាញសង្គម និងប្រព័ន្ធឌីជីថល ត្រូវបានប្រជាជនគោលដៅប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការផ្សព្វផ្សាយព័ត៌មាន ស្ដីពីទម្រង់ និងឧបាយកលនៃអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ច រំលោភបំពានកុមារ<br>៣៨. ប្រព័ន្ធលេខទូរស័ព្ទបន្ទាន់ (hotline) ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ប្រជាពលរដ្ឋទូទៅតាមរយៈប្រព័ន្ធទូរស័ព្ទចល័ត (TRC)<br>៣៩. ប្រជាពលរដ្ឋប្រើប្រាស់លេខទូរស័ព្ទបន្ទាន់ (hotline) រាយការណ៍ ឬសុំកិច្ចអន្តរាគមន៍ជួយសង្គ្រោះពីអាជ្ញាធរមានសមត្ថកិច្ច |

| យុទ្ធសាស្ត្រទី ២៖ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់ | | |
|---|---|---|
| ២.ក លិខិតុបករណ៍ច្បាប់ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងការវិវត្តនៃឧក្រិដ្ឋកម្មជួញដូរមនុស្ស | ២.១. សិក្សាស្រាវជ្រាវអំពីភាពប្រែប្រួល ឬទម្រង់ថ្មីៗនៃបទល្មើស ល្បិចកល និងបណ្តាញជនល្មើស រួមទាំងអំពើពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា ដើម្បីកំណត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព | ៤០. លទ្ធផលនៃការសិក្សាស្រាវជ្រាវពីនិន្នាការ បម្រែបម្រួល និងទម្រង់ថ្មីៗ នៃបទល្មើស ល្បិចកល និងបណ្តាញជនល្មើស រួមទាំងអំពើពាក់ព័ន្ធនឹង បទល្មើសបច្ចេកវិទ្យា និងបទល្មើសជួញដូរមនុស្ស ត្រូវបានផ្សព្វផ្សាយ<br>៤១. លទ្ធផលនៃការសិក្សាស្រាវជ្រាវត្រូវបានយកប្រើប្រាស់ដើម្បីកំណត់វិធានការបង្ក្រាបអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព |
| ២.ក លិខិតុបករណ៍ច្បាប់ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងការវិវត្តនៃឧក្រិដ្ឋកម្មជួញដូរមនុស្ស | ២.២. ពិនិត្យ និងកែសម្រួលក្របខ័ណ្ឌច្បាប់ដើម្បីអាចឆ្លើយតបបានទៅនឹងបច្ចុប្បន្នភាព និងការវិវត្តនៃការជួញដូរមនុស្ស | ៤២. មាត្រាពាក់ព័ន្ធក្នុង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងច្បាប់ ឬគោលនយោបាយពាក់ព័ន្ធ ត្រូវបានពិនិត្យឡើងវិញ ធ្វើការកែសម្រួល ឬធ្វើវិសោធនកម្ម យោងតាមករណីចាំបាច់ជាក់ស្តែង<br>៤៣. នីតិវិធីក្នុងការផ្តល់សំណងជូនជនរងគ្រោះ ត្រូវបានអនុវត្ត |
| ២.ខ វិស័យយុត្តិធម៌បានពង្រឹងយន្តការប្រមូលទិន្នន័យ និងរាយការណ៍ស្តីពីករណីអំពើជួញដូរមនុស្ស | ២.៣. ពង្រឹងយន្តការនៃការប្រមូលទិន្នន័យសំណុំរឿងជួញដូរមនុស្សពីដំណាក់កាលអយ្យការ រហូតដល់ដំណាក់កាលជំនុំជម្រះ | ៤៤. ទិន្នន័យពាក់ព័ន្ធនឹងសំណុំរឿងជួញដូរមនុស្សគ្រប់ទម្រង់ ត្រូវបានប្រមូល ចងក្រង គ្រប់ដំណាក់កាល និងចែករំលែក/ រាយការណ៍ ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សមស្រប តាមពេលវេលាកំណត់ ប្រកបដោយសុក្រឹតភាព និងសង្គតិភាព |
| ៤.ខ ស្ថាប័នយុត្តិធម៌ និងភាគីពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កំពុងសហការគ្នាបង្ការទប់ស្កាត់ បង្ក្រាប និងឆ្លើយតបនឹងអំពើជួញដូរមនុស្ស | ២.៤. បន្តពង្រឹងកិច្ចសហការរវាងស្ថាប័ន និងមន្ត្រីជំនាញអនុវត្តច្បាប់ សង្គមកិច្ច ជាមួយនឹងស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីរួមគ្នាជាបណ្តាញបង្ការទប់ស្កាត់ បង្ក្រាបឧក្រិដ្ឋកម្មជួញដូរមនុស្សឆ្លងដែន និងពង្រឹងការអនុវត្តច្បាប់ ផ្តន្ទាទោសជនល្មើស ការពារសិទ្ធិ និងឧត្តមប្រយោជន៍ជនរងគ្រោះ | ៤៥. ការសម្របសម្រួល និងកិច្ចសហការមន្ត្រីអនុវត្តច្បាប់ និងស្ថាប័នអយ្យការ តុលាការ និងសេវាសង្គមមានការអនុវត្តដោយភាពរលូនដើម្បីលើកកម្ពស់សិទ្ធិ សេចក្តីថ្លៃថ្នូរ និងឧត្តមប្រយោជន៍ជនរងគ្រោះ<br>៤៦. ឧក្រិដ្ឋជនប្រព្រឹត្តបទល្មើសជួញដូរមនុស្សគ្រប់ទម្រង់ត្រូវបានផ្តន្ទាទោសតាមច្បាប់ជាធរមាន |

| | | |
|---|---|---|
| ២.ឃ មន្ត្រីអនុវត្តន៍ច្បាប់បានពង្រឹងសមត្ថភាពស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ២.៥. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់អំពីជំនាញពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការ លើការងារប្រឆាំងអំពើជួញដូរមនុស្សគ្រប់ដំណាក់កាល និងលើកកម្ពស់ក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអនុវត្តច្បាប់ | ៤៧. ក្រសួង ស្ថាប័ន ក្នុងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានយល់ដឹង និងមានសមត្ថភាពដាក់ និងអនុវត្តវិធានការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព<br>៤៨. មន្ត្រីអនុវត្តច្បាប់ទទួលបានការបណ្តុះបណ្តាលសមត្ថភាព ជំនាញនីតិវិធីស៊ើបអង្កេត និងអនុវត្តការងារប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ<br>៤៩. មន្ត្រីជំនាញទទួលបានការបណ្តុះបណ្តាលពីសុវត្ថិភាពស្ត្រី និងកុមារ ក្នុងវិស័យទេសចរណ៍ និងបានយល់ដឹងអំពីច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| ២.ក លិខិតុបករណ៍ច្បាប់ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន និងការវិវត្តនៃឧក្រិដ្ឋកម្មជួញដូរមនុស្ស | ២.៦. ជំរុញការអនុវត្ត និងតាមដានប្រសិទ្ធភាពនៃច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្ត អនុស្សរណៈ កិច្ចព្រមព្រៀង នីតិវិធីប្រតិបត្តិស្តង់ដារពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស រវាងស្ថាប័ន និង/ឬប្រទេសពាក់ព័ន្ធ ទាំងនៅកម្រិតជាតិ តំបន់ និងអន្តរជាតិ | |
| ២.ខ វិស័យយុត្តិធម៌បានពង្រឹងយន្តការប្រមូលទិន្នន័យ និងរាយការណ៍ស្តីពីករណីអំពើជួញដូរមនុស្ស | ២.៧. បន្តពង្រឹង និងយកចិត្តទុកដាក់ចំពោះចំណាត់ការសំណុំរឿងជួញដូរមនុស្សនៅគ្រប់ដំណាក់កាល | |
| ២.ង ប្រព័ន្ធយុត្តិធម៌បានពង្រីកការប្រើប្រាស់នីតិវិធីស្តាប់ចម្លើយតាមបែបកុមារមេត្រីក្នុងអំឡុងពេលកំណត់អត្តសញ្ញាណ ការសម្ភាស និងដំណើរការតុលាការ | ២.៨.ពិនិត្យលទ្ធភាពក្នុងការពង្រីកការប្រើប្រាស់នីតិវិធីស្តាប់ចម្លើយតាមបែបកុមារមេត្រី ជាពិសេសករណីពាក់ព័ន្ធនឹងកុមារ ឬអនីតិជន | |

| យុទ្ធសាស្ត្រទី ៣៖ ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃកិច្ចការពារជនរងគ្រោះ | | |
|---|---|---|
| ៣.ក ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានកំណត់អត្តសញ្ញាណប្រកបដោយប្រសិទ្ធភាព | ៣.១. ពង្រឹងប្រសិទ្ធភាពការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្ដល់សេវាសមស្រប | ៥០. គោលការណ៍ណែនាំស្ដីពីបែបបទ និងនីតិវិធីក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្ដល់សេវាសមស្រប ត្រូវបានកែសម្រួល/ធ្វើបច្ចុប្បន្នភាព ប្រកាសឱ្យអនុវត្ត និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយអនុលោមតាមច្បាប់ជាតិ គោលការណ៍តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>៥១. ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានផ្ដល់សេវាសមស្របតាមស្ថានភាពជាក់ស្ដែង ទាន់ពេលវេលា ប្រកបដោយគុណភាព<br>៥២. សេវាត្រូវបានផ្ដល់ដល់ជនរងគ្រោះ ដោយមានការយកចិត្តទុកដាក់ ពិចារណាលើគោលការណ៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងឧត្តមប្រយោជន៍ជនរងគ្រោះ |
| ៣.ខ ប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ត្រូវបានបង្កើតឡើង និងអនុវត្ត | ៣.២. ជំរុញការរៀបចំ និងការអនុវត្តប្រព័ន្ធបញ្ជូនថ្នាក់ជាតិ | ៥៣. ប្រព័ន្ធបញ្ជូនថ្នាក់ជាតិត្រូវបានបង្កើត និងអនុវត្តដោយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព<br>៥៤. សេវានៅក្នុងដំណាក់កាលនីមួយៗនៃប្រព័ន្ធបញ្ជូនថ្នាក់ជាតិ ត្រូវបានផ្ដល់ដល់ជនរងគ្រោះ ដោយមានការយកចិត្តទុកដាក់ ពិចារណា លើគោលការណ៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងឧត្តមប្រយោជន៍ជនរងគ្រោះ |
| ៣.ឃ ប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះ និងការប្រមូលទិន្នន័យពាក់ព័ន្ធត្រូវបានពង្រឹង | ៣.៣. ពង្រឹងប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះ | ៥៥. ប្រព័ន្ធគ្រប់គ្រងករណីជនរងគ្រោះត្រូវបានបង្កើត និងអនុវត្តដោយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព<br>៥៦. ទិន្នន័យពាក់ព័ន្ធនឹងជនរងគ្រោះត្រូវបានកត់ត្រា ផ្ទុក ចែករំលែក និងរាយការណ៍ប្រកបដោយសុក្រឹតភាព សង្គតិភាព ទាន់ពេលវេលា ដល់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ដោយអនុលោមតាមគោលការណ៍គោរពសិទ្ធិឯកជនភាពរបស់ជនរងគ្រោះ |

| | | |
|---|---|---|
| ៤.គ អ្នកផ្ដល់សេវាក្នុងរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល បានពង្រឹងកិច្ចសហប្រតិបត្តិការ ដោយតម្កល់ឧត្តមប្រយោជន៍របស់ជនរងគ្រោះនៅគ្រប់ដំណាក់កាល | ៣.៤. ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្ដល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យកាន់តែប្រសើរ ដើម្បីលើកកម្ពស់កិច្ចការពារផ្លូវច្បាប់ និងសេវាចាំបាច់សមស្របតាមឧត្តមប្រយោជន៍ជនរងគ្រោះ គ្រប់ដំណាក់កាល។ | ៥៧. ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានសេវាសមស្របប្រកបដោយគុណភាព<br>៥៨. ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍<br>៥៩. លិខិតបទដ្ឋានពាក់ព័ន្ធនឹងការផ្ដល់នីតិសម្បទាដល់ជនរងគ្រោះ ត្រូវបានបង្កើត និងអនុវត្ត<br>៦០. កិច្ចសហប្រតិបត្តិការរវាងអ្នកផ្ដល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ត្រូវបានពង្រឹង |
| ៣.គ ស្ថាប័នបានកំណត់តួនាទីយ៉ាងច្បាស់លាស់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងយន្តការបញ្ជូនបន្ត | ៣.៥. ពង្រឹងប្រសិទ្ធភាពការអនុវត្តអភិក្រមផ្ដល់កិច្ចគាំពារ និងផ្ដល់សេវាជូនជនរងគ្រោះ តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលធ្វើសមាហរណកម្មដោយជោគជ័យ និងបិទករណីដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើក្រុមគោលដៅអាទិភាព មានជាអាទិ៍ កុមារ ស្ត្រី យុវវ័យ ក្រុមជនមានពិការភាព ជនដែលមានជំនឿសាសនា ជាតិពន្ធុ អត្តសញ្ញាណយេនឌ័រ និងភាសាដោយឡែក ជាដើម ដោយគ្មានការរើសអើង | ៦១. សមត្ថភាព ជំនាញ និងចំណេះដឹងរបស់មន្ត្រីសង្គមកិច្ច និងភាគីពាក់ព័ន្ធក្នុងការផ្ដល់សេវាត្រូវបានពង្រឹង<br>៦២. ប្រសិទ្ធភាពកិច្ចគាំពារ និងសេវាជូនជនរងគ្រោះត្រូវបានពង្រឹងបន្ថែមនៅគ្រប់ដំណាក់កាល<br>៦៣. សេវាសមស្របត្រូវបានផ្ដល់ដល់ជនរងគ្រោះប្រកបដោយបរិយាបន្នត្រឹមត្រូវដោយគ្មានការរើសអើង |
| ៣.ង ការស្ដារនីតិសម្បទាជនរងគ្រោះផ្ដោតលើចរិតលក្ខណៈ និងតម្រូវការរបស់បុគ្គល | ៣.៦. ពង្រឹងប្រសិទ្ធភាព និងគុណភាពការស្ដារនីតិសម្បទាជនរងគ្រោះដោយផ្ដោតការយកចិត្តទុកដាក់លើលក្ខណៈដោយឡែក ឬស្ថានភាពដោយឡែកៗពីគ្នា មានជាអាទិ៍ ទារក កុមារ ស្ត្រីវ័យក្មេង ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនចាស់ជរា កុមារ ជនមានពិការភាព ភាពខុសគ្នានៃយេនឌ័រ ជាដើម | ៦៤. ប្រសិទ្ធភាព និងគុណភាពនៃសេវាពាក់ព័ន្ធនឹងការស្ដារនីតិសម្បទាជនរងគ្រោះត្រូវបានពង្រឹងដោយមានការយកចិត្តទុកដាក់ ពិចារណា លើគោលការណ៍ពាក់ព័ន្ធនឹងសមភាពយេនឌ័រ ពិការភាព បរិយាបន្នសង្គម និងឧត្តមប្រយោជន៍ជនរងគ្រោះ<br>៦៥. ជនធ្លាប់រងគ្រោះ ត្រូវបានស្ដារនីតិសម្បទា រស់នៅប្រកបដោយសុវត្ថិភាព និងភាពរីករាយក្នុងគ្រួសារ និងសហគមន៍ |

| យុទ្ធសាស្ត្រទី ៤៖ ការពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា | | |
|---|---|---|
| ៤.យ កិច្ចព្រមព្រៀង ផែនការ និងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងមានប្រសិទ្ធភាព | ៤.១. រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រចាំឆ្នាំ និងពង្រឹងយន្តការ | ៦៦. ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ត្រូវបានរៀបចំ អនុវត្ត តាមដាន និងវាយតម្លៃ<br>៦៧. រចនាសម្ព័ន្ធ និងយន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវបានពង្រឹង និងកែលម្អ |
| ៤.យ កិច្ចព្រមព្រៀង ផែនការ និងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងមានប្រសិទ្ធភាព | ៤.២. ពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័នអង្គភាព និងអង្គការដៃគូអនុវត្ត | ៦៨. របៀបរបបការងារត្រូវបានពង្រឹង<br>៦៩. កិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំត្រូវបានធ្វើឡើងយ៉ាងទៀងទាត់<br>៧០. របាយការណ៍កិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំត្រូវបានផលិត<br>៧១. មន្ត្រីលេខាធិការដ្ឋាន គរបជ/គខបជ ទទួលបានការបណ្តុះបណ្តាល<br>៧២. មន្ត្រីនគរបាលយុត្តិធម៌ទទួលបានការបណ្តុះបណ្តាលជំនាញក្បួននីតិវិធីប្រតិបត្តិពាក់ព័ន្ធ |
| ៤.យ កិច្ចព្រមព្រៀង ផែនការ និងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងមានប្រសិទ្ធភាព | ៤.៣. ប្រមូល ចងក្រង និងកសាងប្រព័ន្ធទិន្នន័យ ដើម្បីជាមូលដ្ឋាននៃការវិភាគលើកទិសដៅអនុវត្តផ្សព្វផ្សាយ និងផ្លាស់ប្តូរជាមួយប្រទេសពាក់ព័ន្ធ | ៧៣. យន្តការក្នុងការប្រមូលចងក្រង គ្រប់គ្រង និងផ្លាស់ប្តូរទិន្នន័យ ត្រូវបានបង្កើត និងដំណើរការជាប្រព័ន្ធ<br>៧៤. កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរ និងសមត្ថកិច្ចកម្ពុជា ជាមួយបណ្តាប្រទេសពាក់ព័ន្ធត្រូវបានពង្រឹង និងបង្កើនប្រសិទ្ធភាព<br>៧៥. របាយការណ៍បង្ក្រាបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានផលិត<br>៧៦. របាយការណ៍ជនរងគ្រោះដោយអំពើជួញដូរមនុស្សប្រចាំ ខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានផលិត និងផ្សព្វផ្សាយ |
| ៤.យ កិច្ចព្រមព្រៀង ផែនការ និងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិត្រូវបានពង្រឹង និងមានប្រសិទ្ធភាព | ៤.៤. កសាងបទដ្ឋានគតិយុត្ត និងអនុស្សរណៈ កិច្ចព្រមព្រៀង និងស្តង់ដារនីតិវិធីប្រតិបត្តិនានាជាមួយប្រទេសពាក់ព័ន្ធ | ៧៧. បទដ្ឋានគតិយុត្ត ស្តង់ដារនីតិវិធីប្រតិបត្តិ និងកិច្ចព្រមព្រៀងអនុវត្តសកម្មភាពស្តីពីការបង្ការទប់ស្កាត់ អនុវត្តច្បាប់ និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានបង្កើត និងចុះហត្ថលេខាជាមួយប្រទេសពាក់ព័ន្ធ |

| | | |
|---|---|---|
| ៤.ឃ កិច្ចព្រមព្រៀង ផែនការ និងរចនាសម្ព័ន្ធនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិត្រូវបានពង្រឹង និងមានប្រសិទ្ធភាព | ៤.៥. ពង្រឹងកិច្ចសហប្រតិបត្តិការ និងសមត្ថភាពជំនាញ ជាមួយប្រទេសពាក់ព័ន្ធ និងជាអន្តរជាតិ ដើម្បីបង្ការទប់ស្កាត់បង្ក្រាបអំពើជួញដូរមនុស្សឆ្លងដែន ផ្តល់អន្តរាគមន៍ជួយជនរងគ្រោះ និងជំរុញការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី | ៧៨. អនុស្សរណៈ កិច្ចព្រមព្រៀងត្រូវបានអនុវត្ត<br>៧៩. បញ្ហាប្រឈមក្នុងការអនុវត្តត្រូវបានរកឃើញ និងដោះស្រាយ<br>៨០. កិច្ចប្រជុំទ្វេភាគី ពហុភាគី ត្រូវបានរៀបចំទៀងទាត់ |
| ៤.ង ច្បាប់ និងគោលនយោបាយត្រូវបានកែសម្រួល និង/ឬបង្កើតដើម្បីដោះស្រាយនិន្នាការអំពើជួញដូរមនុស្ស ដែលកំពុងកើតមាន | ៤.៦. ធ្វើវិសោធនកម្ម ឬ/និងរៀបចំសេចក្តីព្រាងច្បាប់ និងគោលនយោបាយជាតិឆ្លើយតបនឹងបញ្ហាថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស | ៨១. ឯកសារបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវបានកែលម្អក្នុងករណីចាំបាច់សម្រាប់ជាជំនួយដល់ការអនុវត្ត<br>៨២. ច្បាប់ និងគោលនយោបាយថ្មីៗ ត្រូវបានបង្កើតឡើងសម្រាប់អនុវត្ត ឆ្លើយតបទៅតាមតម្រូវការចាំបាច់ |

## ឧបសម្ព័ន្ធ ខ៖ សូចនាករផលសម្រេច

ឧបសម្ព័ន្ធនេះផ្តល់នូវបញ្ជីសូចនាករផលសម្រេចដែលត្រូវប្រមូលដោយស្ថាប័នពាក់ព័ន្ធ ក្រសួង អង្គភាព និង/ឬក្រុមការងារ។ រយៈពេលរាយការណ៍ គឺស្របជាមួយនឹងពេលវេលារាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដែលមានស្រាប់។ ការប្រមូលទិន្នន័យនៃផលសម្រេចនឹងចាប់ផ្តើមនៅឆ្នាំ ២០២៥ សម្រាប់សកម្មភាពប្រឆាំងការជួញដូរមនុស្សដែលបានអនុវត្តក្នុងឆ្នាំ ២០២៤។

| លេខយោង | លេខយុទ្ធសាស្ត្រ | សូចនាករផលសម្រេច |
|---|---|---|
| ១ | ១ | ចំនួនយុទ្ធនាការលើកកម្ពស់ការយល់ដឹងសាធារណៈអំពីការប្រឆាំងអំពើជួញដូរមនុស្ស ដែលបែងចែកប្រភេទយុទ្ធនាការ និងក្រុមគោលដៅ ដូចជាអាយុ យេនឌ័រ ជនមានពិការភាព ឬក្រុមដែលងាយរងគ្រោះផ្សេងទៀត |
| ២ | ១, ២ | ចំនួន និងព័ត៌មានលម្អិតនៃការស្រាវជ្រាវ/ការសិក្សា ដែលបានចាប់ផ្តើម បញ្ចប់ និងកំពុងបន្តក្នុងអំឡុងពេលរបាយការណ៍ |
| ៣ | ១ | ចំនួន និងព័ត៌មានលម្អិតនៃសម្ភារនិង/ឬឧបករណ៍បញ្ជូនសារអំពើជួញដូរមនុស្ស ដែលបានបង្កើត |
| ៤ | ១ | ចំនួនអធិការកិច្ចដែលបានធ្វើលើទីតាំងគោលដៅសង្ស័យ |
| ៥ | ១ | ចំនួនភាគីពាក់ព័ន្ធមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងសកម្មភាពបង្ការទប់ស្កាត់នានា ដែលបែងចែកតាមប្រភេទអង្គការ (អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សាលារៀន ដៃគូអន្តរជាតិ) និងតាមប្រភេទវិស័យ (អប់រំ ទេសចរណ៍ ការផ្តល់ការងារ កសិកម្ម ឧស្សាហកម្ម សិប្បកម្ម សុខាភិបាល មីក្រូហិរញ្ញវត្ថុ ធនាគារ ដឹកជញ្ជូន ប្រៃសណីយ៍ និងទូរគមនាគមន៍) |
| ៦ | ១ | ចំនួនច្បាប់ គោលនយោបាយ នីតិវិធី សេចក្តីណែនាំ ឯកសារច្បាប់ និងរបាយការណ៍នានាទាក់ទងនឹងអំពើជួញដូរមនុស្ស ដែលបានផ្សព្វផ្សាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ៧ | ១, ២, ៣ និង ៤ | ចំនួនវគ្គបណ្តុះបណ្តាលដែលបានធ្វើឡើង និងចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាលសរុប ដែលបែងចែកតាមយេនឌ័រ |
| ៨ | ២ | ចំនួនករណីអំពើជួញដូរមនុស្សដែលត្រូវបានបែងចែកតាមប្រភេទនៃការជួញដូរ និងចំនួនដែលពាក់ព័ន្ធនឹងកុមារ |
| ៩ | ២ | ចំនួនករណីអំពើជួញដូរមនុស្សដែលត្រូវបានស៊ើបអង្កេតសម្រាប់ការកាត់ទោស |
| ១០ | ២ | ចំនួនមន្ត្រីអនុវត្តច្បាប់ដែលត្រូវបានបណ្តុះបណ្តាល ដែលបែងចែកតាមយេនឌ័រ |
| ១១ | ២ | ចំនួននៃការបណ្តុះបណ្តាល ឬសិក្ខាសាលាស្តីពីអភិក្រមដែលយកចិត្តទុកដាក់ដល់យេនឌ័រ និងជនរងគ្រោះជាមជ្ឈមណ្ឌល |

| លេខយោង | លេខយុទ្ធសាស្ត្រ | សូចនាករផលសម្រេច |
|---|---|---|
| ១២ | ៣ | ចំនួនជនរងគ្រោះដែលត្រូវបានកំណត់ បែងចែកតាមសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (អាយុ យេនឌ័រ ពិការភាព និងក្រុមងាយរងគ្រោះ) |
| ១៣ | ៣ | ចំនួនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រូវបានផ្តល់សេវាគាំទ្រ |
| ១៤ | ៣ | ចំនួនជនរងគ្រោះអំពើជួញដូរមនុស្ស ដែលត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍របស់ពួកគេ |
| ១៥ | ៣ | ចំនួន និងភាគរយនៃជនរងគ្រោះអំពើជួញដូរមនុស្ស ដែលត្រូវបានដាក់នៅកន្លែងស្នាក់នៅដែលសមស្របនឹងតម្រូវការរបស់ពួកគេ ដែលបែងចែកតាមប្រភេទកន្លែងស្នាក់នៅ (ការថែទាំតាមគ្រួសារ ឬការស្នាក់នៅជាមួយសាច់ញាតិ ការថែទាំជាកូនចិញ្ចឹម ផ្ទះជាក្រុមតូចៗ ទីជម្រក ឬកន្លែងសុខុមាលភាព) |
| ១៦ | ៤ | ចំនួនកិច្ចប្រជុំដែលបានធ្វើឡើង និងចំនួនអ្នកចូលរួមសរុប ដែលបែងចែកតាមយេនឌ័រ |
| ១៧ | ៤ | ចំនួនច្បាប់ បទដ្ឋានគតិយុត្ត នីតិវិធី គោលនយោបាយ និងកិច្ចព្រមព្រៀងដែលត្រូវបានពិនិត្យ បង្កើត កែសម្រួល ឬបញ្ចប់ក្នុងអំឡុងពេលរាយការណ៍ |
| ១៨ | ៤ | ចំនួនអ្នកចូលរួមព្រឹត្តិការណ៍ដែលមកពីវិស័យឯកជន សង្គមស៊ីវិល និងតំណាងជនរងគ្រោះ រួមទាំងក្រុមដែលជួបការលំបាក |

## ឧបសម្ព័ន្ធ ៨៖ វិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ

ខាងក្រោមនេះ គឺជាវិធីសាស្ត្រប្រមូលទិន្នន័យក្នុងលក្ខណៈចង្អុលបង្ហាញ។ នឹងមានឯកសារកញ្ចប់ឧបករណ៍ដោយឡែកមួយសម្រាប់ការប្រមូលទិន្នន័យ និងការរាយការណ៍។ សៀវភៅណែនាំនៃកញ្ចប់ឧបករណ៍ MEL នឹងត្រូវបានប្រើក្នុងការបណ្តុះបណ្តាលអ្នកប្រើ និងអ្នកអនុវត្តក្របខ័ណ្ឌ MEL នេះ។

| អភិក្រមប្រមូលទិន្នន័យ | ភាពញឹកញាប់ | សូចនាករពាក់ព័ន្ធ |
|---|---|---|
| តាមដានសកម្មភាពទាំងឡាយដែលត្រូវបានរាយការណ៍ ដោយផ្អែកលើផែនការសកម្មភាព | ប្រមូលជាប្រចាំ និងចងក្រងប្រចាំខែ | ▪ សូចនាករផលសម្រេចទាំងអស់ |
| ព័ត៌មានលម្អិតអំពីអ្នកចូលរួមដែលស្រង់ពីការតាមដានសកម្មភាពទាំងឡាយដែលត្រូវបានរាយការណ៍ ដោយផ្អែកលើផែនការសកម្មភាព | ប្រមូលជាប្រចាំ និងចងក្រងប្រចាំខែ | ▪ ចំនួនអ្នកចូលរួម<br>▪ ចំនួនអ្នកចូលរួមព្រឹត្តិការណ៍ដែលមកពីវិស័យឯកជន សង្គមស៊ីវិល និងតំណាងជនរងគ្រោះ/ជនធ្លាប់រងគ្រោះ រួមទាំងក្រុមជួបការលំបាក<br>▪ ចំនួនមន្ត្រីអនុវត្តច្បាប់ដែលត្រូវបានបណ្តុះបណ្តាល ដែលបែងចែកតាមយេនឌ័រ |
| ទម្រង់ផ្តល់មតិកែលម្អ | ប្រមូលជាប្រចាំ និងចងក្រងប្រចាំខែ | ▪ វិស័យឯកជនចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស<br>▪ កិច្ចសហប្រតិបត្តិការរវាងស្ថាប័នផ្តល់សេវារាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលត្រូវបានពង្រឹង<br>▪ អង្គភាពពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានពង្រឹងការយល់ដឹងអំពីគោលនយោបាយទាក់ទងនឹងការជួញដូរមនុស្ស កលល្បិច ជនល្មើស និងផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងទម្រង់នៃការជួញដូរមនុស្ស |
| រឿងរ៉ាវអំពីការផ្លាស់ប្តូរ ឬករណីសិក្សា | ប្រចាំឆមាស និងប្រចាំឆ្នាំ | ▪ សូចនាករលទ្ធផលអាទិភាពទាំងអស់នៅក្នុងតារាងទី ២ |
| ការស្ទង់មតិតាមគោលដៅ | ប្រចាំឆ្នាំ | ▪ សូចនាករលទ្ធផលអាទិភាពទាំងអស់នៅក្នុងតារាងទី ២ |
| ប្រភពព័ត៌មានបន្ទាប់បន្សំ ឬប្រភពផ្សេងទៀត | ប្រចាំឆ្នាំ | ▪ សូចនាករផលសម្រេច និងសូចនាករលទ្ធផលពាក់ព័ន្ធ |

## ឧបសម្ព័ន្ធ ឃ៖ សេចក្ដីព្រាងលក្ខខណ្ឌយោងការងាររបស់មន្ត្រីទទួលបន្ទុកការងារ MEL

### សេចក្ដីផ្ដើម

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ជាយន្តការជាតិកម្ពុជាដើម្បីទប់ស្កាត់ និងលុបបំបាត់អំពើជួញដូរមនុស្ស។ គ.ជ.ប.ជ. មានកាតព្វកិច្ចដឹកនាំ សម្របសម្រួល ប្រមូលព័ត៌មាន វិភាគទិន្នន័យ និងផ្ដួចផ្ដើមការរៀបចំច្បាប់ គោលនយោបាយ និងផែនការ សម្រាប់ការអនុវត្តដោយមានការចូលរួមនូវកិច្ចខិតខំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយក្រសួង/ស្ថាប័នជាសមាជិកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ មានក្រសួងចំនួន ២២ និងអង្គភាពឯកទេសចំនួន ៥ ជាសមាជិក គ.ជ.ប.ជ. និងមានក្រុមការងារអន្តរក្រសួង-ស្ថាប័នចំនួន ៦។

នៅចុងឆ្នាំ ២០២៣ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. បានដឹកនាំការវាយតម្លៃផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០១៩-២០២៣។ របកគំហើញនិងអនុសាសន៍នៃការវាយតម្លៃ បានផ្ដល់ព័ត៌មានដល់ការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់ឆ្នាំ ២០២៤-២០២៨។

ការបង្កើតក្របខ័ណ្ឌតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) សម្រាប់ផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨ (ផែនការយុទ្ធសាស្ត្រជាតិ) នៃព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្ដើមក្នុងឆមាសទីពីរឆ្នាំ ២០២៤។ ក្របខ័ណ្ឌ MEL នេះ ផ្ដល់ជូនទាំងក្រសួង ស្ថាប័ន និងសមាជិកអង្គភាពឯកទេសនៃ គ.ជ.ប.ជ. និងគណៈកម្មាធិការរាជធានី/ខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ./គ.ខ.ប.ជ.) និងដៃគូ ក្នុងការតាមដាន វាយតម្លៃ និងរាយការណ៍អំពីការរំពឹងទុក លទ្ធផលគោលការណ៍ និងរួមចំណែកក្នុងការអនុវត្តសកម្មភាពដែលបានគ្រោងទុក។ ក្របខ័ណ្ឌ MEL បានចងក្រងជាឯកសារ និងពង្រឹកប្រព័ន្ធតាមដាន និងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រជាតិ (ជំពូក ឃ) ដោយផ្ដល់ព័ត៌មានលម្អិត និងការពិពណ៌នាបន្ថែមអំពីរបៀបដែលប្រព័ន្ធតាមដាននិងវាយតម្លៃនឹងត្រូវបានអនុវត្ត។

សូមស្នើឱ្យបង្កើតបណ្ដាញមន្ត្រីទទួលបន្ទុកការងារ MEL ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌ MEL និងគាំទ្រដល់សកម្មភាព MEL លើការងារប្រឆាំងអំពើជួញដូរមនុស្ស។

## គោលបំណង

គោលបំណងនៃការតែងតាំងមន្ត្រីទទួលបន្ទុកការងារ MEL មានដូចខាងក្រោមៈ

ក. បំពេញមុខងារជាចំណុចដំបូងនៃទំនាក់ទំនងសម្រាប់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. ទាក់ទងនឹងការងារតាមដាន និងរាយការណ៍អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទិន្នន័យទាក់ទងនឹងអំពើជួញដូរមនុស្ស

ខ. សម្របសម្រួល និងជួយសម្រួលការងារតាមដាន និងរាយការណ៍ជារួម នៅតាមក្រសួង ឬស្ថាប័នស្របតាមការអនុវត្តក្របខ័ណ្ឌ MEL នៃផែនការយុទ្ធសាស្ត្រជាតិ

គ. បង្កើតការផ្សារភ្ជាប់ និងការសម្របសម្រួលលើការងារតាមដាន និងរាយការណ៍នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. និងក្នុងចំណោមក្រសួង/ស្ថាប័នសមាជិក គ.ជ.ប.ជ.

ឃ. លើកកម្ពស់កិច្ចខិតខំក្នុងការជំរុញការងារ MEL និងក្នុងការអនុវត្តក្របខ័ណ្ឌ MEL។

## ការតែងតាំង

ការតែងតាំងមន្ត្រីទទួលបន្ទុកការងារ MEL អាចធ្វើឡើងតាមមុខតំណែងពិសេសមួយ ឬជាក្រុម/ក្រុមការងារ/អង្គភាពកំណត់មួយនៅក្នុងក្រសួង ឬស្ថាប័ន ជាពិសេស មន្ត្រីទាំងឡាយដែលទទួលបន្ទុករៀបចំ និងបូកសរុបទិន្នន័យ និងព័ត៌មាន។

## ការទទួលខុសត្រូវ

មន្ត្រីទទួលបន្ទុកការងារ MEL នឹងមានការទទួលខុសត្រូវដូចខាងក្រោមៈ

១. តំណាងឱ្យក្រសួង ឬស្ថាប័ននៅក្នុងបណ្តាញមន្ត្រីទទួលបន្ទុកការងារ MEL ដែលបានបង្កើតឡើង។

២. ចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានាទាក់ទងនឹងការងារ MEL ដែលរៀបចំដោយ គ.ជ.ប.ជ. និងព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទងនឹងការអនុវត្តក្របខ័ណ្ឌ MEL។

៣. សម្របសម្រួលការប្រមូលទិន្នន័យ និងការចងក្រងទិន្នន័យពាក់ព័ន្ធនៅតាមក្រសួង ឬស្ថាប័នដោយប្រើទម្រង់ប្រមូលទិន្នន័យដែលផ្តល់ដោយអគ្គលេខាធិការដ្ឋាន និង/ឬឧបករណ៍ប្រមូលទិន្នន័យពីក្របខ័ណ្ឌ MEL នេះ។ ចំណុចនេះ អាចរួមមានព័ត៌មាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីវឌ្ឍនភាពឆ្ពោះទៅការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ វឌ្ឍនភាពលើសកម្មភាពដែលបានគ្រោង

ទុកដែលមានចែងក្នុងផែនការសកម្មភាពប្រចាំឆ្នាំ មេរៀនដែលបានទទួល និងព័ត៌មានអំពីសូចនាករទិន្នផល និងសូចនាករលទ្ធផល។

៤. ជួយសម្រួល និងសម្របសម្រួលកិច្ចប្រជុំ ឬសិក្ខាសាលានៅតាមក្រសួង ឬស្ថាប័ន ដើម្បីពិនិត្យ និងឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃផែនការសកម្មភាពមានស្រាប់ និងរៀបចំផែនការសម្រាប់ផែនការសកម្មភាពបន្ទាប់។

៥. បំពេញទម្រង់របាយការណ៍ផ្សេងៗដែលផ្តល់ដោយអគ្គលេខាធិការដ្ឋាន និង/ឬទម្រង់របាយការណ៍ពីក្របខ័ណ្ឌ MEL។

៦. ធានាឱ្យបាននូវការដាក់របាយការណ៍ទាន់ពេលវេលាជូនអគ្គលេខាធិការដ្ឋាន និង/ឬក្រុមការងារអន្តរក្រសួង/ស្ថាប័នពាក់ព័ន្ធ ដូចដែលបានគូសបញ្ជាក់តាមពេលវេលាដែលបានព្រមព្រៀងនៃលក្ខខណ្ឌយោងការងារនេះ។

៧. ចូលរួមចំណែកដល់ការធ្វើរបាយការណ៍ប្រចាំឆ្នាំនៅថ្នាក់តំបន់ និងតាមការស្នើសុំរបស់អគ្គលេខាធិការដ្ឋាន។

៨. ជំរុញការតាមដាន និងការរាយការណ៍ទិន្នន័យទាក់ទងនឹងអំពើជួញដូរមនុស្ស និងកិច្ចខិតខំប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួង ឬស្ថាប័ន។

ខាងក្រោមនេះគឺជាការទទួលខុសត្រូវបន្ថែម (លេខ៩ ដល់លេខ១១) របស់មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួង/ស្ថាប័នដឹកនាំ៖

- ក្រសួងអប់រំ យុវជន និងកីឡា - ក្រុមការងារបង្ការទប់ស្កាត់
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា - ក្រុមការងារការពារជនរងគ្រោះ
- នគរបាលជាតិ - ក្រុមការងារអនុវត្តច្បាប់
- ក្រសួងយុត្តិធម៌ - ក្រុមការងារកិច្ចការយុត្តិធម៌
- ក្រសួងកិច្ចការនារី - ក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ - ក្រុមការងារទេសន្តរប្រវេសន៍

៩. ធានាឱ្យបាននូវការរៀបចំសិក្ខាសាលាពិនិត្យវាយតម្លៃ ឆ្លុះបញ្ចាំង និងរៀបចំផែនការប្រចាំឆ្នាំដើម្បីវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅរកលទ្ធផល និងរៀបចំផែនការសម្រាប់វដ្តថវិកាប្រចាំឆ្នាំបន្ទាប់។

១០. ធានាឱ្យបាននូវការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំនៅតាមស្ថាប័នសមាជិកក្រុមការងារស្របតាមផែនការយុទ្ធសាស្ត្រជាតិ។

១១. បូកសរុប និងដាក់របាយការណ៍វឌ្ឍនភាពរបស់ក្រុមការងារជូនអគ្គលេខាធិការដ្ឋាន អំពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ វឌ្ឍនភាពនៃលទ្ធផល និងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។

## យន្តការរាយការណ៍ និងពេលវេលា

ការបូកសរុប និងការបញ្ជូនទិន្នន័យនិងរបាយការណ៍ នឹងត្រូវធ្វើតាមនីតិវិធី និងពេលវេលាកំណត់ក្នុងតារាងខាងក្រោម។

| ឈ្មោះរបាយការណ៍ | ការពិពណ៌នាអំពីរបាយការណ៍ | របាយការណ៍ត្រូវបានរៀបចំដោយ | របាយការណ៍ត្រូវបានដាក់ជូន | ពេលដែលត្រូវដាក់របាយការណ៍ |
|---|---|---|---|---|
| របាយការណ៍សកម្មភាពប្រចាំខែ | របាយការណ៍បូកសរុបស្ដីពី សកម្មភាពលម្អិតដែលបានបញ្ចប់ និងកំពុងដំណើរការ | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រុមការងារបច្ចេកទេសនៃក្រសួងនិងស្ថាប័នទាំង ៦ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំខែ - រៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំខែ - រៀងរាល់ថ្ងៃទី ៥ នៃខែបន្ទាប់ |
| របាយការណ៍ផលសម្រេច | ទិន្នន័យ ឬព័ត៌មានទាក់ទងនឹងព័ត៌មានលម្អិតអំពីផលសម្រេច ឬលទ្ធផលនៃសកម្មភាពដែលបានអនុវត្ត ដែលត្រូវបានចងក្រងពីរបាយការណ៍សកម្មភាព | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័នទាំង ៦ និងក្រុមការងារ MEL នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំខែ - រៀងរាល់ថ្ងៃទី ១០ នៃខែបន្ទាប់ |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំខែ - រៀងរាល់ថ្ងៃទី ៥ នៃខែបន្ទាប់ |
| របាយការណ៍វឌ្ឍនភាពប្រចាំឆមាស | របាយការណ៍បូកសរុបវឌ្ឍនភាពអំពីផលសម្រេច និងលទ្ធផល រួមទាំងសេចក្ដីសង្ខេបអំពីក្របខ័ណ្ឌការងារ ACWC | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័នទាំង ៦ និងក្រុមការងារ MEL នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំឆមាស - រៀងរាល់ថ្ងៃទី ១០ នៃខែកក្កដា និងខែមករា |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំឆមាស - រៀងរាល់ថ្ងៃទី ១០ នៃខែកក្កដា និងខែមករា |

| ឈ្មោះរបាយការណ៍ | ការពិពណ៌នាអំពីរបាយការណ៍ | របាយការណ៍ត្រូវបានរៀបចំដោយ | របាយការណ៍ត្រូវបានដាក់ជូន | ពេលដែលត្រូវដាក់របាយការណ៍ |
|---|---|---|---|---|
| របាយការណ៍ប្រចាំឆ្នាំ | របាយការណ៍បូកសរុបវឌ្ឍនភាពប្រចាំឆ្នាំ ដែលចងក្រងចេញពីរបាយការណ៍ផលសម្រេច និងរបាយការណ៍វឌ្ឍនភាពប្រចាំឆមាស | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័នទាំង ៦ និងក្រុមការងារ MEL នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ប្រចាំឆ្នាំ - រៀងរាល់ខែកុម្ភៈ |
| | | មន្ត្រីទទួលបន្ទុកការងារ MEL នៃក្រសួងនិងស្ថាប័នអនុវត្ត | ក្រុមការងារបច្ចេកទេសអន្តរក្រសួង/ស្ថាប័ន | ប្រចាំឆ្នាំ - រៀងរាល់ថ្ងៃទី ៣១ ខែមករា នៃឆ្នាំបន្ទាប់ |

# ឧបសម្ព័ន្ធ ខ៖ សកម្មភាព MEL

ខាងក្រោមនេះគឺជាសកម្មភាពការងារ MEL ដែលបានស្នើឡើង ដើម្បីគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌ MEL នេះ និងដើម្បីសម្រេចបាននូវគោលបំណងនៃការងារតាមដាននិងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រជាតិ។

| សកម្មភាព MEL | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|
| បញ្ចប់ និងអនុម័តក្របខ័ណ្ឌ MEL | ត្រីមាសទី១<br>ត្រីមាសទី២ | | | |
| ផ្សព្វផ្សាយក្របខ័ណ្ឌ MEL ដែលបានអនុម័ត | ត្រីមាសទី៣<br>ត្រីមាសទី៤ | | | |
| តែងតាំងមន្ត្រីទទួលបន្ទុកការងារ MEL និងក្រុមការងារ MEL នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ. | ត្រីមាសទី៣ | | | |
| ការបណ្តុះបណ្តាលស្តីពីការងារតាមដាន និងរាយការណ៍សម្រាប់មន្ត្រីទទួលបន្ទុកការងារ MEL និងក្រុមការងារ MEL | ត្រីមាសទី៣<br>ត្រីមាសទី៤ | | | |
| ការកសាងសមត្ថភាពនៃមន្ត្រីទទួលបន្ទុកការងារ MEL និងក្រុមការងារ MEL | ត្រីមាសទី៣<br>ត្រីមាសទី៤ | ✓ | | |
| ការប្រមូលទិន្នន័យ និងការតាមដាន | ✓ | ✓ | ✓ | ✓ |
| របាយការណ៍ប្រចាំខែអំពីសកម្មភាព និងផលសម្រេច | ✓ | ✓ | ✓ | ✓ |
| របាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ |
| សិក្ខាសាលាពិនិត្យវាយតម្លៃ ឆ្លុះបញ្ចាំង និងរៀបចំផែនការ | ✓ | ✓ | ✓ | ✓ |
| រៀបចំ បញ្ចប់បង្ហើយ និងផ្សព្វផ្សាយផែនការសកម្មភាពប្រចាំឆ្នាំ | ✓ | ✓ | ✓ | ✓ |
| អនុវត្តសកម្មភាព/គម្រោងដើម្បីកែលម្អសង្គតិភាព និយមន័យ និងគុណភាពនៃទិន្នន័យ | ✓ | ✓ | | |
| អនុវត្តអភិក្រមប្រមូលទិន្នន័យ ឬប្រព័ន្ធប្រមូលទិន្នន័យដែលបានកែលម្អ | | | ✓ | ✓ |
| ការវាយតម្លៃពាក់កណ្តាលអាណត្តិ | | ✓ | | |
| ការវាយតម្លៃចុងអាណត្តិ | | | | ✓ |

## ឧបសម្ព័ន្ធ ចៈ ពាក្យគន្លឹះ និងនិយមន័យ

| | |
|---|---|
| សកម្មភាព | សកម្មភាពដែលបានធ្វើឡើង ឬការងារដែលបានបំពេញ ដែលតាមរយៈនោះ ធាតុចូលនានា ដូចជា មូលនិធិ ជំនួយបច្ចេកទេស និងប្រភេទធនធានផ្សេងទៀត ត្រូវបានកៀរគរដើម្បីសម្រេចបាននូវផលសម្រេចជាក់លាក់។ |
| ការសន្មត | សម្មតិកម្មអំពីកត្តា ឬហានិភ័យនានាដែលអាចប៉ះពាល់ដល់វឌ្ឍនភាព ឬជោគជ័យនៃយុទ្ធសាស្ត្រ កម្មវិធី គម្រោង ឬផែនការសកម្មភាពមួយ។ ការសន្មត ក៏អាចត្រូវបានយល់ផងដែរថាជាលក្ខខណ្ឌសម្មតិកម្មដែលពាក់ព័ន្ធនឹងសុពលភាពនៃការវាយតម្លៃ។ |
| ការសិក្សាបន្ទាត់មូលដ្ឋាន | ការវិភាគដែលពិពណ៌នាអំពីស្ថានភាពមុនពេលមានអន្តរាគមន៍អភិវឌ្ឍន៍ យុទ្ធសាស្ត្រ កម្មវិធី ឬផែនការសកម្មភាពមួយ ដែលធៀបនឹងស្ថានភាពនេះ វឌ្ឍនភាពអាចត្រូវបានគេវាយតម្លៃ ឬការប្រៀបធៀបអាចធ្វើបាន។ |
| គោលវង្វាស់ | ចំណុចយោង ឬស្តង់ដារ ដែលធៀបនឹងចំណុចយោង ឬស្តង់ដារនេះ ស្នាដៃការងារ ឬសមិទ្ធផលអាចត្រូវបានវាយតម្លៃ។ គោលវង្វាស់ សំដៅលើស្នាដៃការងារដែលសម្រេចបានកាលពីពេលថ្មីៗនេះ ដោយស្ថាប័នប្រហាក់ប្រហែលដទៃ ឬអ្វីដែលអាចសន្និដ្ឋានបានដោយសមហេតុផលថាសម្រេចបានក្នុងកាលៈទេសៈទាំងនេះ។ |
| អ្នកទទួលផល | បុគ្គល ក្រុម ឬស្ថាប័នមួយ ទោះបីគឺជា ឬមិនមែនជាគោលដៅក្តី ដែលទទួលផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោល ពីការអនុវត្តផែនការសកម្មភាព ឬផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>សូមមើលផងដែរ *អ្នកចូលរួមអនុវត្ត (reach)* និង *ក្រុមគោលដៅ*។ |
| សមត្ថភាព | សមត្ថភាពរបស់មនុស្ស ស្ថាប័ន និងសង្គមទាំងមូលក្នុងការគ្រប់គ្រងកិច្ចការរបស់ពួកគេប្រកបដោយជោគជ័យ។ |
| ការអភិវឌ្ឍសមត្ថភាព | កិច្ចដំណើរការមួយ ដែលនៅក្នុងនោះ មនុស្ស ស្ថាប័ន និងសង្គមទាំងមូលបញ្ចេញ ពង្រឹង បង្កើត សម្របខ្លួន និងរក្សាសមត្ថភាពតាមពេលវេលា។ |
| ការពង្រឹងសមត្ថភាព | កិច្ចដំណើរការមួយ ដែលសំដៅកែលម្អលទ្ធភាពរបស់បុគ្គល ក្រុម ស្ថាប័ន បណ្តាញ ឬប្រព័ន្ធមួយ ដើម្បីលើកកម្ពស់ ឬអភិវឌ្ឍចំណេះដឹង ជំនាញ ឥរិយាបថ ប្រព័ន្ធ និងរចនាសម្ព័ន្ធដែលចាំបាច់ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព និងគ្រប់គ្រងកិច្ចការរបស់ពួកគេប្រកបដោយជោគជ័យ។ |
| អង្គការសង្គមស៊ីវិល | អង្គការ ឬស្ថាប័នមួយនៅក្រៅរដ្ឋាភិបាល ដែលតំណាងឱ្យសហគមន៍ និងផលប្រយោជន៍របស់ពួកគេ។ នៅក្នុងបរិបទនៃការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មពាក់ព័ន្ធ |

អង្គការសង្គមស៊ីវិលរួមមានអ្នកដែលផ្តល់សេវាសុខុមាលភាពសង្គមដល់ជនរងគ្រោះដោយការជួញដូរមនុស្ស តំណាងឱ្យពលករទេសន្តរប្រវេសន៍ និង/ឬអ្នកតស៊ូមតិដើម្បីសិទ្ធិមនុស្ស សមភាពយេនឌ័រ និងទម្រង់ផ្សេងទៀតនៃបរិយាបន្ន។

**ឧបករណ៍ប្រមូលទិន្នន័យ** វិធីសាស្ត្រមួយដែលត្រូវបានប្រើដើម្បីកំណត់ប្រភពព័ត៌មាន និងប្រមូលព័ត៌មានក្នុងពេលតាមដាន ឬវាយតម្លៃ។ ឧទាហរណ៍ រួមមានការស្ទង់មតិក្រៅផ្លូវការ និងផ្លូវការ ការសង្កេតដោយផ្ទាល់ និងដោយមានការចូលរួម ការសម្ភាសសហគមន៍ ក្រុមអ្នកផ្តល់ព័ត៌មាន មតិអ្នកជំនាញ ករណីសិក្សា និងការសិក្សាឯកសារ។

**ប្រសិទ្ធភាព** ទាក់ទងទៅនឹងកម្រិតដែលលទ្ធផលភ្លាមៗ និងលទ្ធផលរយៈពេលមធ្យមត្រូវបានសម្រេច និងផ្តោតលើទំនាក់ទំនងរវាងផលសម្រេច និងលទ្ធផល។ លទ្ធផលរួមមានផលវិជ្ជមាន អវិជ្ជមាន ដោយចេតនា និងដោយអចេតនា ដែលផលិតដោយផ្ទាល់ ឬដោយប្រយោល តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ប្រសិទ្ធភាព គឺជាកម្រិត ដែលនៅក្នុងនោះ យុទ្ធសាស្ត្រ ឬគោលបំណងនៃផែនការសកម្មភាពត្រូវបានសម្រេច ឬរំពឹងថានឹងសម្រេចបាន ដោយគិតគូរដល់សារៈសំខាន់ពាក់ព័ន្ធរបស់វា។ ក៏ត្រូវបានប្រើផងដែរជារង្វាស់រួមនៃ (ឬការវិនិច្ឆ័យអំពី) គុណវុឌ្ឍិ ឬតម្លៃនៃសកម្មភាពមួយ ពោលគឺ កម្រិត ដែលនៅក្នុងនោះ អន្តរាគមន៍សម្រេចបាន ឬត្រូវបានរំពឹងថានឹងសម្រេចបានគោលដៅពាក់ព័ន្ធសំខាន់ៗរបស់វាប្រកបដោយប្រសិទ្ធផល ប្រកបដោយនិរន្តរភាព និងដោយមានផលប៉ះពាល់វិជ្ជមានលើការអភិវឌ្ឍស្ថាប័ន។

**ប្រសិទ្ធផល** ផ្តោតលើរបៀបដែលធាតុចូល (ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងឧបករណ៍) ត្រូវបានបំប្លែងក្នុងលក្ខណៈសេដ្ឋកិច្ចនិងពេលវេលា ទៅជាផលសម្រេចក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់។

ប្រសិទ្ធផល គឺជារង្វាស់នៃរបៀបដែលធនធាន/ធាតុចូល (មូលនិធិ ជំនាញ ពេលវេលា។ល។) ត្រូវបានបំប្លែងក្នុងលក្ខណៈសេដ្ឋកិច្ច ទៅជាលទ្ធផល ឬផលសម្រេច។

**ការវាយតម្លៃ** ការវាយតម្លៃជាប្រព័ន្ធ និងមិនលម្អៀងលើគម្រោង កម្មវិធី ឬគោលនយោបាយដែលបានគ្រោង កំពុងដំណើរការ ឬដែលបានបញ្ចប់ ការរៀបចំ ការអនុវត្ត និងលទ្ធផលរបស់វា។ គោលបំណង គឺសំដៅកំណត់ភាពសមស្រប និងការបំពេញគោលបំណង ប្រសិទ្ធផលអភិវឌ្ឍន៍ ប្រសិទ្ធភាព ផលប៉ះពាល់ និងនិរន្តរភាព។ ការវាយតម្លៃ គួរផ្តល់

ព័ត៌មានដែលគួរឱ្យទុកចិត្ត និងមានប្រយោជន៍ ដែលអនុញ្ញាតឱ្យមានការដាក់បញ្ចូល មេរៀនដែលបានទទួលទៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ទាំងអ្នកទទួលជំនួយ និងម្ចាស់ជំនួយ។ ការវាយតម្លៃ ក៏សំដៅផងដែរលើដំណើរការនៃការកំណត់គុណតម្លៃ ឬសារៈសំខាន់នៃសកម្មភាព គោលនយោបាយ ឬកម្មវិធី។ សូមមើលផងដែរ *ការពិនិត្យមើលឡើងវិញ*។

**យេនឌ័រ** សំដៅលើតួនាទី អាកប្បកិរិយា សកម្មភាព និងគុណលក្ខណៈ ដែល នៅពេលណាមួយ សង្គមចាត់ទុកថាសមរម្យសម្រាប់បុរស និងស្ត្រី។ បន្ថែមលើលក្ខណៈសង្គម និងឱកាសដែលទាក់ទងនឹងភាពជាបុរស និងស្ត្រី និងទំនាក់ទំនងរវាងស្ត្រី និងបុរស និងកុមារី និងកុមារ យេនឌ័រក៏សំដៅទៅលើទំនាក់ទំនងរវាងស្ត្រី និងបុរសផងដែរ។ គុណលក្ខណៈ ឱកាស និងទំនាក់ទំនងទាំងនេះ ត្រូវបានកសាងឡើងក្នុងសង្គម ហើយត្រូវបានសិក្សាតាមរយៈដំណើរការសង្គមភាវូបនីយកម្ម។ ចំណុចទាំងនេះ គឺមានលក្ខណៈជាក់លាក់តាមបរិបទ និងពេលវេលា និងអាចផ្លាស់ប្តូរបាន។ យេនឌ័រកំណត់នូវអ្វីដែលត្រូវបានរំពឹងទុក ត្រូវបានអនុញ្ញាត និងត្រូវបានផ្តល់តម្លៃចំពោះស្ត្រី ឬបុរសក្នុងបរិបទដោយឡែកមួយ។

នៅក្នុងសង្គមភាគច្រើន គេឃើញមានភាពខុសគ្នា និងវិសមភាពរវាងស្ត្រី និងបុរសក្នុងការទទួលខុសត្រូវដែលត្រូវបានកំណត់ សកម្មភាពដែលត្រូវបានអនុវត្ត ការទទួលបាន និងការគ្រប់គ្រងលើធនធាន ព្រមទាំងឱកាសធ្វើការសម្រេចចិត្ត។ យេនឌ័រ គឺគ្រាន់តែជាផ្នែកមួយប៉ុណ្ណោះនៃបរិបទសង្គមវប្បធម៌ទូលាយ ទន្ទឹមគ្នានឹងលក្ខណៈវិនិច្ឆ័យសំខាន់ៗផ្សេងទៀតសម្រាប់ការវិភាគសង្គមវប្បធម៌ រួមមានកម្រិតភាពក្រីក្រ ជាតិពន្ធុ ពិការភាព ទំនោរផ្លូវភេទ អាយុ និងភូមិសាស្ត្រ។

**ការវិភាគយេនឌ័រ** ការសិក្សាយ៉ាងមធ្យ័តអំពីរបៀបដែលភាពខុសគ្នានៃតួនាទីយេនឌ័រ សកម្មភាព តម្រូវការ ឱកាស និងសិទ្ធិ/សិទ្ធិទទួលបាន ប៉ះពាល់ដល់បុរស ស្ត្រី កុមារី និងកុមារក្នុងស្ថានភាព ឬបរិបទមួយចំនួន។ ការវិភាគយេនឌ័រ ពិនិត្យមើលទំនាក់ទំនងរវាងស្ត្រី និងបុរស និងការទទួលបាន និងការគ្រប់គ្រងលើធនធានរបស់ពួកគេ និងឧបសគ្គដែលពួកគេជួបប្រទះ ធៀបនឹងស្ត្រីនិងបុរស។

**សមភាពយេនឌ័រ** សិទ្ធិ ការទទួលខុសត្រូវ និងឱកាសស្មើគ្នារបស់ស្ត្រី និងបុរស និងកុមារី និងកុមារ។ សមភាព មិនមែនមានន័យថាស្ត្រី និងបុរសនឹងក្លាយជាមនុស្សដូចគ្នាទេ ប៉ុន្តែសិទ្ធិ ការទទួលខុសត្រូវ និងឱកាសរបស់ស្ត្រី និងបុរស នឹងមិនអាស្រ័យលើថាតើពួកគេកើតមកជាបុរស ឬស្ត្រីនោះទេ។ សមភាពយេនឌ័របង្កប់ន័យថាផលប្រយោជន៍ តម្រូវការ និង

អាទិភាពរបស់ស្ត្រី និងបុរស ត្រូវបានយកមកពិចារណា ដោយទទួលស្គាល់ពិពិធភាពនៃក្រុមស្ត្រី និងបុរសផ្សេងៗគ្នា។ សមភាពយេនឌ័រ មិនមែនជាបញ្ហារបស់ស្ត្រីទេ ប៉ុន្តែគប្បីយកចិត្តទុកដាក់ និងមានការចូលរួមយ៉ាងពេញលេញពីបុរស ក៏ដូចជាស្ត្រី។ សមភាពរវាងស្ត្រី និងបុរសត្រូវបានគេមើលឃើញថាជាបញ្ហាសិទ្ធិមនុស្ស និងគឺជាបុព្វលក្ខខណ្ឌ និងជាសូចនាករនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពដែលមានមនុស្សជាមជ្ឈមណ្ឌល។

**ដែលឆ្លើយតបទៅនឹងយេនឌ័រ**
ទទួលស្គាល់ថាវិសមភាពយេនឌ័រ និងអតុល្យភាពអំណាច ប៉ះពាល់ដល់ជីវិតរបស់បុគ្គល និងសហគមន៍ ហើយគោលនយោបាយ និងការអនុវត្តគួរតែត្រូវបានរៀបចំឡើងដើម្បីដោះស្រាយវិសមភាពទាំងនេះ និងលើកកម្ពស់សមភាពយេនឌ័រ។ (ប្រភព៖ UN ESCAP, ២០១៤)។

**ដែលយកចិត្តទុកដាក់ដល់យេនឌ័រ**
ទទួលស្គាល់ភាពខុសគ្នារវាងបទពិសោធន៍ តម្រូវការ និងអាទិភាពរបស់ស្ត្រី និងបុរស ដោយមានគោលដៅកាត់បន្ថយវិសមភាពយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រ។ (ប្រភព៖ UN Women, ២០១៥)។

**គោលដៅ (goal)**
គោលបំណងលំដាប់ខ្ពស់ ដែលអន្តរាគមន៍អភិវឌ្ឍន៍មានបំណងចូលរួមចំណែក។

**ការអនុវត្តល្អ (good practice)**
គឺជាឧទាហរណ៍នៃគោលការណ៍ណែនាំ នីតិវិធី ស្តង់ដារ ឬគំនិតដែលត្រូវបានគេដឹងថាបង្កើតលទ្ធផលល្អប្រសិនបើគេធ្វើតាម ហើយក៏អាចពិពណ៌នាផងដែរអំពីរបៀបអនុវត្តកិច្ចការ ដំណើរការ ឬអភិក្រមមួយដើម្បីទទួលបានលទ្ធផលល្អ។ ការអនុវត្តល្អត្រូវបានចែករំលែកដើម្បីជាព័ត៌មាន ការរៀនសូត្រដកពិសោធន៍ និងការណែនាំ ពោលគឺ មិនត្រូវបានកំណត់ឲ្យអនុវត្ត ឬជាកាតព្វកិច្ចទេ។

**ផលប៉ះពាល់**
ផលចម្បងនិងបន្ទាប់បន្សំវិជ្ជមាននិងអវិជ្ជមានរយៈពេលវែង ដែលត្រូវបានផលិតដោយអន្តរាគមន៍អភិវឌ្ឍន៍ ដោយផ្ទាល់ ឬដោយប្រយោល ដោយចេតនា ឬដោយអចេតនា។

**សូចនាករ**
កត្តាឬអថេរបែបបរិមាណ ឬគុណភាព ដែលផ្តល់មធ្យោបាយសាមញ្ញ និងអាចទុកចិត្តបានមួយ ក្នុងការវាស់វែងសមិទ្ធផល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលភ្ជាប់ទៅនឹងអន្តរាគមន៍មួយ ឬដើម្បីជួយវាយតម្លៃស្នាដៃការងារ ឬវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និង/ឬផែនការសកម្មភាពប្រចាំឆ្នាំ។

**ធាតុចូល**
ធនធានហិរញ្ញវត្ថុ មនុស្ស សម្ភារៈ និងបញ្ញាដែលត្រូវបានប្រើសម្រាប់អន្តរាគមន៍អភិវឌ្ឍន៍មួយ ឬក្នុងអំឡុងពេលអនុវត្តសកម្មភាពក្រោមផែនការយុទ្ធសាស្ត្រជាតិ ឬផែនការសកម្មភាពប្រចាំឆ្នាំ។

| | |
|---|---|
| លទ្ធផលរយៈពេលមធ្យម | ផលប៉ះពាល់រយៈពេលខ្លី និងមធ្យមនៃផលសម្រេចនៃផែនការសកម្មភាពប្រចាំឆ្នាំ ឬផលប៉ះពាល់នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ជាឧទាហរណ៍ ផលប៉ះពាល់រយៈពេលខ្លី រួមមានការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ និងជំនាញរបស់ដៃគូ ឬអ្នកទទួលផល ខណៈដែល ឥទ្ធិពលរយៈពេលមធ្យមជារឿយៗ ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអាកប្បកិរិយា ការអនុវត្ត និងការសម្រេចចិត្ត។ លទ្ធផលរយៈពេលមធ្យម គឺជាសមិទ្ធផលដែលមានគុណភាពខ្ពស់ ពេលគឺអាទិភាពសម្រេចបានក្នុងរយៈពេលពី ២ ទៅ ៥ ឆ្នាំ។ លទ្ធផលរយៈពេលមធ្យមនៅក្នុងក្របខ័ណ្ឌ MEL ត្រូវបានចាត់ទុកថាជាបុព្វលក្ខខណ្ឌដើម្បីគាំទ្រ ឬជំរុញការសម្រេចបាននូវលទ្ធផលចុងក្រោយនៅពេលបញ្ចប់ផែនការយុទ្ធសាស្ត្រជាតិក្នុងឆ្នាំ ២០២៨។ |
| មេរៀនដែលបានទទួល | ទូទៅនីយកម្មដោយផ្អែកលើបទពិសោធន៍ MEL ជាមួយនឹងសកម្មភាព គម្រោង កម្មវិធី ឬគោលនយោបាយ ដែលដកស្រង់ពីកាលៈទេសៈជាក់លាក់ទៅនឹងស្ថានភាពទូលាយ។ ជាញឹកញាប់ មេរៀនបង្ហាញពីចំណុចខ្លាំង ឬចំណុចខ្សោយក្នុងការរៀបចំ ការរចនា និងការអនុវត្ត ដែលមានឥទ្ធិពលលើស្នាដៃការងារ លទ្ធផល និងផលប៉ះពាល់។ |
| ការតាមដាន | មុខងារជាបន្តដែលប្រើការប្រមូលទិន្នន័យជាប្រព័ន្ធ លើសូចនាករដែលបានកំណត់ ដើម្បីផ្តល់ជូនអ្នកគ្រប់គ្រងនិងភាគីពាក់ព័ន្ធសំខាន់ៗនៃអន្តរាគមន៍អភិវឌ្ឍន៍ដែលកំពុងដំណើរការ ជាមួយនឹងការចង្អុលបង្ហាញអំពីវិសាលភាពនៃវឌ្ឍនភាព និងការសម្រេចបាននូវគោលបំណង និងវឌ្ឍនភាពនៃការប្រើប្រាស់មូលនិធិដែលបានវិភាជន៍។ |
| លទ្ធផល (outcome) | ផលរយៈពេលខ្លី និងរយៈពេលមធ្យមដែលទំនងជាសម្រេចបាន ឬដែលសម្រេចបាននៃផលសម្រេច។ |
| ផលសម្រេច (output) | ផលិតផល និងសេវាកម្មរួបន្តែដែលទទួលបានតាមរយៈការអនុវត្តផែនការសកម្មភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ ២០២៤-២០២៨។ លទ្ធផលដែលបានពិពណ៌នានៅក្នុងក្របខ័ណ្ឌ MEL រួមមានលទ្ធផលដែលឆ្លើយតបទៅនឹងសូចនាករនៅក្នុងផែនការយុទ្ធសាស្ត្រជាតិ ដែលបែងចែកជាសូចនាករសម្រាប់ផែនការសកម្មភាពប្រចាំឆ្នាំ។ |
| ដៃគូ | បុគ្គល ឬស្ថាប័នដែលសហការជាមួយបុគ្គល ឬស្ថាប័នដទៃ ដើម្បីសម្រេចបាននូវគោលបំណងដែលបានព្រមព្រៀងគ្នាទៅវិញទៅមក។ គោលគំនិតនៃភាពជាដៃគូសំដៅលើគោលដៅរួម ការទទួលខុសត្រូវរួមចំពោះលទ្ធផល ការទទួលខុសត្រូវដាច់ដោយឡែក និងកាតព្វកិច្ចបដិទាន។ |

| | |
|---|---|
| ភាពជាដៃគូ | កិច្ចសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការរវាងដៃគូក្នុងការអនុវត្តគោលដៅរួម។ ភាពជាដៃគូ មិនមែនមានត្រឹមតែទំនាក់ទំនងផ្លូវការដែលបានបង្កើតឡើងនោះទេ ប៉ុន្តែក៏រួមមានការធ្វើការរួមគ្នាដោយឈរលើមូលដ្ឋានស្មើភាព ទំនាក់ទំនងជាប់លាប់ ភាពជាម្ចាស់ និង ការចាប់អារម្មណ៍ជាបន្តដោយដៃគូក្នុងការសម្រេចបាននូវលទ្ធផលដែលរួមចំណែកដល់គោលដៅទូលាយនៃផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| ស្នាដៃការងារ (performance) | កម្រិតដែលក្រសួង និងស្ថាប័នជាសមាជិកធ្វើប្រតិបត្តិការយោងតាមលក្ខណៈវិនិច្ឆ័យស្តង់ដារ ឬគោលការណ៍ណែនាំជាក់លាក់ ឬសម្រេចបានលទ្ធផលស្របតាមផែនការយុទ្ធសាស្ត្រជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| សូចនាករស្នាដៃការងារ | អថេរដែលអនុញ្ញាតឱ្យមានការផ្ទៀងផ្ទាត់ការផ្លាស់ប្តូរ ឬបង្ហាញលទ្ធផលទាក់ទងនឹងអ្វីដែលត្រូវបានគ្រោងក្នុងផែនការយុទ្ធសាស្ត្រជាតិ។ |
| ការតាមដានស្នាដៃការងារ | កិច្ចដំណើរការជាប្រចាំនៃការប្រមូល និងវិភាគទិន្នន័យ ដើម្បីប្រៀបធៀបថាតើផែនការយុទ្ធសាស្ត្រជាតិកំពុងត្រូវបានអនុវត្តបានល្អប៉ុណ្ណា ធៀបនឹងលទ្ធផលរំពឹងទុក លទ្ធផល និងសូចនាករ។ |
| អ្នកចូលរួមអនុវត្ត (reach) | អ្នកទទួលផល និងភាគីពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។ |
| លទ្ធផល (result) | ផលសម្រេច លទ្ធផល ឬផលប៉ះពាល់ (ដោយចេតនា ឬដោយអចេតនា វិជ្ជមាន និង/ឬអវិជ្ជមាន) នៃសកម្មភាព គម្រោង ឬកម្មវិធី។ |
| ការពិនិត្យមើលឡើងវិញ (review) | ការវាយតម្លៃលើស្នាដៃការងារនៃអន្តរាគមន៍មួយ ជាទៀងទាត់ ឬចំពោះកិច្ច។ ជាញឹកញាប់ 'ការវាយតម្លៃ' ត្រូវបានប្រើសម្រាប់ការវាយតម្លៃដ៏ទូលំទូលាយ និង/ឬស៊ីជម្រៅជាង 'ការពិនិត្យមើលឡើងវិញ' ។ ការពិនិត្យមើលឡើងវិញ មាននិន្នាការសង្កត់ធ្ងន់លើទិដ្ឋភាពប្រតិបត្តិការ។ ពេលខ្លះពាក្យ 'ពិនិត្យមើលឡើងវិញ' និង 'ការវាយតម្លៃ' ត្រូវបានប្រើជាពាក្យដែលមានន័យដូចគ្នា។ |
| ការវិភាគហានិភ័យ | ការវិភាគ ឬការប៉ាន់ប្រមាណរបៀបដែលកត្តា (ដែលហៅថា 'ការសន្មត') ប៉ះពាល់ដល់ ឬទំនងជាប៉ះពាល់ដល់ការសម្រេចបានប្រកបដោយជោគជ័យនូវគោលបំណងនៃអន្តរាគមន៍មួយ។ ការពិនិត្យលម្អិតមួយអំពីផលវិបាកដែលមិនចង់បាន និងអវិជ្ជមានចំពោះជីវិតមនុស្ស សុខភាព ទ្រព្យសម្បត្តិ ឬបរិស្ថានដែលបង្កឡើងដោយអន្តរាគមន៍អភិវឌ្ឍន៍, កិច្ចដំណើរការជាប្រព័ន្ធដើម្បីផ្តល់ព័ត៌មានទាក់ទងនឹងផលវិបាកដែលមិន |

ចង់បានបែបនេះ, កិច្ចដំណើរការនៃការកំណត់ជាបរិមាណនូវភវនីយភាព (probabilities) និងផលប៉ះពាល់ដែលរំពឹងទុកសម្រាប់ហានិភ័យដែលបានកំណត់។ សូមមើលផងដែរ *ការសន្មត* ។

| | |
|---|---|
| ភាគីពាក់ព័ន្ធ | ស្ថាប័ន អង្គការ ក្រុម ឬបុគ្គលដែលមានផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោល លើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ឬការវាយតម្លៃការអនុវត្ត។ |
| និរន្តរភាព | ការបន្តអត្ថប្រយោជន៍ពីសកម្មភាព ឬគម្រោងមួយ បន្ទាប់ពីជំនួយអភិវឌ្ឍន៍សំខាន់ៗ ត្រូវបានបញ្ចប់, លទ្ធភាពនៃអត្ថប្រយោជន៍រយៈពេលវែងជាបន្ត, ភាពធន់នឹងហានិភ័យ នៃលំហូរអត្ថប្រយោជន៍សុទ្ធតាមពេលវេលា។ |
| គោលដៅ (target) | គោលបំណងនៃស្នាដៃការងារដែលត្រូវបានកំណត់ ជាតម្លៃមួយលើសូចនាករស្នាដៃការងារ ដែលបានកំណត់។ គោលដៅដែលបានកំណត់យ៉ាងល្អគឺ 'SMART' ពោលគឺជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន ប្រាកដនិយម និងមានកំណត់ពេលវេលា។ |
| ក្រុមគោលដៅ (target group) | បុគ្គល ឬស្ថាប័នជាក់លាក់ ដែលអន្តរាគមន៍អភិវឌ្ឍន៍ត្រូវបានអនុវត្តដើម្បីផលប្រយោជន៍ពួកគេ ។ |
| ការបណ្តុះបណ្តាល | ការផ្ទេរចំណេះដឹងជារចនាសម្ព័ន្ធ ដែលអភិវឌ្ឍសមត្ថភាពបុគ្គលិក។ ចំណុចនេះរួមមានការបណ្តុះបណ្តាលនៅនឹងកន្លែង សិក្ខាសាលា ការណែនាំ និងការបង្រៀនមនុស្សពីរបៀបបណ្តុះបណ្តាលអ្នកដទៃ (ការបណ្តុះបណ្តាលគ្រូបង្គោល)។ វាអាចគឺជាខ្លឹមសារជាក់លាក់ ឬផ្អែកលើជំនាញ ហើយអាចមានលក្ខណៈជាការបណ្តុះបណ្តាលតែមួយវគ្គ ឬអាចជាការបណ្តុះណ្តាលជាបន្តបន្ទាប់៕ |

# កម្រងរូបភាពនៃដំណើររៀបចំក្របខ័ណ្ឌត្រួតពិនិត្យ វាយតម្លៃ និងសិក្សាដកពិសោធន៍ សម្រាប់ផែនការយុទ្ធសាស្រ្តជាតិប្រាំឆ្នាំ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (២០២៤-២០២៨)















# កម្រងរូបភាពនៃដំណើររៀបចំក្របខ័ណ្ឌត្រួតពិនិត្យ វាយតម្លៃ និងសិក្សាដកពិសោធន៍ សម្រាប់ផែនការយុទ្ធសាស្ត្រជាតិប្រាំឆ្នាំ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (២០២៤-២០២៨)
















# អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរ មនុស្ស ជាពិសេស ស្ត្រី និងកុមារ

## ២០១៧

អនុសញ្ញា ACTIP បានចូលជាធរមាន ហើយបច្ចុប្បន្ន រដ្ឋសមាជិកអាស៊ានទាំង ១០ មានកាតព្វកិច្ចអនុវត្តអនុសញ្ញានេះ។

## ៣

គោលបំណងសំខាន់ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងអនុសញ្ញា ACTIP គឺសំដៅ៖

ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

ការពារ និងជួយជនរងគ្រោះ និង

ជំរុញកិច្ចសហប្រតិបត្តិការ។

## ៣១

មាត្រានៅក្នុងអនុសញ្ញា ACTIP ចែងលំអិតអំពី៖

**ការចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ** (ជំពូក ២)

**ការបង្ការទប់ស្កាត់** (ជំពូក ៣)

**កិច្ចការពារ** (ជំពូក ៤)

**ការអនុវត្តច្បាប់** (ជំពូក ៥)

**កិច្ចសហប្រតិបត្តិការអន្តរជាតិ** (ជំពូក ៦)

## រដ្ឋសមាជិកអាស៊ាន

ទទួលខុសត្រូវក្នុងការអនុវត្តអនុសញ្ញា ACTIP ។

តួអង្គទាំងអស់ រួមមានអ្នកដឹកនាំក្នុងរដ្ឋាភិបាល អ្នករៀបចំគោលនយោបាយ អ្នកអនុវត្តច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវទទួលខុសត្រូវក្នុងការសម្រេចបាននូវការអនុវត្តថ្នាក់ជាតិនៃអនុសញ្ញា ACTIP។

## អង្គការមិនមែនរដ្ឋាភិបាល

ត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញា ACTIP ថាមានតួនាទីសំខាន់ក្នុងការទប់ស្កាត់ការជួញដូរ ក៏ដូចជាការជួយ និងការពារជនរងគ្រោះផងដែរ។

(មាត្រា ១១ និង ១៤)

## ឧទាហរណ៍

អនុសញ្ញា ACTIP លើកទឹកចិត្តឱ្យរដ្ឋសមាជិកអាស៊ានដាក់បញ្ចូលអភិក្រមដែលផ្តោតលើជនរងគ្រោះ យកចិត្តទុកដាក់លើយេនឌ័រ និងផ្អែកលើសិទ្ធិ។

ឧទាហរណ៍:
បង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ ដើម្បីធានាឱ្យបានថាស្ថាប័នយុត្តិធម៌អនុម័តយកការអនុវត្តដែលផ្តោតលើជនរងគ្រោះនៅក្នុងតុលាការ។

ការប្រមូល និងផ្សព្វផ្សាយទិន្នន័យ ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរ និងផ្តល់ព័ត៌មានជូនជនរងគ្រោះកាន់តែប្រសើរឡើង។

ទាញយកអនុសញ្ញា ACTIP ពីគេហទំព័រ aseanact.org

Australian Aid | ASEAN-Australia Counter Trafficking




Australian Aid | ASEAN-Australia Counter Trafficking